# សំណួរទាំង២០ ដែលអ្នកមិនមែនមូស្លីម និយមចង់ដឹង

រៀបរៀងចេញពីបាឋកថាលោកបណ្ឌិត ហ្សាគៀរ ណៃក

ប្រែសម្រួលដោយអាចារ្យ វ៉ាន វ៉ាន់ឌី

# សំណួរទាំង២០ ដែលអ្នកមិនមែនមូស្លីម និយមចង់ដឹង

រៀបរៀងចេញពីបាឋកថាលោកបណ្ឌិត. ហ្សាគៀរ ណៃក

ប្រែសម្រួលដោយអាចារ្យ. វ៉ាន វ៉ាន់ឌី

ចំណងជើង៖ សំណួរទាំង២០ដែលអ្នកមូស្លីមនិយមចង់ដឹង

ចំណងជើងដើម៖ 20 Common questions asked by Non-Muslim (who have some knowledge of Islam)

និពន្ធដោយ៖ លោកបណ្ឌិត. ហ្សាគៀរ អាប់ឌុលការីម ណៃក

ប្រែសម្រួលដោយ៖ អាចារ្យ. វ៉ាន វ៉ាន់ឌី

រចនាគម្របដោយ៖ អាចារ្យ. វ៉ាន វ៉ាន់ឌី

រចនាទំព័រដោយ៖ អាចារ្យ. វ៉ាន វ៉ាន់ឌី

បោះពុម្ពផ្សាយដោយ៖ សន្និបាទដ្ឋានអាល់ភីស

តម្លៃ៖ ១០០០០៛

បោះពុម្ពផ្សាយឆ្នាំ ២០២៣

---

អាល់ភីស

**<u>កំណត់សម្គាល់</u>**

*អក្សរទ្រេត* ប្រើសម្គាល់ថាជាអត្ថបទដកស្រង់។

សញ្ញាវង់ក្រចក() ក្រោយអក្សរទ្រេត ប្រើសម្រាប់បញ្ជាក់ប្រភពយោងអត្ថបទ។

សញ្ញាវង់ក្រចក() ក្នុងអត្ថបទធម្មតា ប្រើសម្រាប់បន្ថែមន័យ, បញ្ជាក់ន័យ, បំពេញន័យ។

សម្រាប់លេខយោងព្រះគម្ពីរគួរអាន ក្នុងវង់ក្រចក()ដំបូងគេគឺពាក្យថា ព្រះគម្ពីគួរអាន បន្ទាប់មកលេខចំពូក បន្ទាប់មកលេខវាក្យខណ្ឌ។ ឧ. (ព្រះគម្ពីរគួរអាន ៥:១) មានន័យថា អត្ថបទដកស្រង់ចេញពីព្រះគម្ពីរគួរអាន ចំពូក ៥ វាក្យខណ្ឌ ១។

---

ខ្លឹមសារ និងសេចក្តីទាំងអម្បាលម៉ានក្នុងសៀវភៅនេះជាទស្សនៈ និងការទទួលខុសត្រូវរបស់អ្នកនិពន្ធ និងពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកបកប្រែឡើយ។

រាល់ការថតចម្លងដោយគ្មានការអនុញ្ញាតជាទង្វើខុសសីលធម៌។

# ជំនូននៃប្រាជ្ញា

ជូនចំពោះ: ____________________

__________________________________________________

__________________________________________________

__________________________________________________

__________________________________________________

__________________________________________________

__________________________________________________

ពីខ្ញុំ ____________________

កាលបរិច្ឆេទ ____________________

# ចំណាររបស់អ្នកបកប្រែ

*ក្នុងព្រះនាមនៃព្រះជាម្ចាស់ដ៏មេត្តាករុណា ដ៏អាណិតអាសូរ*

*សូមភាពសុខសាន្តកើតមានដល់លោកអ្នកទាំងអស់គ្នា*

កូនសៀវភៅស្តើងដែលលោកអ្នកកំពុងកាន់ក្នុងដៃនេះ ជាស្នាដៃដ៏ប៉ិនប្រសព្វរបស់លោកឃោសនាចារ្យបណ្ឌិត ហ្សាគៀរ ណៃក ដែលជាអ្នកផ្សព្វផ្សាយសាសនាអ៊ីស្លាមជនជាតិឥណ្ឌាដ៏ល្បីល្បាញម្នាក់ខាងដោះស្រាយសំណួរផ្សេងៗ។ ក្រោយបានអានស្នាដៃនេះចប់ខ្ញុំយល់ឃើញថា គួរតែបកប្រែជាខេមរៈភាសាជូនបងប្អូនជនរួមជាតិបានសិក្សាឈ្វេងយល់ជាចំណេះដ៏សំខាន់មួយ។ សៀវភៅនេះភាគច្រើននិយាយអំពីបញ្ហាព្រះគម្ពីរគួរអាន ដែលដើមឡើយខ្ញុំយល់ថាគួរប្តូរចំណងជើងទៅជា«សំណួរសំខាន់ៗអំពីបញ្ហាក្នុងព្រះគម្ពីរគួរអាន» ក៏ប៉ុន្តែដោយមិនចង់ឱ្យប្រាសចាកឆ្ងាយពីចំណងជើងដើម ទើបសម្រេចចិត្តបកប្រែចំណងជើងដើមយកមកប្រើប្រាស់ដដែល។ មិនខុសពីសៀវភៅមុនៗរបស់ខ្ញុំឡើយ ខ្ញុំប្រើប្រាស់ពាក្យពេចន៍ និងឈ្មោះដែលសមគួរនឹងប្រើប្រាស់ក្នុងវប្បធម៌ខ្មែរ ដែលអាចនាំឱ្យរង្គៀសចិត្តបងប្អូនមូស្លីមមួយចំនួនផងដែរ។ ម្យ៉ាងទៀតអត្ថបទយោងនៃព្រះគម្ពីរគួរអានក្នុងសៀវភៅនេះ ភាគច្រើនដកស្រង់ពីសៀវភៅ«អត្ថន័យនៃព្រះគម្ពីរអាល់គួរអានជាខេមរៈភាសា»ដែលអាចជាការប្លែកមួយសម្រាប់បងប្អូនយើង។ ដោយសៀវភៅនេះជាការរៀបរៀងចេញពីបាឋកថាផ្ទាល់មាត់ ដែលភស្តុតាងសម្អាងខ្លះមិនសូវបានលើកយកមកបង្ហាញឱ្យស៊ីជម្រៅ តែខ្ញុំសូមអញ្ជើញបងប្អូនដែលមានលទ្ធភាពសូមអានសៀវភៅ«Quran and Modern science»ជាស្នាដៃរបស់លោកបណ្ឌិត ហ្សាគៀរ ណៃក ដដែលនោះនឹងទទួលបានភស្តុតាងសម្អាងខាងវិទ្យាសាស្ត្រថែមទៀត។ ម្យ៉ាងឧទាហរណ៍មួយចំនួន ខ្ញុំបានសម្រួលមកជាបរិបទខ្មែរ ដែលមិនប្រាសចាកខ្លឹមសារដើម ប៉ុន្តែឱ្យលោកអ្នកកាន់តែងាយយល់ថែមទៀត។ ខ្ញុំសូមអភ័យទោសចំពោះខ្លឹមសារ ឬការប្រើប្រាស់ពាក្យពេជចន៍ ឬកំហុសអក្ខរាវិរុទ្ធមិនត្រឹមត្រូវ និងមិនសមរម្យត្រង់ណាដោយអចេតនា។ សូមអស់លោកអ្នកអានទទួលយកសេចក្តីរាប់អាន និងសេចក្តីស្រឡាញ់អំពីខ្ញុំ។

ខ្ញុំសូមបួងសួងពីព្រះជាម្ចាស់ឱ្យសៀវភៅនេះបានជាប្រយោជន៍ពង្រឹងដល់អ្នកមានជំនឿ និង បំភ្លឺដល់អ្នកគ្មានជំនឿ បានជាអង្វែងតទៅ អាមីន!

ពីខ្ញុំ អាចារ្យ. វ៉ាន វ៉ាន់ឌី

# មាតិកា

១.តើព្រះគម្ពីរគួរអានជាការតាក់តែងរបស់អារក្សបីសាចឬយ៉ាងណា? ............................ 2

២.ព្រះគម្ពីរគួរអានពុំមែនជាព្រះគម្ពីរដើមនោះទេតែជាព្រះគម្ពីររបស់លោកអូស្មាន ប៉ុណ្ណោះ ........................................................................................................ 4

៣.តើសាសនាអ៊ីស្លាមជំរុញឱ្យមានហិង្សាឬយ៉ាងណា?................................................ 9

៤.ព្រះគម្ពីរគួរអានប្រើសព្វនាម “យើង”ចំពោះព្រះអល់ឡោះ........................................ 12

៥.សាច់ជ្រូកត្រូវបានហាមប្រាម.............................................................................. 14

៦.ទ្រឹស្តីនៃការនិរាករណ៍.........................................................................................17

៧.អត្ថន័យនៃព្យញ្ជនៈ អាលីហ្វ ឡាម មីម ..........................................................23

៨.តើព្រះគម្ពីរគួរអានលើកឡើងថាផែនដីមានរាងរាបសំប៉ែតឬយ៉ាងណា? ...................29

៩.តើមានតែព្រះអល់ឡោះទេមែនទេដែលអាចដឹងពីភេទរបស់ទារកក្នុងផ្ទៃម្តាយបាន?..32

១០.ទេពអប្សរនៃស្ថានសួគ៌ ......................................................................................34

១១.តើបេះដូងជាអ្នកទទួលមុខងារនៃការយល់ដឹងឬយ៉ាងណា?..................................37

១២.តើហេតុអ្វីទើបបានជាអ្នកមូស្លីមបែកជា និកាយផ្សេងគ្នា?.................................... 41

១៣.ព្រះអល់ឡោះបិទភ្ជិតចិត្តគំនិតអ្នកមិនជឿ............................................................45

១៤.មេឃនិងដីត្រូវបានបង្កើតក្នុងរយៈកាល៦ថ្ងៃមិនមែន៨ថ្ងៃទេ ..................................47

១៥.តើមនុស្សកើតមកអំពីទឹកអសុចិ ឬកើតមកពីដី? .................................................. 51

១៦.ព្រះអល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ទាំងពីរនិងទិសបស្ចិមទាំងពីរ......................53

១៧.តើ១ថ្ងៃសម្រាប់ព្រះអល់ឡោះ ស្មើនឹង១០០០ឆ្នាំ ឬ៥០០០០ឆ្នាំសម្រាប់មនុស្ស លោក?...........................................................................................................56

១៨.តើអ៊ីព្លីសជាទេវតា ឬជាអារក្សបីសាច?................................................................59

១៩.ព្រះគម្ពីរគួរអានគណនាគណិតវិទ្យាមិនត្រឹមត្រូវ.....................................................62

២០តើព្រះអល់ឡោះជាព្រះដ៏អភ័យទោសឬជាព្រះដ៏ចងអាឃាត?................................65

# ១

# តើព្រះគម្ពីរគួរអានជាការតាក់តែងរបស់អារក្សបីសាចឬយ៉ាងណា?

**សំណួរ៖**

តើធ្វើយ៉ាងណាទើបយើងអាចដឹងថាព្រះគម្ពីរគួរអានមិនមែនជាការតាក់តែងដោយអារក្សបីសាច?

**ចម្លើយ៖**

សំណួររបៀបនេះក៏ធ្លាប់ត្រូវបានអ្នកគោរពព្រះខុសឆ្គងនៅក្រុងម៉ាក្កះចោទសួរមកកាន់ព្យាការីមូហាំម៉ាត់ផងដែរ ដោយចោទប្រកាន់ថាលោកបានទទួលការបើកបង្ហាញពីអារក្សបីសាចមិនមែនមកពីព្រះនោះទេ។ បន្ទាប់មកព្រះជាម្ចាស់ក៏បានប្រទានវាក្យខណ្ឌមួយចុះមកដោយមានខ្លឹមសារថា៖

*«ព្រះគម្ពីរនេះគឺជាព្រះគម្ពីរគួរអានមួយដ៏ឧត្តុងឧត្តមយ៉ាងប្រាកដ។ ដែលត្រូវបានទុកក្នុងព្រះគម្ពីរអតិរក្ស ឥតមាននរណាប៉ះពាល់បានឡើយ ក្រៅតែពីអ្នកដែលល្អវិសុទ្ធ។ ជាសេចក្តីប្រទានចុះមកពីព្រះជាអម្ចាស់នៃស្ថានទាំងឡាយ។»* (ព្រះគម្ពីរគួរអាន ៥៦: ៧៧-៨០)

ពាក្យថា **«គីតាប៊ីម ម៉ាក់នូន»** ជាភាសាអារ៉ាប់ដែលប្រែជាភាសាខ្មែរថា «ព្រះគម្ពីរអតិរក្សា» មានន័យថា ព្រះគម្ពីរដែលត្រូវបានរក្សាការពារយ៉ាងល្អប្រសើរ គឺសំដៅដល់ព្រះគម្ពីរ«ឡាវហ៊ុលម៉ាស់ហ្វូស» ដែលជាព្រះគម្ពីរនៅឯស្ថានសួគ៌ ឥតមាននរណាអាចប៉ះពាល់បានឡើយក្រៅតែពីពួកជនដែលល្អវិសុទ្ធ ផុតអំពីមន្ទិលសៅហ្មងនានា សេចក្តី

អាក្រក់នានា ឬបាបជាដើម។ ពួកជនទាំងនេះគឺសម្តៅដល់ពពួកទេវតាទាំងឡាយទាំងពួង ឯចំពោះអារក្សបីសាចវិញគឺឥតមានលក្ខណៈបែបនេះឡើយ។

គិតត្រឹមថា ការណ៍ដែលអារក្សបីសាចមិនអាចទាំងទៅក្បែរ ឬប៉ះពាល់ព្រះគម្ពីរបានផង ចុះទម្រាំថាអារក្សបីសាចតាក់តែងព្រះគម្ពីរទៅទៀតនៅ តើអាចទៅរួចទេ?

ព្រះជាម្ចាស់មានព្រះបន្ទូលបញ្ជាក់បន្ថែមទៀតថាៈ

«*ហើយអារក្សបីសាចនោះក៏មិនមែនជាអ្នកយក(ព្រះគម្ពីរគួរអាន)នេះចុះទៅដែរ។ ពួកវាមិនសមទំនង ហើយក៏ពុំមានសមត្ថភាព(ធ្វើរឿងនេះដែរ)។ ប្រាកដណាស់ ពួកវាត្រូវបានគេបញ្ចៀសមិនឱ្យទាំងស្តាប់ឮ(គេសូត្រព្រះគម្ពីរផង)។*» (ព្រះគម្ពីរគួរអាន ២៦: ២១០-២១២)

# ២

# ព្រះគម្ពីរគួរអានពុំមែនជាព្រះគម្ពីរដើមនោះទេ តែជាព្រះគម្ពីររបស់លោកអូស្មានប៉ុណ្ណោះ

**សំណួរៈ**

មានគម្ពីរគួរអានជាច្រើនប្រភេទដែលត្រូវលោក អូស្មាន ប្រមូលដុតកម្ទេចចោល លើកលែងតែមួយប៉ុណ្ណោះ។ យ៉ាងនេះហើយ តើពិតឬទេដែលថាព្រះគម្ពីរគួរអានសព្វថ្ងៃនេះជាគម្ពីរដែលចងក្រងដោយលោកអូស្មានខ្លួនឯង ហើយក៏ពុំមែនជាព្រះគម្ពីរដើមនោះដែរ?

**ចម្លើយៈ**

រឿងមួយដែលគេឧស្សាហ៍យល់ច្រឡំនោះគឺការណ៍ដែលថាព្រះគម្ពីរគួរអានត្រូវបានលោក អូស្មាន ដែលជាមេដឹកនាំជំនាន់ទី៣របស់អ៊ីស្លាមជាអ្នកសន្មត់យកជាការ និងជាអ្នករៀបរៀងចេញពីសំណៅចម្លងខុសៗគ្នាជាច្រើន។ ព្រះគម្ពីរគួរអានបច្ចុប្បន្ន ដែលត្រូវបានអ្នកមូស្លីមទូទាំងពិភពលោកទុកថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះ គឺជាព្រះគម្ពីរដូចគ្នាបេះដាក់ទៅនឹងព្រះគម្ពីរដែលត្រូវបានព្រះជាម្ចាស់ប្រទានចុះមកព្យាការីមូហាំម៉ាត់។ ព្រះគម្ពីរត្រូវបានព្យាការីលោកបញ្ជាក់ថាត្រឹមត្រូវ និងត្រូវបានរៀបរៀងដោយលោកផ្ទាល់ក្រោមការបណ្តាលចិត្តពីព្រះជាម្ចាស់។ តទៅនេះយើងនឹងវែកញែកពីឬសគល់ដែលនាំឱ្យមានទស្សនៈយល់ច្រឡំថាលោក អូស្មាន ជាអ្នករៀបរៀង និងសន្មត់យកជាការណ៍។

### ក. អត្ថបទសំណេរនៃព្រះគម្ពីរគួរអានត្រូវបានព្យាការីមូហាំម៉ាត់ត្រួតពិនិត្យ និងបញ្ជាក់ពីភាពត្រឹមត្រូវដោយផ្ទាល់

នៅពេលណាហើយដែលព្យាការីលោកទទួលបានការបើកបង្ហាញពីព្រះជាម្ចាស់ ដំបូងបំផុតលោកទន្ទេញឱ្យចាំដោយខ្លួនលោក ហើយបន្ទាប់មកទើបប្រកាសអំពីសេចក្តីទាំងនោះដល់សហការីរបស់លោក និងបង្គាប់ឱ្យពួកគេកត់ត្រាផង។

លោក អូស្មាន ក៏បានទន្ទេញចាំសេចក្តីទាំងនោះផងដែរ។ ព្យាការីលោកតែងតែរួសរាន់ឱ្យពួកស្មៀន កត់ត្រាទុកនូវសេចក្តីទាំងអម្បាលម៉ានដែលលោកបានទទួល ហើយលោកពិនិត្យពិច័យ និងបញ្ជាក់ជាថ្មីម្តងទៀតដោយខ្លួនលោកផ្ទាល់។ យ៉ាងណាមិញ ព្យាការីលោកជាមនុស្សអនក្ខរជន យ៉ាងនេះហើយរាល់ពេលដែលលោកទទួលការបើកបង្ហាញពីព្រះ លោកសូត្ររាវដែលៗឱ្យសហការីរបស់លោកស្តាប់ ពួកគេស្តាប់ហើយក៏កត់ត្រាសេចក្តីទាំងនោះ ហើយព្យាការីលោកនឹងពិនិត្យឡើងវិញនូវការកត់ត្រានោះ ដោយបង្គាប់ឱ្យពួកស្មៀនសូត្រនូវអ្វីដែលខ្លួនបានកត់ត្រា។ បើការកត់ត្រាមានកំហុសឆ្គងណាមួយ លោកនឹងរួសរាន់ប្រាប់ពួកស្មៀនឱ្យកែតម្រូវឡើងវិញហើយពិនិត្យម្តងទៀត។ មិនខុសគ្នាឡើយ លោកថែមទាំងពិនិត្យវគ្គនីមួយៗនៃព្រះគម្ពីរដែលសហការីរបស់លោកបានទន្ទេញទៀតផង។ ដោយប្រើវិធីសាស្ត្របែបនេះ ព្រះគម្ពីរគួរអានទាំងមូលបានបានកត់ត្រាទុក ក្រោមការពិនិត្យពិច័យពីសំណាក់ព្យាការីដោយផ្ទាល់។

## ខ.លំដាប់លំដោយ និងការភ្ជាប់ខ្លឹមសារនៃព្រះគម្ពីរគឺដោយការបណ្តាលចិត្តពីព្រះជាម្ចាស់

ព្រះគម្ពីរគួរអានត្រូវបានប្រទានចុះមកចប់សព្វគ្រប់ដោយប្រើពេល ២២ឆ្នាំកន្លះ ដោយប្រទានចុះមកម្តងមួយផ្នែកៗ ស្របតាមតម្រូវការនៃស្ថានភាពជាក់ស្តែង។ ព្រះគម្ពីរគួរអានមិនមែនត្រូវបានព្យាការីរៀបរៀងតាមលំដាប់នៃការប្រទានចុះមុនក្រោយនោះឡើយ។ លំដាប់លំដោយ និងការភ្ជាប់ខ្លឹមសារគឺស្ថិតក្រោមការបណ្តាលចិត្ត និងណែនាំពីព្រះជាម្ចាស់មកកាន់ព្យាការីតាមរយៈទេវទូតកាព្រីយ៉ែល។ នៅពេលដែលព្រះជាម្ចាស់ប្រទានចុះវាក្យខណ្ឌណាមួយ ព្យាការីលោកបានប្រកាសសេចក្តីនោះបន្តទៅសហការីរបស់លោក ហើយលោកក៏បញ្ជាក់ប្រាប់ថាត្រូវសរសេរវាក្យខណ្ឌថ្មីនេះក្នុងចំពូកណា បន្ទាប់ពីវាក្យខណ្ឌណាផងដែរ។

ក្នុងខែរ៉ម៉ាដនរៀងរាល់ឆ្នាំ ព្យាការីរួមទាំងទេវទូតកាព្រីយ៉ែល បានពិនិត្យនិងបញ្ជាក់ឡើងវិញគ្រប់វគ្គទាំងអស់នៃព្រះគម្ពីរគួរអានទាំងមូលដែលបានប្រទានចុះមក រួមទាំង

លំដាប់លំដោយនៃវាក្យខណ្ឌផង។ នាខែរ៉ម៉ាដនចុងក្រោយមុនព្យាការីលោកទទួលមរណភាព ព្រះគម្ពីរគួរអានទាំងមូលត្រូវបានពិនិត្យនិងបញ្ជាក់ដល់ទៅ២ដង។

នេះហើយជាសក្ខីភាពបញ្ជាក់ថា ព្រះគម្ពីរគួរអានត្រូវបានរៀបរៀង និងបញ្ជាក់យកជាការណ៍ដោយព្យាការីផ្ទាល់នៅពេលលោកនៅមានជីវិត ហើយការពិនិត្យរបស់លោកគឺទាំងទៅលើការកត់ត្រា និងទៅលើការទន្ទេញរបស់សហការីលោកផង។

## គ.ព្រះគម្ពីរគួរអានត្រូវបានចម្លងទុកលើវត្ថុយ៉ាងសាមញ្ញមួយ

ព្រះគម្ពីរគួរអានដែលចប់សព្វគ្រប់ និងត្រឹមត្រូវតាមលំដាប់លំដោយ គឺមានវត្តមាននៅពេលដែលព្យាការីលោកនៅមានជីវិតនៅឡើយ។ យ៉ាងណាមិញ វាក្យខណ្ឌទាំងនោះត្រូវបានសរសេរនៅវត្ថុដោយឡែកៗពីគ្នាដូចជា បំណែកស្បែកសត្វ, ផ្ទាំងថ្មសំប៉ែតស្តើង, ស្លឹកឈើ(របៀបដូចស្លឹករឹតខ្មែរយើង), ធាងលម៉ើ, ឆ្អឹងសត្វ ជាដើម។ ក្រោយពេលព្យាការីលោកទទួលមរណភាព លោក អាប៊ូ បាកើរ មេដឹកនាំជំនាន់ទី១របស់អ៊ីស្លាមបានបញ្ជាឱ្យគេចម្លងព្រះគម្ពីរគួរអានចេញពីវត្ថុផ្សេងៗនោះមកដាក់លើវត្ថុដែលសាមញ្ញមួយគឺសន្លឹកស្បែកមានរាងដូចក្រដាស។ សន្លឹកទាំងនោះត្រូវបានចងខ្សែរភ្ជាប់គ្នា ដូច្នេះហើយក៏នឹងមិនរបូតបាត់ផ្នែកណាមួយឡើយ។

## ឃ.លោក អូស្មាន បានចម្លងព្រះគម្ពីរគួរអានចេញពីសំណុំសន្លឹកដើម

កាលជំនាន់ដើមពួកសហការីទាំងអស់គ្នា ច្រើននាំគ្នាកត់ត្រាវាក្យខណ្ឌព្រះគម្ពីរទុករៀងៗខ្លួននៅពេលណាហើយដែលពួកគេឮព្យាការីលោកសូត្យវាក្យខណ្ឌណាមួយ។ យ៉ាងណាមិញ សេចក្តីទាំងអម្បាលម៉ានដែលពួកគេកត់ត្រាពុំសុទ្ធតែត្រូវបានព្យាការីលោកពិនិត្យ និងបញ្ជាក់ថាត្រឹមត្រូវនោះទេ ដូច្នេះហើយ កំហុសនៅតែអាចកើតមាន។ ពួកសហការីខ្លះពុំបានឮព្យាការីលោកសូត្រដោយផ្ទាល់នោះទេក្រោយពេលលោកទទួលវាក្យខណ្ឌទាំងនេះពីព្រះជាម្ចាស់។ ដូច្នេះក៏មានន័យថា សហការីទាំងអស់របស់លោកអាចខ្វះចន្លោះផ្នែកផ្សេងៗគ្នានៃព្រះគម្ពីរគួរអាន។ ការណ៍នេះបានធ្វើឱ្យមានខ្វែងយោបល់គ្នាខ្លះរវាងអ្នកមូស្លីមអំពីបរិមាណនៃអត្ថបទរបស់ព្រះគម្ពីរគួរអានក្នុងជំនាន់ដែលដឹកនាំដោយលោក អូស្មាន នោះ។

លោក អូស្មាន បានខ្ចីសំណុំអត្ថបទព្រះគម្ពីរគួរអានដើមដែលបានត្រួតពិនិត្យដោយព្យាការីមូហាំម៉ាត់ ពីលោកស្រី ហាហ្វស្វា ដែលជាភរិយារបស់ព្យាការី។ លោក អូស្មាន

បានបញ្ជាឱ្យសហការី៤រូបដែលធ្លាប់ជាស្មៀនកត់ត្រាព្រះគម្ពីរគួរអានដែលព្យាការីលោក ហៅឱ្យកត់ដោយផ្ទាល់ ដោយក្រុមស្មៀននេះដឹកនាំដោយលោក ហ្សៃដ បីន ដហ្វាបិត ធ្វើការកត់ចម្លងនូវសេចក្តីចម្លងដែលត្រឹមត្រូវឥតខ្ចោះប៉ុន្មានច្បាប់ទៀត ហើយលោក អូស្មាន ក៏បានផ្ញើសេចក្តីចម្លងទាំងនេះទៅទីតាំងមជ្ឈមណ្ឌលធំៗរបស់អ៊ីស្លាមក្នុងរជ្ជកាលលោក ផងដែរ។

ម្យ៉ាងវិញទៀត ក៏មានមនុស្សម្នាមួយចំនួនបានប្រមែប្រមូលផ្នែកនានានៃព្រះគម្ពីរគួរអានមករក្សាទុកផ្ទាល់ខ្លួនពួកគេ។ អត្ថបទដែលរក្សាទាំងនេះអាចមានការខ្វះចន្លោះ និងកត់ត្រាមិនបានត្រឹមត្រូវ។ លោក អូស្មាន បានបង្គាប់ឱ្យអ្នកផងទាំងឡាយបំផ្លាញចោលអត្ថបទព្រះគម្ពីរទាំងឡាយដែលមានខ្លឹមសារខុសពីច្បាប់ដើម ក្នុងនៃរក្សាអត្ថបទដើមឱ្យបានគង់វង្សចៀសវាងការភ័ន្តច្រឡំ។ មានសេចក្តីចម្លងព្រះគម្ពីរគួរអាន២ច្បាប់ ដែលចម្លងចេញពីច្បាប់ដើមដែលពិនិត្យយកជាការណ៍ដោយព្យាការីនោះគឺត្រូវបានរក្សាទុករហូតដល់សព្វថ្ងៃ មួយច្បាប់ដម្កល់ទុកនៅសារមន្ទីរ«តាស់ស្គីន»ប្រទេសអូបេគីស្ថាន និងមួយច្បាប់ទៀតដម្កល់នៅសារមន្ទីរ«ធុបកាភី»នាទីក្រុង អ៊ីស្តង់ប៊ុល ប្រទេសតួកគី។

## ង.ស្រៈ និងវណ្ណយុត្តិត្រូវបានគេបន្ថែមសម្រាប់អ្នកដែលមិនមែនជាជនជាតិអារ៉ាប់

អត្ថបទដើមរបស់ព្រះគម្ពីរគួរអានពុំមានចុះស្រៈ និងវណ្ណយុត្តិសម្រាប់បញ្ចេញសំឡេងជាភាសាអារ៉ាប់នោះឡើយ។ ស្រៈទាំងនោះមានដូចជា ហ្វាត់តាស(ប្រហែលនឹងស្រៈា), ដាំម៉ា(ប្រហែលនឹងស្រៈុ) និង កាស់ស្រា(ប្រហែលនឹងស្រៈី)។ ជនជាតិអារ៉ាប់មិនដែលប្រើស្រៈដើម្បីដឹងអំពីរបៀបអានព្រះគម្ពីរគួរអានឱ្យត្រឹមត្រូវនោះទេ ដ្បិតជាភាសាកំណើតរបស់គេស្រេចហើយ(ដោយការចំណាំពាក្យ)។ ប៉ុន្តែសម្រាប់អ្នកមូស្លីមដែលមិនមែនជាជនជាតិអារ៉ាប់ ពួកគេពិបាកនឹងសូត្រព្រះគម្ពីរឱ្យបានត្រឹមត្រូវណាស់បើពុំមានស្រៈទេនោះ។ ស្រៈទាំងនេះត្រូវបានគេដាក់បញ្ចូលទៅក្នុងព្រះគម្ពីរគួរអានក្នុងជំនាន់អ្នកដឹកនាំទី៥គឺរាជវង្ស អ៊ុមម៉ៃយ៉ាត់ ហើយការបញ្ចូលស្រៈនេះគឺដឹកនាំដោយសម្តេច ម៉ាលិក អារ ម៉ារវ៉ាន (ឆ្នាំ ៦៨៥ ដល់ ៧០៥ គ.ស.) ក្នុងកំឡុងរជ្ជកាលអាល់ហាច្ជាច នៃប្រទេសអ៊ីរ៉ាក់។

មានអ្នកខ្លះបានប្រឆាំងទាស់ថា សេចក្តីចម្លងព្រះគម្ពីរគួរអានសព្វថ្ងៃនេះដែលយើងកំពុងប្រើប្រាស់ដែលមានស្រៈ និងវណ្ណយុត្តិផងនោះមិនដូចព្រះគម្ពីរគួរអានដើមក្នុងសម័យកាលព្យាការីនោះទេ។ ប៉ុន្តែអ្នកទាំងនោះហាក់ដូចជាភ្លេចគិតថា ពាក្យថា«គួរអាន»មានន័យថា ការសូត្រ។ ដូច្នេះហើយការរក្សាទ្រង់ទ្រាយដើម្បីរបស់ព្រះគម្ពីរគួរអានតាមរយៈការសូត្រនោះគឺសំខាន់ណាស់ មិនថាអត្ថបទនោះកត់ត្រារបៀបណា មានស្រៈឬអត់ បើការបញ្ចេញសម្លេងដូចគ្នា ក្នុងភាសាអារ៉ាប់ដូចគ្នា នោះខ្លឹមសារក៏រក្សាភាពដដែលដូចគ្នា។

## ច.ព្រះអល់ឡោះទ្រង់សន្យាថានឹងរក្សាការពារព្រះគម្ពីរគួរអានដោយអង្គទ្រង់ផ្ទាល់

ព្រះអល់ឡោះជាម្ចាស់បានសន្យាក្នុងព្រះគម្ពីរថា៖

*«ជាការប្រាកដណាស់ យើងបានប្រទានចុះនូវសេចក្តីរំឭក ហើយប្រាកដណាស់ យើងនឹងរក្សាការពារវា។»* (ព្រះគម្ពីរគួរអាន ១៥:៩)

# ៣

# តើសាសនាអ៊ីស្លាមជំរុញឱ្យមានហិង្សាយ៉ាងណា?

**សំណួរ៖**

តើសាសនាអ៊ីស្លាមជំរុញឱ្យមានហិង្សា ការបង្ហូរឈាម អំពើឃោរឃៅ ឬយ៉ាងណា? បើព្រះគម្ពីរគួរអានចែងថា អ្នកមូស្លីមត្រូវសម្លាប់ពួកអ្នកមិនជឿនៅកន្លែងណាក៏ដោយខ្លួនបានប្រទះ។

**ចម្លើយ៖**

វាក្យខណ្ឌមួយចំនួនខាងក្រោមនេះតែងតែត្រូវបានគេលើយកមកដោយខុសបរិបទ ដើម្បីបន្ទុះបង្អាប់ថា សាសនាអ៊ីស្លាមជំរុញឱ្យមានហិង្សា ហើយញុះញ៉ុងឱ្យអ្នកដើរតាមសាសនានេះសម្លាប់អ្នកក្រៅសាសនាខ្លួនចោល។

## ក.វាក្យខណ្ឌមួយក្នុងចំពូកទី ៩

វាក្យខណ្ឌខាងក្រោមដែលស្រង់ចេញពីចំពូកទី៩ ជានិច្ចជាកាលតែងតែត្រូវអ្នករិះគន់សាសនាអ៊ីស្លាមលើកយកមកនិយាយដើម្បីបង្ហាញថា សាសនាអ៊ីស្លាមជំរុញឱ្យមានហិង្សា ការបង្ហូរឈាម និងអំពើឃោរឃៅ៖

*«ចូរឯងរាល់គ្នាប្រហារពួកអ្នកគោរពព្រះខុសឆ្គងចុះ នៅកន្លែងណាក៏ដោយដែលបានប្រទះនឹងពួកគេ»* (ព្រះគម្ពីរគួរអាន ៩:៥)

## ខ.បរិបទនៃវាក្យខណ្ឌនេះគឺនៅក្នុងសមរភូមិ

អ្នករិះគន់សាសនាអ៊ីស្លាមច្រើនតែលើកយកវាក្យខណ្ឌនេះមកនិយាយទាំងខុសបរិបទ។ ដើម្បីអាចយល់បានអំពីបរិបទនោះយើងត្រូវអានចាប់ពីវាក្យខណ្ឌ១នៃចំពូកនេះមក។ ដំណើររឿងនោះគឺ ដើមឡើយមានសន្ធិសញ្ញាសន្តិភាពរវាងអ្នកមូស្លីម និងអ្នកគោរពព្រះខុសឆ្គងនៅឯទីក្រុងម៉ាក្កះ។ ក្រោយមកពួកអ្នកគោរពព្រះខុសឆ្គងទាំងនោះបានបំពាន

សន្ធិសញ្ញានេះ ពេលនោះអ្នកមូស្លីមក៏ទុករយៈពេល៤ខែឱ្យពួកអ្នកគោរពព្រះខុសឆ្គងដើម្បីកែប្រែឡើងវិញ បើមិនដូច្នេះទេគេមុខជាប្រកាសសង្គ្រាមមិនខាន។ វាក្យខណ្ឌ៥ នៃចំពូកទី៩នេះ ចែងថា៖

*«ប៉ុន្តែនៅពេលដែលខែបម្រាមបានកន្លងផុតទៅ ចូរឯងរាល់គ្នាប្រហារពួកអ្នកគោរពព្រះខុសឆ្គងចុះ នៅកន្លែងណាក៏ដោយដែលបានប្រទះនឹងពួកគេ ចូរចាប់ចងពួកគេ និងឡោមព័ទ្ធពួកគេ ហើយចាំស្ទាក់ពួកគេនៅគ្រប់ច្រក(ក្នុងសមរភូមិ)។ ប៉ុន្តែបើគេសារភាពទោសហើយ ព្រមទាំងថ្វាយបង្គំព្រះ និងបរិច្ចាគទ្រព្យហើយនោះ ចូរបើកផ្លូវឱ្យគេចុះ។ ព្រះអល់ឡោះពិតអង្គដ៏អភ័យទោស ដ៏អាណិតអាសូរ។»* (ព្រះគម្ពីរគួរអាន ៩:៥)

បរិបទនៃវាក្យខណ្ឌនេះគឺនៅក្នុងសមរភូមិ។

## គ.ឧទាហរណ៍អំពីសង្គ្រាមរវាងអាមេរិក និងវៀតណាម

យើងទាំងគ្នាបានដឹងហើយថា មានម្តងនោះអាមេរិកបានធ្វើសង្គ្រាមជាមួយវៀតណាម។ ប្រធានាធិបតី ឬមេបញ្ជាការអាមេរិកប្រាកដជាប្រាប់កងទ័ពរបស់ខ្លួនថា៖ «អ្នកទាំងអស់គ្នាត្រូវសម្លាប់ពួកវៀតណាមនៅទីណាក៏ដោយដែលអ្នកទាំងអស់គ្នាបានប្រទះ។» បច្ចុប្បន្ននេះ បើសុខៗខ្ញុំនិយាយថា ប្រធានាធិបតីអាមេរិកថ្លែងថា៖ «អ្នកទាំងអស់គ្នាត្រូវសម្លាប់ពួកវៀតណាមនៅទីណាក៏ដោយដែលអ្នកទាំងអស់គ្នាបានប្រទះ» ដោយមិនប្រាប់ពីបរិបទដំណើររឿងទេនោះ ខ្ញុំហាក់ដូចជាចោទប្រកាន់គាត់ថាជាមនុស្សសាហាវយង់ឃ្នងជាមិនខាន។ ប៉ុន្តែបើខ្ញុំនិយាយពីគាត់ដោយភ្ជាប់ជាមួយបរិបទដំណើររឿង ថាគាត់ប្រើភាសានេះក្នុងពេលសមរភូមិ វាស្តាប់ទៅពិតជាសមហេតុសមផល ព្រោះគាត់កំពុងព្យាយាមបំផុសទឹកចិត្តកងទ័ពអាមេរិករបស់គាត់ក្នុងពេលសមរភូមិ។

## ឃ.វាក្យខណ្ឌក្នុងចំពូកទី៩ គឺបំផុសទឹកចិត្តកងទ័ពមូស្លីមក្នុងសមរភូមិ

មិនខុសពីឧទាហរណ៍ខាងលើនេះទេ វាក្យខណ្ឌ៥ ចំពូក៩ ដែលចែងថា៖ *«ចូរឯងរាល់គ្នាប្រហារពួកអ្នកគោរពព្រះខុសឆ្គងចុះ នៅកន្លែងណាក៏ដោយដែលបានប្រទះនឹងពួកគេ»* គឺដើម្បីបំផុសទឹកចិត្តកងទ័ពមូស្លីម។ អ្វីដែលព្រះគម្ពីរគួរអានប្រាប់ដល់កងទ័ពមូស្លីមនោះគឺ កុំឱ្យមានការភ័យខ្លាចក្នុងសមរភូមិ បើប្រទះនឹងសត្រូវនៅត្រង់ណាចូរប្រហារនៅត្រង់នោះចុះ។

## ង.លោក សូរី រំលងពីវាក្យខណ្ឌ៥ ដល់វាក្យខណ្ឌ៧តែម្តង

លោក អារុណ សូរី គឺជាអ្នករិះគន់សាសនាអ៊ីស្លាមដ៏លេចធ្លោម្នាក់ក្នុងប្រទេសឥណ្ឌា។ លោកបានលើកឡើងពីវាក្យខណ្ឌខាងលើ គឺវាក្យខណ្ឌ៥ ចំពូក៩ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា «The world of Fatwah» ទំព័រទី៥៧២។ ក្រោយពីលោកលើកពីវាក្យខណ្ឌ៥ហើយ លោករំលងចូលវាក្យខណ្ឌ៧តែម្តងក្នុងចំពូកដដែល។ នរណាក៏អាចដឹងបានថាលោកបានរំលងវាក្យខណ្ឌ៦។

## ច.ចម្លើយមាននៅក្នុងវាក្យខណ្ឌ៦នេះហើយ

ចំពូក៩ វាក្យខណ្ឌ៦ បានផ្តល់ចម្លើយចំពោះការចោទប្រកាន់ថាសាសនាអ៊ីស្លាមជំរុញឱ្យមានហិង្សា ការបង្ហូរឈាម និងអំពើឃោរឃៅ។ វាក្យខណ្ឌនេះចែងថា៖

*«ប្រសិនបើមានពួកអ្នកគោរពព្រះខុសឆ្គងណា បានមកសុំជ្រកអាស្រ័យអំពីឯង ចូរឯងផ្តល់ជម្រកអាស្រ័យដល់ពួកគេចុះ ដើម្បីឱ្យពួកគេបានឮព្រះបន្ទូលនៃព្រះអល់ឡោះ។ បន្ទាប់មកចូរបញ្ជូនគេទៅទីសុវត្ថិភាពចុះ។ នេះក៏ដោយសារតែពួកគេ ជាអ្នកដែលមិនទាន់បានយល់ដឹងអ្វីឡើយ។»* (ព្រះគម្ពីរគួរអាន ៩:៦)

ព្រះគម្ពីរគួរអានមិនត្រឹមតែបង្គាប់ឱ្យផ្តល់ជម្រកអាស្រ័យដល់អ្នកគោរពព្រះខុសឆ្គងប៉ុណ្ណោះទេ ថែមទាំងបង្គាប់ឱ្យបញ្ជូនពួកគេទៅទីសុវត្ថិភាពទៅទៀត។ បើនិយាយពីស្ថានការណ៍អន្តរជាតិបច្ចុប្បន្នវិញ ក្នុងសមរភូមិអាចមានមេទ័ពខ្លះដែលមានសមានចិត្តល្អប្រសើរ អាចនឹងឱ្យសត្រូវរត់រស់ជីវិតបើគេចង់មានសន្តិភាពរវាងគ្នានោះ។ ប៉ុន្តែតើមានមេទ័ពឯណាដែលប្រាប់កងទ័ពរបស់ខ្លួនថា បើសត្រូវចង់មានសន្តិភាព ចូរឱ្យគេរត់រួចជីវិតចុះ ហើយថែមទាំងជួយបញ្ជូនពួកគេទៅកន្លែងសុវត្ថិភាពទៀត ទាំងស្ថិតក្នុងសមរភូមិនោះ?

នេះជាអ្វីដែលព្រះអល់ឡោះជាម្ចាស់ទ្រង់មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានដើម្បីជំរុញឱ្យមានសន្តិភាពក្នុងពិភពលោក។

# ៤

# ព្រះគម្ពីរគួរអានប្រើសព្វនាម "យើង" ចំពោះព្រះអល់ឡោះ

**សំណួរ៖**

តើសាសនាអ៊ីស្លាមជឿថាព្រះមានច្រើនឬយ៉ាងណា? ព្រោះព្រះគម្ពីរគួរអានប្រើសព្វនាម«យើង» នៅពេលព្រះមានព្រះបន្ទូល។

**ចម្លើយ៖**

សាសនាអ៊ីស្លាមជាសាសនាឯកទេពនិយមយ៉ាងប្រាកដ។ សាសនានេះមានជំនឿ និងប្រកាសថា មានព្រះតែមួយអង្គគត់គ្មានអ្វីអាចប្រៀបផ្ទឹមបានឡើយ។ សាសនានេះជឿថាមានតែព្រះអល់ឡោះមួយអង្គគត់ដែលមានលក្ខណៈឯកអគ្គភាព[1]។ ក្នុងព្រះគម្ពីរគួរអាន ព្រះជាម្ចាស់ទ្រង់ត្រាស់ហៅអង្គទ្រង់ថា «យើង»។ តែពាក្យ «យើង» នេះមិនមែនមានន័យថាព្រះមានច្រើនអង្គនោះឡើយ។

## សព្វនាមមាន២ប្រភេទ

នៅក្នុងភាសាមួយចំនួន សព្វនាមមានពីរប្រភេទគឺ ពហុវចនៈសព្វនាម ជាសព្វនាមនៃវចនៈអ្វីមួយដែលមានចំនួនលើសពីមួយ និង ឧត្តមបុរិសៈសព្វនាម ជាសព្វនាមប្រើដើម្បីផ្តល់ការគោរព។

១.ក្នុងភាសាខ្មែរ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់មានរាជឱង្ការជាផ្លូវការហៅអង្គទ្រង់ថា «យើង» ដោយមិនប្រើពាក្យថា «ខ្ញុំ» ឡើយ នេះហៅថាជាពាក្យរាជស័ព្ទ។

[1] លក្ខណៈល្អឯកវិសេសលើសលន់។

**២**.ក្នុងភាសាហីណ្ឌី លោក រ៉ាជីវ គន្ធី អតីតនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌាធ្លាប់ថ្លែងថា៖ « हूँ देखना चाहती है » ដែលមានន័យថា«យើងចង់ឃើញ»។ លោកប្រើពាក្យ « हूँ » មានន័យថា «យើង» ដែលនេះក៏ដូចគ្នាដែរ ជារាជស័ព្ទក្នុងភាសាហីណ្ឌី។

**៣**.ក្នុងភាសាអារ៉ាប់ក៏មិនខុសគ្នាដែរនៅពេលដែលព្រះអល់ឡោះទ្រង់ត្រាស់ហៅអង្គទ្រង់ថា«យើង»។ ក្នុងព្រះគម្ពីរយើងតែងតែឃើញទ្រង់ប្រើពាក្យ«ណាហ៊្ញ»ដែលមានន័យថា«យើង» នោះមិនមែនជាពហុវចនៈសព្វនាមនោះឡើយ ប៉ុន្តែជាឧត្តមបុរិសៈសព្វនាម។

គោលជំនឿឯកទេពនិយម គឺជាសសរស្តម្ភមួយនៃសាសនាអ៊ិស្លាម។ អត្ថិភាព[2] និងឯកអគ្គភាព នៃព្រះតែមួយអង្គមានលើកឡើងជាច្រើនកន្លែងក្នុងព្រះគម្ពីរគួរអាន។ ដូចមានចែងក្នុងចំពូក ១១២ ថា៖

«*ចូរពោលថា ព្រះអល់ឡោះទ្រង់តែមួយអង្គគត់*» (ព្រះគម្ពីរគួរអាន ១១២:១)

---

[2] ភាពដែលមានឡើង Existence

# ៥

# សាច់ជ្រូកត្រូវបានហាមប្រាម

**សំណួរ៖**

ហេតុអ្វីបានជាសាសនាអ៊ីស្លាមហាមប្រាមមិនឱ្យទទួលទានសាច់ជ្រូក?

**ចម្លើយ៖**

មនុស្សភាគច្រើនបានដឹងយ៉ាងច្បាស់ថាសាសនាអ៊ីស្លាមបានហាមប្រាមមិនឱ្យទទួលទានសាច់ជ្រូក។ ខាងក្រោមនេះជាចំណុចខ្លះដែលទាក់ទងនឹងការហាមប្រាមនេះ៖

## ១.សាច់ជ្រូកត្រូវបានហាមប្រាមនៅក្នុងព្រះគម្ពីរគួរអាន

ព្រះគម្ពីរគួរអានបានចែងអំពីការហាមប្រាមមិនឱ្យទទួលទានសាច់ជ្រូកមិនតិចជាង ៤ដងនោះទេ។ ការហាមប្រាមនេះមានចែងក្នុងចំពូក ២ វាក្យខណ្ឌ ១៧៣, ចំពូក ៥ វាក្យខណ្ឌ ៣, ចំពូក ៦ វាក្យខណ្ឌ ១៤៥ និងចំពូក ១៦ វាក្យខណ្ឌ ១១៥។

*«ជាបម្រាមដល់ឯងរាល់គ្នា ចំពោះសាច់សត្វស្លាប់ ឈាម សាច់ជ្រូក នឹងអ្វីដែលត្រូវបានគេពិឃាតក្នុងនាមអ្វីផ្សេងពីព្រះអល់ឡោះ។»* (ព្រះគម្ពីរគួរអាន ៥:៣)

វាក្យខណ្ឌខាងលើនេះគឺសមល្មមគ្រប់គ្រាន់សម្រាប់ឱ្យអ្នកមូស្លីមទទួលស្គាល់ថាសាច់ជ្រូកត្រូវបានហាមប្រាមយ៉ាងប្រាកដ។

## ២.សាច់ជ្រូកត្រូវបានហាមប្រាមក្នុងគម្ពីរបរិសុទ្ធ

គ្រិស្តបរិស័ទត្រូវជឿនិងស្តាប់បង្គាប់គម្ពីររបស់ខ្លួន។ គម្ពីរបរិសុទ្ធបានចែងអំពីការហាមប្រាមមិនឱ្យទទួលទានសាច់ជ្រូក ដូចមានចែងក្នុងកណ្ឌគម្ពីរលេវីវិន័យ ថា៖

*«ជ្រូក ដ្បិតវាមានក្រចកឆែក តែមិនទំពាអៀងទេ ដូច្នេះ ត្រូវចាត់ទុកវាជាសត្វមិនបរិសុទ្ធ។ អ្នករាល់គ្នាមិនត្រូវបរិភោគសាច់សត្វទាំងនោះឡើយ ហើយក៏មិនត្រូវប៉ះពាល់ខ្មោចវាដែរ គឺត្រូវចាត់ទុកវាជាសត្វមិនបរិសុទ្ធ។»* (លេវីវិន័យ ១១:៧-៨)

សាច់ជ្រូកក៏ត្រូវបានហាមប្រាមក្នុងកណ្ឌគម្ពីរទុតិយកថាផងដែរ៖

*«រីឯជ្រូកក៏មិនត្រូវបរិភោគដែរ ព្រោះវាមានក្រចកជើងឆែក តែមិនទំពាអៀងទេ។ ដូច្នេះ ត្រូវចាត់ទុកវាជាសត្វមិនបរិសុទ្ធ គឺកុំបរិភោគសាច់វា ហើយក៏កុំប៉ះពាល់ខ្មោចវាដែរ។»* (ទុតិយកថា ១៤:៨)

ការហាមប្រាមរបៀបនេះក៏មានចែងផងដែរនៅក្នុងគម្ពីរបរិសុទ្ធត្រង់កណ្ឌគម្ពីរអេសាយ ចំពូក ៦៥ ខ ២ ដល់៥ និងខ ៧។

## ៣.ការទទួលទានសាច់ជ្រូកនាំឱ្យមានរោគជាច្រើន

អ្នកដែលមិនមែនជាមូស្លីម និងអ្នកមិនកាន់សាសនានឹងឯកភាពបើយើងនិយាយពីហេតុផល តក្កៈ និងវិទ្យាសាស្ត្រ។ ការទទួលទានសាច់ជ្រូកអាចបង្កជាជំងឺមិនតិចទៀត ៣០មុខ នោះទេ។ អ្នកទទួលទានអាចប្រឈមមុខនឹងដង្កូវមួយចំនួនដូចជា ព្រូន អៀន តេនញ៉ា ។ល។ ហើយដែលគ្រោះថ្នាក់ជាងគេនោះគឺ តេនញ៉ាជ្រូក ឬភាសាសាមញ្ញហៅថា ព្រូនសំប៉ែត។ វាមានប្រវែងវែងហើយរស់ក្នុងពោះវៀនមនុស្ស ហើយពងរបស់វាអាចចូលទៅក្នុងគ្រាប់ឈាម ហើយធ្វើដំណើរទៅគ្រប់ផ្នែកនៃសារពាង្គកាយ។ បើវាចូលទៅក្នុងខួរក្បាលនោះអាចបណ្តាលឱ្យបាត់ការចងចាំ បើវាចូលទៅដល់បេះដូងវាអាចធ្វើឱ្យគាំងបេះដូង បើវាចូលទៅដល់ភ្នែក វាអាចធ្វើឱ្យភ្នែកនោះងងឹត បើវាចូលទៅក្នុងថ្លើម វាបង្កផលប៉ះពាល់ដល់ថ្លើម ហើយវាអាចបង្កផលប៉ះពាល់ដល់គ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយ។

សត្វល្អិតដ៏គ្រោះថ្នាក់មួយទៀតនោះគឺដង្កូវព្រូន ទ្រីស៊ីណែឡា ឬហៅថា ទ្រីស៊ីណែឡូស៊ីស។ រឿងដែលមនុស្សតែងតែយល់ច្រឡំនោះគឺ នៅពេលដែលគេចម្អិនសាច់ជ្រូកឱ្យឆ្អិនល្អ នោះពួកព្រូននឹងងាប់អស់។ ក្នុងគម្រោងស្រាវជ្រាវមួយនៅសហរដ្ឋអាមេរិកបានឱ្យដឹងថា ក្នុងចំណោមនុស្ស២៤នាក់ដែលមានព្រូនទ្រីស៊ីណែឡូស៊ីស គឺមាន២២នាក់បានចម្អិនសាច់ជ្រូកឱ្យឆ្អិនល្អ។ នេះសបញ្ជាក់ឱ្យដឹងថា ព្រូនមួយចំនួនមិនងាប់ក្នុងកម្រិតសីតុណ្ហភាពចម្អិនធម្មតានោះឡើយ។

## ៤.សាច់ជ្រូកមានសារធាតុធ្វើឱ្យកើនជាតិខ្លាញ់

សាច់ជ្រូកមានសាច់ដុំតិចតួចណាស់ វាផ្ទុកទៅដោយជាតិខ្លាញ់លើសលុប។ ជាតិខ្លាញ់នេះវាអាចកកស្ទះនៅតាមសរសៃឈាម ដែលអាចនាំឱ្យឡើងសម្ពាធឈាម និងគាំងបេះដូង។ វាមិនចម្លែកទេដែលជនជាតិអាមេរិកាំង៥០ភាគរយមានជំងឺលើសសម្ពាធឈាម។

## ៥.សត្វជ្រូកជាសត្វដែលកខ្វក់ជាងគេលើលោក

វារស់នៅ និងធំធាត់នៅលើភក់ជ្រាំ និងដី។ តាមដែលខ្ញុំដឹងវាជាសត្វដែលពូកែស៊ីគំរង់ជាងគេ នៅតាមភូមិករខ្លះដែលពុំទាន់មានបង្គន់ស្រួលបួល ហើយអ្នកភូមិបន្ទោបង់ពាសវាលពាលកាលនោះ  កាកសំណល់ទាំងនោះនឹងត្រូវជ្រូកសម្អាតទាល់តែអស់។

អ្នកខ្លះអាចនឹងប្រកែកថា នៅប្រទេសជឿនលឿនដូចជាអូស្ត្រាលីជាដើម ជ្រូកត្រូវបានបង្កាត់ពូជដោយស្អាតបាត និងអនាម័យ។ តែទោះជាអនាម័យយ៉ាងណាក្តី ជ្រូកត្រូវបានគេដាក់ឱ្យវារស់នៅរួមគ្នា មិនថាគេព្យាយាមសម្អាតវាយ៉ាងណានោះទេ វានៅតែកខ្វក់ដោយធម្មជាតិរបស់វា វានៅតែស៊ីគម្រង់ខ្លួនឯង និងជ្រូកដទៃទៀតដែលនៅជាមួយ។

## ៦.ជ្រូកជាសត្វឥតខ្មាសជាទីបំផុត

សត្វជ្រូកជាសត្វដែលឥតខ្មាសបំផុតលើលោកនេះ វាជាសត្វតែមួយប្រភេទគត់ដែលហៅគ្នីគ្នាមកបន្តពូជនឹងគូរបស់វា។ នៅអាមេរិកមនុស្សភាគច្រើនទទួលទានសាច់ជ្រូក ហើយមួយចំនួនបន្ទាប់ពីជប់លៀងស៊ីផឹកហើយ ពួកគេប្តូរដៃគូគ្នារួមមេត្រី។ មានតែអ្នកទទួលទានសាច់ជ្រូកទេដែលប្រព្រឹត្តរបៀបដូចជ្រូក។ ពួកយើងជាជនជាតិឥណ្ឌាមើលទៅអាមេរិកជាប្រទេសអភិវឌ្ឍន៍ជឿនលឿន និងមានរបៀប។ អ្វីក៏ដោយដែលជនជាតិអាមេរិកាំងធ្វើ មិនបានប៉ុន្មានក៏ពួកយើងធ្វើតាម។ បើយោងតាមអត្ថបទចុះផ្សាយរបស់ទស្សនាវដ្តីIsland វប្បធម៌នៃការប្តូរដៃគូររួមមេត្រី ក្លាយជាធម្មតាទៅហើយនៅទីក្រុងបុមបៃ ប្រទេសឥណ្ឌា។

# ៦

# ទ្រឹស្តីនៃការនិរាករណ៍[3]

**សំណួរៈ**

អ្នកមូស្លីមជឿលើទ្រឹស្តីនៃការនិរាករណ៍ដូចជា ជឿថាមានវាក្យខណ្ឌមួយចំនួននៃព្រះគម្ពីរគួរអានត្រូវបាននិរាករណ៍ចោល ហើយជំនួសមកវិញដោយវាក្យខណ្ឌថ្មីដែលប្រទានមកតាមក្រោយ។ តើនេះមានន័យថា ព្រះបញ្ញត្តិច្បាប់ខុស ហើយកែវិញតាមក្រោយឬយ៉ាងណា?

**ចម្លើយៈ**

## ក.មានការពន្យល់២យ៉ាង

ព្រះគម្ពីរគួរអានបានចែងថាៈ

*«វាក្យខណ្ឌណាក៏ដោយដែលយើងផ្លាស់ប្តូរ ឬធ្វើឱ្យឯង(ព្យាការីមូហាំម៉ាត់)ភ្លេចវានោះ គឺយើងបាននាំមកនូវអ្វី(វាក្យខណ្ឌ)ដែលល្អប្រសើរជាង ឬប្រហាក់ប្រហែលគ្នាវិញ។ តើឯងមិនដឹងទេឬថាព្រះអល់ឡោះព្រះអង្គពិតជាមានព្រះចេស្តាលើរាល់សព្វសារពើនោះ?»* (ព្រះគម្ពីរគួរអាន ២:១០៦)

វាក្យខណ្ឌរបៀបនេះក៏មានចែងផងដែរក្នុងចំពូក ១៦ វាក្យខណ្ឌ ១០១។ នៅក្នុងភាសាអារ៉ាប់លើកឡើងអំពីពាក្យថា «អាយ៉ាត់» ដែលមានន័យថា «ទីសម្គាល់» ឬ «វាក្យខណ្ឌ» ហើយក៏មានន័យថា«ការបើកបង្ហាញ»ផងដែរ។ វាក្យខណ្ឌមួយនេះអាចធ្វើការបកស្រាយបាន២យ៉ាងខុសគ្នាៈ

[3] ការលុបចោលច្បាប់មួយ ហើយជំនួសមកវិញនូវច្បាប់មួយផ្សេងទៀត។

១.គឺសំដៅដល់ការបើកបង្ហាញកាលពីជំនាន់មុនត្រូវនិរាករណ៍ចោល នោះគឺការបើកបង្ហាញមុនព្រះគម្ពីរគួរអាន ដូចជា៖ ព្រះគម្ពីរសម្ពន្ធមេត្រីចាស់, ព្រះគម្ពីរទំនុកតម្កើង និងព្រះគម្ពីរសម្ពន្ធមេត្រីជាដើម។

ក្នុងន័យនេះព្រះអល់ឡោះជាម្ចាស់ មានព្រះបន្ទូលថា ព្រះអង្គមិនធ្វើឱ្យភ្លេចនូវព្រះគម្ពីរមុនៗនោះទេ ក៏ប៉ុន្តែបានជំនួសមកវិញនូវព្រះគម្ពីរដែលប្រសើរជាងនោះ។ ដែលមានន័យថាព្រះគម្ពីរសម្ពន្ធមេត្រីចាស់, ព្រះគម្ពីរទំនុកតម្កើង និងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ត្រូវនិរាករណ៍ដោយព្រះគម្ពីរគួរអានមកជំនួសវិញ។

២.បើយើងយកពាក្យ «អាយ៉ាត់» ជាភាសាអារ៉ាប់ខាងលើមកពិចារណាក្នុងន័យ «វាក្យខណ្ឌ»នៃព្រះគម្ពីរគួរអានហើយមិនសម្តៅដល់ព្រះគម្ពីរមុនៗវិញនោះ វាក្យខណ្ឌនេះសំដៅថា ពុំមានវាក្យខណ្ឌណាត្រូវព្រះជាម្ចាស់និរាករណ៍ចោលនោះទេ ប៉ុន្តែត្រូវបានព្រះអង្គប្រទានវាក្យខណ្ឌដោយឡែកជំនួសមកវិញ ដោយមានលក្ខណៈប្រហាក់ប្រហែលឬល្អប្រសើរជាង។ នេះមានន័យថា វាក្យខណ្ឌដែលបានប្រទានមកខាងដើមៗមួយចំនួន ត្រូវបានជំនួសមកវិញដោយវាក្យខណ្ឌដែលបានប្រទានមកក្រោយៗវិញ។ ខ្ញុំឯកភាពចំពោះការពន្យល់ទាំង២ខាងលើនេះ។

មានអ្នកមូស្លីម និងមិនមែនមូស្លីមជាច្រើនបានយល់ច្រឡំទៅលើការពន្យល់ទី២ថា វាក្យខណ្ឌខាងដើមៗមួយចំនួនត្រូវបាននិរាករណ៍ចោល ហើយសព្វថ្ងៃគ្មានសារៈសំខាន់ចំពោះយើងទៀតទេ ព្រោះមានវាក្យខណ្ឌដទៃមកជំនួសហើយ។ អ្នកទាំងនេះអាចនឹងយល់ថាវាក្យខណ្ឌទាំងនេះមិនស្របគ្នាទៅទៀត។

ចូរយើងមកវិភាគឧទាហរណ៍ខាងក្រោមជាមួយគ្នា

## ខ.ការតាក់តែងគម្ពីរឱ្យដូចព្រះគម្ពីរគួរអានទាំងមូល ឬត្រឹម១០ចំពូក ឬ១ចំពូក

ជនជាតិអារ៉ាប់ដែលមិនជឿព្រះមួយចំនួនបានចោទប្រកាន់ព្យាការីមូហាំម៉ាត់ថាលោកបានប្រតិដ្ឋព្រះគម្ពីរគួរអានឡើងដោយខ្លួនឯង។ ព្រះអល់ឡោះជាម្ចាស់បានល្បងភ្នាល់នឹងពួកជនទាំងនោះដូចមានចែងក្នុងចំពូក ១៧ នៃព្រះគម្ពីរគួរអានថា៖

*«ចូរឯងពោលថា៖ ប្រសិនបើមនុស្សលោក និងអមនុស្ស បានរួមគ្នាដើម្បីនឹងតាក់តែង(គម្ពីរមួយ)ឱ្យដូចនឹងព្រះគម្ពីរគួរអាននេះ ក៏ពួកគេមិនអាចធ្វើទៅរួចឡើយ បើទោះជាខំជួយគ្នាយ៉ាងណាក៏ដោយ។»* (ព្រះគម្ពីរគួរអាន ១៧:៨៨)

ការល្បងភ្នាល់នេះក៏ត្រូវបានសម្រាលឱ្យងាយមួយកម្រិតទៀត ក្នុងចំពូក ១១៖

*«ឬពួកគេនឹងនិយាយថា៖ គាត់(ព្យាការីមូហាំម៉ាត់)បានប្រឌិតវា(ព្រះគម្ពីរគួរអាន)។ ចូរឯងពោលថា៖ ចូរអ្នករាល់គ្នានាំយក១០ចំពូក ឱ្យដូចនឹងការប្រឌិតទាំងនេះមក ហើយចូរអ្នករាល់គ្នាហៅអ្នកណាក៏ដោយដែលអ្នករាល់គ្នាអាចហៅបានក្រៅពីព្រះអល់ឡោះ(ឱ្យមកជួយ) ប្រសិនបើអ្នករាល់គ្នានិយាយការពិតមែននោះ។»* (ព្រះគម្ពីរគួរអាន ១១:១៣)

បន្ទាប់មកការល្បងភ្នាល់សម្រាលមកត្រឹមមួយចំពូកប៉ុណ្ណោះ៖

*«ឬពួកគេនឹងនិយាយថា៖គាត់(ព្យាការីមូហាំម៉ាត់)បានប្រឌិតវា(ព្រះគម្ពីរគួរអាន)។ ចូរឯងពោលថា៖ ចូរអ្នករាល់គ្នានាំយក១ចំពូក ដែលដូចនឹង(ព្រះគម្ពីរ)នេះមក ហើយចូរអ្នករាល់គ្នាហៅអ្នកណាក៏ដោយដែលអ្នករាល់គ្នាអាចហៅបានក្រៅពីព្រះអល់ឡោះ(ឱ្យមកជួយ) ប្រសិនបើអ្នករាល់គ្នានិយាយការពិតមែននោះ។»* (ព្រះគម្ពីរគួរអាន ១០:៣៨)

ជាចុងក្រោយក្នុងចំពូក២ ព្រះអល់ឡោះបានធ្វើឱ្យការល្បងភ្នាល់នេះកាន់តែងាយថែមទៀត៖

*«ប្រសិនបើឯងរាល់គ្នាមានមន្ទិលសង្ស័យចំពោះអ្វី (ព្រះគម្ពីរអាល់គួរអាន) ដែលយើងបានប្រទានចុះមកដល់អ្នកបម្រើយើង(ព្យាការីមូហាំម៉ាត់)នោះ ចូរឯង(និពន្ធហើយ)យកចំពូកណាមួយ (ដែលនិពន្ធនោះ) មកប្រដូចនឹងព្រះគម្ពីរនេះ ហើយចូរឯងហៅសាក្សីរបស់ពួកឯងក្រៅពីព្រះអល់ឡោះមកចុះ បើសិនជាការអះអាងរបស់ឯងត្រឹមត្រូវមែននោះ។ ប្រសិនបើពួកឯងមិនអាចធ្វើបានទេនោះ អំណើះតទៅមុខក៏ពួកឯងមិនអាចធ្វើបានដែរ។ ដូច្នេះហើយ ចូរឯងរាល់គ្នាខ្លាចរអែងចំពោះស្ថាននរក ដែលឥន្ធនៈបញ្ឆេះនរកនោះគឺជាមនុស្ស និងដុំថ្ម ដែលគេរៀបចំសម្រាប់ពួកគ្មានជំនឿ។»* (ព្រះគម្ពីរគួរអាន ២:២៣-២៤)

យើងឃើញថា ព្រះអល់ឡោះជាម្ចាស់បានសម្រាលការល្បងភ្នាល់នេះជាដំណាក់ៗ។ ដំណាក់កាលដំបូង ព្រះគម្ពីរគួរអានចែងអំពីការល្បងភ្នាល់ឱ្យតែងនិពន្ធគម្ពីរមួយឱ្យបានដូចព្រះគម្ពីរគួរអាន។ បន្ទាប់មកបន្ថយត្រឹមតែធ្វើយ៉ាងណាឱ្យបាន១០ចំពូក ឱ្យ

បានដូចចំពូកក្នុងព្រះគម្ពីរគួរអាន ហើយចុងក្រោយបន្ថយមិនត្រឹមតែឱ្យតែងនិពន្ធតែមួយចំពូកប៉ុណ្ណោះតែធ្វើយ៉ាងឱ្យដូច ឬ ប្រហាក់ប្រហែលនឹងចំពូកក្នុងព្រះគម្ពីរគួរអាន។ នេះមិនមែនមានន័យថា ចំពូក២ វាក្យខណ្ឌ ២៣ និង ២៤ នេះមានខ្លឹមសារមិនស្របនឹងវាក្យខណ្ឌទាំងពាខាងលើៗនោះទេ។ ពាក្យថាមិនស្របគ្នា គឺទាល់តែមានការលើកឡើងអំពីព័ត៌មានខុសគ្នា ដែលមិនអាចកើតឡើងព្រមៗគ្នាបាន ឧទាហរណ៍លោក ក ផ្តល់ព័ត៌មានថាលោក គ ស្លាប់នៅអាយុ៥៩ឆ្នាំ ឯលោក ខ ផ្តល់ព័ត៌មានថាលោក គ ស្លាប់នៅអាយុ ៥៥ ឆ្នាំ។ ព័ត៌មានទាំងពីរលើកឡើងខុសគ្នាអំពីព្រឹត្តការណ៍តែមួយ រាប់ថាមិនស្របគ្នា។

វាក្យខណ្ឌខាងដើមៗ ឬថាវាក្យខណ្ឌដែលគេថានិរាករណ៍ចោលនោះ គឺសុទ្ធតែជាព្រះបន្ទូលរបស់ព្រះ ហើយផ្ទុកនូវព័ត៌មានដែលត្រឹមត្រូវរហូតមកដល់សព្វថ្ងៃ។ ហើយជាការពិតណាស់ ការល្បងភ្នាល់អំពីការតែងនិពន្ធព្រះគម្ពីរគួរអាននេះគឺនៅបន្តមកដល់សព្វថ្ងៃ។ ការល្បងភ្នាល់អំពីការតែងនិពន្ធ១០ចំពូកឱ្យបានដូចព្រះគម្ពីរគួរអានក្តី ១ចំពូកឱ្យដូចព្រះគម្ពីរគួរអានក្តី ឬ១ចំពូកដែលត្រឹមតែប្រហាក់ប្រហែលនឹងព្រះគម្ពីរគួរអានក្តី សុទ្ធតែជាការល្បងភ្នាល់ដ៏ពិតប្រាកដទាំងអស់ ព្រោះវាមិនមានអ្វីដែលមិនស្របនឹងគ្នានោះទេ ប៉ុន្តែនេះក៏ជាការល្បងភ្នាល់ដែលងាយជាងគេដែលព្រះគម្ពីរគួរអានបានលើកឡើង។ បើការតែងនិពន្ធមួយចំពូកឱ្យបានត្រឹមតែប្រហាក់ប្រហែល មិនអាចធ្វើទៅរួចផង តើមានអ្វីត្រូវទៅនិយាយពី១ចំពូក និង១០ចំពូកដែលដូចទៀតនោះ?

ឧបមាខ្ញុំនិយាយអំពីមនុស្សម្នាក់ដែលមហាសែនល្ងង់ ខ្ញុំនិយាយថា៖«គាត់ល្ងង់ណាស់ អន់ជាសិស្សថ្នាក់ទី១០ទៀត។» ក្រោយមកខ្ញុំនិយាយថា៖ «គាត់អន់ជាងសិស្សថ្នាក់ទី៥ទៀត» បន្ទាប់មកខ្ញុំថា៖ «មិនត្រឹមតែប៉ុណ្ណឹងទេ អន់ជាងក្មេងថ្នាក់ទី១ទៅទៀត។» នៅពេលខ្ញុំនិយាយថា គាត់អន់ជាងក្មេងថ្នាក់ទី១ទៀតនោះ មានន័យថា អ្វីដែលខ្ញុំលើកឡើងនេះមិនទាស់គ្នានឹងប្រយោគពីរខាងលើនោះទេ។ ប៉ុន្តែប្រយោគចុងក្រោយរបស់ខ្ញុំគឺបញ្ជាក់ពីកម្រិតនៃភាពល្ងង់ខ្លៅរបស់គាត់បានពេញលេញតែម្តង។ បើគាត់ល្ងង់ជាងក្មេងថ្នាក់ទី១ហើយ តើមានអ្វីត្រូវទៅជជែកពីថ្នាក់ទី៥ ឬទី១០ទៀតនោះ?

### គ.ការហាមប្រាមចំពោះគ្រឿងស្រវឹងជាដំណាក់កាល

ឧទាហរណ៍អំពីរឿងនេះមួយទៀតគឺវាក្យខណ្ឌដែលចែងអំពីការហាមប្រាមចំពោះគ្រឿងស្រវឹងជាដំណាក់កាល។ វាក្យខណ្ឌដំបូងៗដែលព្រះជាម្ចាស់ប្រទានចុះមកទាក់ទងនឹងរឿងគ្រឿងស្រវឹងគឺមាននៅក្នុងចំពូក ២ ៖

*«ពួកគេនឹងសួរឯងអំពីគ្រឿងស្រវឹង និងល្បែងស៊ីសង។ ចូរឯងឆ្លើយថា៖ ក្នុងវាទាំងពីរនេះគឺមានទុក្ខទោសធំ តែក៏មានគុណប្រយោជន៍ខ្លះដល់មនុស្សលោកដែរ។ ប៉ុន្តែបាបរបស់វា ទាំងពីរគឺធ្ងន់ធ្ងរជាងគុណប្រយោជន៍ទៅទៀត។»* (ព្រះគម្ពីរគួរអាន ២:២១៩)

ហើយវាក្យខណ្ឌបន្តទៅនេះក៏ចែងទាក់ទងនិងគ្រឿងស្រវឹងផងដែរក្នុងចំពូក៤៖

*«ម្នាលអស់អ្នកមានជំនឿទាំងឡាយអើយ! ចូរកុំថ្វាយបង្គំព្រះឡើយនៅពេលស្រវឹង (ត្រូវរង់ចាំ)រហូតដល់ដឹងថាខ្លួននិយាយអ្វីសិន។ »* (ព្រះគម្ពីរគួរអាន ៤:៤៣)

វាក្យខណ្ឌចុងក្រោយដែលចែងទាក់ទងនឹងគ្រឿងស្រវឹងនោះគឺនៅក្នុងចំពូក៥៖

*«ម្នាលអស់អ្នកមានជំនឿទាំងឡាយអើយ! គ្រឿងស្រវឹង ល្បែងស៊ីសង ការគោរពបូជាបដិមា ការជឿព្រួញទស្សន៍ទាយ ជាអំពើដ៏គួរស្អប់ខ្ពើមរបស់អារក្សបីសាចប៉ុណ្ណោះ។ ចូរចៀសចេញឱ្យឆ្ងាយ នោះឯងរាល់គ្នាអាចនឹងទទួលបានជោគជ័យ។»* (ព្រះគម្ពីរគួរអាន ៥:៩០)

ព្រះគម្ពីរគួរអានត្រូវបានប្រទានចុះមកដោយប្រើរយៈពេល២២ឆ្នាំកន្លះ។ មានការធ្វើកំណែទម្រង់សង្គមជាច្រើនត្រូវធ្វើឡើងជាដំណាក់កាល នេះជាការសម្រួលដល់មនុស្សម្នាដើម្បីឱ្យពួកគេអាចទទួលយកច្បាប់ថ្មីបានដោយងាយស្រួល ឯការផ្លាស់ប្តូរដោយបង្ខំនិងលឿនរហ័សអាចនាំរកការបះបោរ និងច្របូកច្របល់ក្នុងសង្គម។

ការហាមប្រាមចំពោះគ្រឿងស្រវឹងត្រូវបានធ្វើឡើងជា៣ដំណាក់កាល។ វាក្យខណ្ឌដំបូងៗគ្រាន់តែលើកឡើងពីទុក្ខទោស និងផលបាបរបស់វា ឯប្រយោជន៍របស់វាមានតិចតួចប៉ុណ្ណោះធៀបនឹងបាប។ ដំណាក់កាលបន្ទាប់គឺការហាមប្រាមមិនឱ្យថ្វាយបង្គំព្រះពេលស្រវឹង ដែលសំដៅថា មនុស្សមិនត្រូវទទួលទានគ្រឿងស្រវឹងនៅពេលថ្ងៃនោះទេ ពីព្រោះអ្នកមូស្លីមត្រូវថ្វាយបង្គំព្រះ៥ដងក្នុងមួយថ្ងៃ។ វាក្យខណ្ឌនេះក៏សំដៅថា បើអ្នកនោះមិនថ្វាយបង្គំនៅពេលយប់ទេនោះ(ថ្វាយបង្គំរួចរាល់) គេត្រូវបានអនុញ្ញាតឱ្យទទួលទានគ្រឿង

ស្រវឹង។ នេះមានន័យថាគ្រឿងស្រវឹងអនុញ្ញាតិផង និងមិនអនុញ្ញាតផង។ ព្រះគម្ពីរគួរអាន មិនបកស្រាយច្រើនអំពីបញ្ហានេះទេ ព្រោះបើព្រះគម្ពីរចែងថា មនុស្សអាចទទួលទានគ្រឿង ស្រវឹងបានកាលណាគេមិនថ្វាយបង្គំព្រះ នោះមុខជាមានការខ្វែងយោបល់គ្នាជាមិនខាន។ ព្រះអល់ឡោះជាម្ចាស់ព្រះអង្គយកពាក្យដែលសមគួរ និងត្រឹមត្រូវបំផុតមកប្រើប្រាស់។ ចុង ក្រោយការហាមប្រាមដាច់ខាតចំពោះការទទួលទានគ្រឿងស្រវឹងមិនថាពេលណាក៏ដោយ ត្រូវបានចែងក្នុងចំពូក៥ វាក្យខណ្ឌ៩០។

ឧបមាខ្ញុំនិយាយថា «ខ្ញុំមិនបានរស់នៅទីក្រុងឡូសអាន់ជើឡេសទេ» ក្រោយមកខ្ញុំ ថា «ខ្ញុំមិនបានរស់នៅរដ្ឋកាលីហ្វ័រញ៉ាទេ» ហើយចុងក្រោយខ្ញុំនិយាយថា «ខ្ញុំមិនបានរស់ នៅសហរដ្ឋអាមេរិកទេ»។ នេះមិនមែនមានន័យថា ប្រយោគទាំង៣ដែលខ្ញុំលើកឡើង នោះមិនស្របគ្នាទេ។ ប្រយោគនីមួយៗផ្តល់ព័ត៌មានបំពេញបន្ថែមពីប្រយោគមុន ហើយ ប្រយោគចុងក្រោយផ្ទុកសរុបព័ត៌មានដែលក្នុង២ប្រយោគមុន។ យ៉ាងណាមិញ បើខ្ញុំត្រឹម តែប្រាប់ថា«ខ្ញុំមិនរស់នៅសហរដ្ឋអាមេរិកទេ» វាក៏សរុបទាំងអស់ថា ខ្ញុំមិនរស់នៅរដ្ឋ កាលីហ្វ័រញ៉ា ឬរដ្ឋណាឯទៀតនោះដែរ។ មិនខុសគ្នាទេ ដោយគ្រឿងស្រវឹងត្រូវបានហាម ប្រាមដាច់ខាតហើយនោះ ក៏មានន័យថា ការថ្វាយបង្គំព្រះនៅពេលស្រវឹងក៏ត្រូវហាមប្រាម ដាច់ខាត ហើយព័ត៌មានដែលថា គ្រឿងស្រវឹងផ្តល់ទុក្ខទោសធំសម្បើម ហើយមាន ប្រយោជន៍តិចតួច តែបាបនោះធំធេងជាងប្រយោជន៍ នៅតែជាព័ត៌មានត្រឹមត្រូវដដែល។

## ឃ.ព្រះគម្ពីរគួរអានគ្មានអ្វីដែលខ្វែងគ្នានោះទេ

ការនិរាករណ៍បញ្ញត្តិខ្លះពុំមែនមានន័យថា ព្រះគម្ពីរគួរអានមានចំណុចខ្វែងគ្នានោះ ឡើយ។ ព្រោះអ្នកបដិបត្តិអាចបដិបត្តិច្បាប់ទាំងអស់នៅក្នុងព្រះគម្ពីរព្រមៗគ្នាបាន។

ប្រសិនបើក្នុងព្រះគម្ពីរគួរអានមានផ្ទុកខ្លឹមសារខ្វែងគ្នានោះ ព្រះគម្ពីរនេះមិនអាចជា ព្រះបន្ទូលនៃព្រះជាម្ចាស់បានឡើយ។

*«តើពួកគេមិនពិចារណាអំពីព្រះគម្ពីរគួរអានទេឬ? ប្រសិនបើព្រះគម្ពីរគួរអានមិន មែនមកពីព្រះអល់ឡោះនោះ គេមុខជានឹងឃើញរឿងខ្វែងគ្នាជាច្រើននៅក្នុងនោះ។»* (ព្រះគម្ពីរគួរអាន ៤:៨២)

# ៧

# អត្ថន័យនៃព្យញ្ជនៈ អាលីហ្វ ឡាម មីម

**សំណួរ៖**

តើហេតុអ្វីបានជាចំពូកមួយចំនួននៃព្រះគម្ពីរគួរអានផ្ដើមដោយព្យញ្ជនៈទោលដូចជា៖ អាលីហ្វ ឡាម មីម, ហា មីម ឬ យ៉ា ស៊ីន ជាដើម? តើព្យញ្ជនៈទាំងនេះមានអត្ថន័យពិសេសអ្វីទេ?

**ចម្លើយ៖**

## ក.ព្យញ្ជនៈសង្ខេប

ព្យញ្ជនៈ អាលីហ្វ(ا) ឡាម(ل) មីម(م), យ៉ា(ي) ស៊ីន(س), ហា(ح) មីម(م) ជាដើមត្រូវបានគេស្គាល់ជាភាសាអារ៉ាប់ថា «អាល់-មូកត់-តអាត់» ឬជាភាសាខ្មែរហៅថា «ព្យញ្ជនៈសង្ខេប»។ ក្នុងភាសាអារ៉ាប់មានព្យញ្ជនៈ២៩តួ (នេះបើរាប់ អាលីហ្វ(ا) និង ហាំហ្សះ(ء) ថាជាព្យញ្ជនៈ២ទទៃពីគ្នា) ហើយក្នុងព្រះគម្ពីរគួរអានទាំងមូល ចំពូកដែលផ្ដើមដោយព្យញ្ជនៈសង្ខេបនេះមាន២៩ចំពូក។ ព្យញ្ជនៈសង្ខេបនេះ ក្នុងចំពូកខ្លះមានតែ១តួ ចំពូកខ្លះមាន២, ៣, ៤ និង៥តួក៏មាន។

១. សេចក្ដីផ្ដើមដោយព្យញ្ជនៈ ១ តួមាន ៣ ចំពូករួមមាន៖

- ចំពូក ៣៨ ផ្ដើមដោយព្យញ្ជនៈ សត់ (ص)
- ចំពូក ៥០ ផ្ដើមដោយព្យញ្ជនៈ កហ្វ (ق)
- ចំពូក ៦៨ ផ្ដើមដោយព្យញ្ជនៈ នូន (ن)

២. សេចក្ដីផ្ដើមដោយព្យញ្ជនៈ ២ តួមាន ១០ ចំពូករួមមាន៖

- ចំពូក ២០ ផ្ដើមដោយព្យញ្ជនៈ ត(ط) ហា(ه)
- ចំពូក ២៧ ផ្ដើមដោយព្យញ្ជនៈ ត(ط) ស៊ីន(س)

- ចំពូក ៣៦ ផ្ដើមដោយព្យញ្ជនៈ យ៉ា(ي) ស៊ីន(س)
  ក្នុងនោះមាន ៧ ចំពូកដែលផ្ដើមដោយព្យញ្ជនៈ ហា(ح) មីម(م) ដូចគ្នា រួមមាន៖
- ចំពូក ៤០ ឈ្មោះថា «អ្នកអភ័យទោស»
- ចំពូក ៤១ ឈ្មោះថា «រៀបរាប់ពិស្ដារ»
- ចំពូក ៤២ ឈ្មោះថា «ការជំនុំ»
- ចំពូក ៤៣ ឈ្មោះថា «គ្រឿងលម្អ»
- ចំពូក ៤៤ ឈ្មោះថា «ផ្សែង»
- ចំពូក ៤៥ ឈ្មោះថា «ការលុតជង្គង់»
- ចំពូក ៤៦ ឈ្មោះថា «ផ្នូកខ្សាច់»

៣. សេចក្ដីផ្ដើមដោយព្យញ្ជនៈ ៣ តួមាន ១៤ ចំពូក៖

ក្នុងនោះមាន ៦ ចំពូកផ្ដើមដោយព្យញ្ជនៈ អាលីហ្វ(ا) ឡាម(ل) មីម(م)ដូចគ្នារួមមាន៖

- ចំពូក ២ ឈ្មោះថា «គោញី»
- ចំពូក ៣ ឈ្មោះថា «គ្រួសារលោកអ៊ីមរ៉ន»
- ចំពូក ២៩ ឈ្មោះថា «សត្វពីងពាង»
- ចំពូក ៣០ ឈ្មោះថា «ទីក្រុងរ៉ូម»
- ចំពូក ៣១ ឈ្មោះថា «លោកលុកម៉ាន»
- ចំពូក ៣២ ឈ្មោះថា «លុតក្រាប»

បន្ទាប់មកមាន ៦ ចំពូកផ្ដើមដោយព្យញ្ជនៈ អាលីហ្វ(ا) ឡាម(ل) រ៉(ر) ដូចគ្នារួមមាន៖

- ចំពូក ១០ ឈ្មោះថា «ព្យាការីយ៉ូណាស»
- ចំពូក ១១ ឈ្មោះថា «ព្យាការីហ៊ូត»
- ចំពូក ១២ ឈ្មោះថា «ព្យាការីយ៉ូសែប»
- ចំពូក ១៣ ឈ្មោះថា «ផ្គរ»
- ចំពូក ១៤ ឈ្មោះថា «ព្យាការីអប្រាហាំ»

- ចំពូក ១៥ ឈ្មោះថា «ច្រកផ្លូវថ្ម»

ចុងក្រោយមាន ២ ចំពូកផ្ដើមដោយព្យញ្ជនៈ ត(ط) ស៊ីន(س) មីម(م) ដូចគ្នា រួមមាន៖

- ចំពូក ២៦ ឈ្មោះថា «កវី»
- ចំពូក ២៨ ឈ្មោះថា «ការនិទាន»

៤. សេចក្ដីផ្ដើមដោយព្យញ្ជនៈ ៤ តួមាន ២ ចំពូករួមមាន៖

- ចំពូក ៧ ឈ្មោះថា«ខណ្ឌដ៏ខ្ពស់»ផ្ដើមដោយព្យញ្ជនៈ អាលីហ្វ(ا) ឡាម(ل) មីម(م) សត់(ص)
- ចំពូក ៨ ឈ្មោះថា«ជ័យភណ្ឌ»ផ្ដើមដោយព្យញ្ជនៈ អាលីហ្វ(ا) ឡាម(ل) មីម(م) រ៉(ر)

៥.សេចក្ដីផ្ដើមដោយព្យញ្ជនៈ ៥ តួមាន ២ ចំពូករួមមាន៖

- ចំពូក ១៩ ឈ្មោះថា«នាងម៉ារី»ផ្ដើមដោយព្យញ្ជនៈ កាហ្វ (ك) ហា(ه) យ៉ា(ي) អ៊ីន(ع) សត់ (ص)
- ចំពូក ៤២ ឈ្មោះថា«ការជំនុំ»ផ្ដើមដោយព្យញ្ជនៈ ហា(ح) មីម(م) អ៊ីន(ع) ស៊ីន(س) កហ្វ(ق)

ចំពូក ៤២ នេះមានលក្ខណៈប្លែកគេ ដ្បិតវាក្យខណ្ឌ១ មាន ២ ព្យញ្ជនៈ វាក្យខណ្ឌ២មាន ៣ ព្យញ្ជនៈ សរុបទាំង២វាក្យខណ្ឌទើបបាន ៥ ព្យញ្ជនៈ។

## ខ.អត្ថន័យនៃព្យញ្ជនៈសង្ខេបទាំងនេះ

អំពីអត្ថន័យ និងគោលបំណងនៃការប្រទានចុះព្យញ្ជនៈសង្ខេបទាំងនេះគ្មាននរណាបានដឹងប្រាកដឡើយក្រៅពីព្រះអល់ឡោះ។ មានការពន្យល់បកស្រាយមួយចំនួនដែរដែលអស់លោកជាសាសនវិទូអ៊ីស្លាមក្នុងសម័យកាលមុនៗខ្លះបានផ្ដល់ឱ្យយើង ក្នុងនោះមានដូចជា៖

**១.**ព្យញ្ជនៈទាំងនេះប្រហែលជាព្យញ្ជនៈសង្ខេបនៃប្រយោគ និងពាក្យជាក់លាក់មួយជាឧទាហរណ៍. ព្យញ្ជនៈ អាលីហ្វ(ا) ឡាម(ل) មីម(م) អាចមកពីប្រយោគ «អាន់

ណា អល់ឡោះហ៊ូ អាក់ឡាំ»ដែលមានន័យថា «ព្រះដ៏ដឹងជ្រាប» ឯព្យញ្ជនៈ នូន អាចមកពីពាក្យថា «នូរ» ដែលមានន័យថា «ពន្លឺ» ជាដើម។

២.ព្យញ្ជនៈទាំងនេះពុំមែនជាព្យញ្ជនៈសង្ខេបទេក៏ប៉ុន្តែជានិមិត្តសញ្ញាឬជាព្រះនាមនៃព្រះអល់ឡោះ ឬអាចជាអ្វីផ្សេងទៀត។

៣.ព្យញ្ជនៈទាំងនេះត្រូវបានប្រទានចុះមកដើម្បីចាប់ចំណាប់ចួន។

៤.ព្យញ្ជនៈទាំងនេះក៏អាចមានអត្ថន័យជាតម្លៃលេខ ដ្បិតក្នុងអម្បូរភាសាសេមីទិច[4] ព្យញ្ជនៈអាចមានតម្លៃជាលេខ(តំណាងឱ្យលេខ) ផងដែរ។

៥.ព្យញ្ជនៈទាំងនេះត្រូវបានប្រើដើម្បីទាញចំណាប់អារម្មណ៍ព្យាការី ក៏ដូចជាអ្នកស្តាប់ដទៃទៀតផងដែរ។

មានសៀវភៅច្រើនណាស់បានសរសេរស្រាវជ្រាវអំពីអត្ថន័យនៃព្យញ្ជនៈទាំងនេះ។

## គ.សេចក្តីពន្យល់ដ៏ល្អបំផុតអំពីព្យញ្ជនៈទាំងនេះ

មានសេចក្តីពន្យល់ច្រើនណាស់ដែលបានលើកឡើងដោយអស់លោកជាសាសនវិទូជាច្រើនរូប ក៏ប៉ុន្តែមានសេចក្តីពន្យល់មួយដែលរឹងមាំជាងគេ ហើយត្រូវបានគាំទ្រដោយសាសនវិទូផ្នែកពន្យល់ព្រះគម្ពីរគួរអានគឺលោក អ៊ីបនូ ខាសៀរ៍, លោក ហ្សាម៉ាខ ស្ហារី និង លោក អ៊ីបនូ តៃមីយ៉ះ ដែលលើកឡើងដូចតទៅ៖

រាងកាយមនុស្សគឺផ្សំផ្គុំឡើងដោយធាតុជាច្រើន ដែលធាតុទាំងនោះក៏ត្រូវបានគេរកឃើញក្នុងធម្មជាតិផងដែរ។ ដីឥដ្ឋ និងធូលីដី ផ្សំឡើងពីធាតុតែមួយដូចគ្នាគឺធាតុដី។ ដូច្នេះគេក៏អាចនិយាយបានម្យ៉ាងថា មនុស្សនិងដីគឺដូចតែគ្នា។

យើងអាចទទួលបាន ឬប្រើប្រាស់សារធាតុទាំងអស់ដែលមានក្នុងខ្លួនមនុស្សយើង ហើយបើយើងចាក់ទឹកបន្ថែមប៉ុន្មានលីត្រចូលទៅ វាមិនមានអ្វីខុសឆ្គងនឹងសរីរាង្គមនុស្សឡើយ។ យើងបានដឹងអំពីធាតុទាំងអស់ដែលមានក្នុងខ្លួនយើង ប៉ុន្តែបើគេសួរយើងអំពីអាថ៌កំបាំងនៃជីវិតនោះយើងក៏មិនដឹងសោះឡើយ។

---

[4] អម្បូរភាសាសេមីទិចរួមមាន៖ ភាសាអារ៉ាប់ ភាសាហេប្រឺ ភាសាអារ៉ាម ជាដើម។

ស្រដៀងគ្នានេះដែរ ព្រះគម្ពីរគួរអានបានលើកឡើងអំពីពួកមនុស្សដែលប្រឆាំងនឹងអំណាចអភិបាលនៃព្រះជាម្ចាស់(ជាពិសេសសម្តៅដល់ជនជាតិអារ៉ាប់គូរេស្ហ)។ ព្រះគម្ពីរគួរអានប្រាប់ពួកគេនោះថា ព្រះគម្ពីរនេះ! ជាភាសានៃពួកគេ! ភាសាដែលពួកអារ៉ាប់មានមោទនភាព។ ព្រះគម្ពីរនេះ! ផ្សំផ្គុំពីព្យញ្ជនៈដែលពួកជនជាតិអារ៉ាប់តែងតែយកមកប្រើប្រាស់ដើម្បីសម្តែងអំពីខ្លួន ដោយសំនួនវោហាខ្ពង់ខ្ពស់សម្បើម។

ជនជាតិអារ៉ាប់មានមោទនភាពនឹងភាសារបស់ខ្លួនណាស់ ហើយអំឡុងពេលដែលព្រះគម្ពីរគួរអានកំពុងប្រទានចុះមក ភាសាអារ៉ាប់ក៏កំពុងមានកិត្យានុភាពដល់កំពូលផងដែរ។ ដោយប្រើព្យញ្ជនៈ អាលីហ្វ ឡាម មីម, យ៉ា ស៊ីន, ហា មីម ជាដើមដែលជាព្យញ្ជនៈធម្មតាៗ(ដូចខ្មែរយើងថា ក ខ គ ឃ ដូច្នេះ) ប៉ុន្តែព្រះជាម្ចាស់ល្បងភ្នាល់នឹងមនុស្សឱ្យតែងនិពន្ធយ៉ាងហោចណាស់ឱ្យបាន១ចំពូក ត្រឹមតែប្រហាក់ប្រហែលនឹងព្រះគម្ពីរគួរអានផ្នែកវិចិត្រ និងសោភ័ណ្ឌ ប្រសិនបើមនុស្សនោះមានមន្ទិលសង្ស័យថាមកពីព្រះមែនឬមិនមែន។

មិនតែប៉ុណ្ណោះព្រះគម្ពីរគួរអានល្បងភ្នាល់ឱ្យមនុស្ស និងអមនុស្សរួមគ្នាតែងនិពន្ធគម្ពីរមួយដែលដូចនឹងព្រះគម្ពីរគួអាន ព្រមទាំងថាបើទោះជាមនុស្សនិងអមនុស្សខំជួយគ្នាយ៉ាងណាក៏ពួកគេមិនអាចធ្វើបាននោះដែរ។ ការល្បងភ្នាល់នេះ ត្រូវបានលើកឡើងក្នុងចំពូក ១៧ វាក្យខណ្ឌ ៨៨ និងនៅក្នុងចំពូក ៥២ វាក្យខណ្ឌ ៣៤។

ក្រោយមកឃើញថាការល្បងភ្នាល់នេះបានលើកឡើងម្តងទៀតនៅក្នុងចំពូក ១១ វាក្យខណ្ឌ ១៣ ដោយឱ្យតែងនិពន្ធត្រឹម ១០ ចំពូកឱ្យដូចព្រះគម្ពីរ ហើយក្រោយមកទៀតក្នុងចំពូក ១០ វាក្យខណ្ឌ ៣៨ គឺឱ្យត្រឹមតែតែងនិពន្ធ ១ ចំពូកប៉ុណ្ណោះ ហើយចុងក្រោយគឺការល្បងភ្នាល់ដែលងាយជាងគេដែលមានចែងក្នុងចំពូក ២ វាក្យខណ្ឌ ២៣ និង ២៤។

*«ប្រសិនបើឯងរាល់គ្នាមានមន្ទិលសង្ស័យចំពោះអ្វី (ព្រះគម្ពីរអាល់គួរអាន) ដែលយើងបានប្រទានចុះមកដល់អ្នកបម្រើយើង(ព្យាការីមូហាំម៉ាត់)នោះ ចូរឯង(និពន្ធហើយ) យកចំពូកណាមួយ (ដែលនិពន្ធនោះ) មកប្រដូចនឹងព្រះគម្ពីរនេះ ហើយចូរឯងហៅសាក្សីរបស់ពួកឯងក្រៅពីព្រះអល់ឡោះមកចុះ បើសិនជាការអះអាងរបស់ឯងត្រឹមត្រូវមែននោះ។ ប្រសិនបើពួកឯងមិនអាចធ្វើបានទេនោះ អំណឹះតទៅមុខក៏ពួកឯងមិនអាចធ្វើបានដែរ។ ដូច្នេះហើយ ចូរឯងរាល់គ្នាខ្លាចរអែងចំពោះស្ថាននរក ដែលឥន្ធនៈបញ្ឆេះនរកនោះគឺជាមនុស្ស និងដុំថ្ម ដែលគេរៀបចំសម្រាប់ពួកគ្មានជំនឿ។»* (ព្រះគម្ពីរគួរអាន ២:២៣-២៤)

ដើម្បីប្រៀបធៀបទឹកដៃរបស់និងទេពកោសល្យរបស់ជាងស្នូន២នាក់ ជាងទាំង២នាក់នោះចាំបាច់ត្រូវទទួលបានវត្ថុធាតុដើមដូចគ្នា ទៅស្នូនវត្ថុដូចគ្នា ហើយទទួលបានការវាយតម្លៃដូចគ្នា។ បើជាជាងកាត់ដេរ ពួកគេត្រូវទទួលកំណាត់ដែលដូចគ្នា។ វត្ថុធាតុដើមនៃភាសាអារ៉ាប់នោះគឺព្យញ្ជនៈទាំងអស់នេះហើយ។ លក្ខណៈដ៏មហោស្ចារ្យនៃភាសាដែលប្រើក្នុងព្រះគម្ពីរគួរអាន មិនមែនត្រឹមតែដោយសារជាព្រះបន្ទូលនៃព្រះជាម្ចាស់មួយមុខនោះទេ ប៉ុន្តែលក្ខណៈមហោស្ចារ្យនេះក៏ដោយសារតែព្រះគម្ពីរតាក់តែងដោយប្រើព្យញ្ជនៈដូចគ្នានឹងព្យញ្ជនៈដែលពួកអារ៉ាប់គោរពព្រះខុសឆ្គងជំនាន់នោះដែលគេមានអំណួតថាជាជំនាញរបស់ពួកគេ ប៉ុន្តែពួកគេបែរជាមិនអាចឈ្នះការល្បងភ្នាល់បាន។

ជនជាតិអារ៉ាប់ត្រូវបានគេស្គាល់ថា ជាអ្នកដែលមានសមត្ថភាពប៉ិនប្រសព្វខាងវោហាសាស្ត្រ ថ្វីមាត់ និងពូកែអធិប្បាយប្រកបដោយអត្ថន័យជ្រាលជ្រៅ។ ការដែលមនុស្សយើងដឹងអំពីធាតុដែលមានក្នុងខ្លួន មិនខុសពីព្យញ្ជនៈដែលមានប្រើក្នុងព្រះគម្ពីរគួរអានដូចជា អាលីហ្វ ឡាម មីម ជាដើមគឺសុទ្ធតែយើងបានស្គាល់ហើយប្រើប្រាស់ជាប្រចាំដើម្បីបង្កើតជាពាក្យឡើង។ យើងពុំមានលទ្ធភាពអាចបង្កើតជីវិតបានទេ បើទោះជាយើងបានស្គាល់ និងដឹងអំពីធាតុបង្កុំ និងធម្មជាតិនៃសីរីរាង្គមនុស្សក៏ដោយ។ មិនខុសគ្នានោះទេ យើងគ្មានលទ្ធភាពក្នុងការតែងនិពន្ធឱ្យបានកម្រិតវោហាសាស្ត្រ និងសោភណ្ឌនៃការអធិប្បាយឱ្យបានមហោស្ចារ្យដូចព្រះគម្ពីរគួរអានឡើយ បើទោះជាយើងស្គាល់និងចេះប្រើព្យញ្ជនៈដែលមានប្រើក្នុងព្រះគម្ពីរគួរអានទាំងអស់ក៏ដោយចុះ។ ព្រះគម្ពីរគួរអាននេះជាសក្ខីភាពយ៉ាងប្រាកដអំពីប្រភពដើមថាមកអំពីព្រះពិតមែន។

## ឃ.លក្ខណៈដ៏មហោស្ចារ្យនៃព្រះគម្ពីរត្រូវបានលើកឡើងភ្លាមបន្ទាប់ពីព្យញ្ជនៈទោលទាំងនេះ

នៅក្នុងព្រះគម្ពីរគួរអានយើងឃើញថា បន្ទាប់ពីព្យញ្ជនៈសង្ខេបដែលលើកឡើងនៅវាក្យខណ្ឌដំបូងនៃចំពូក វាក្យខណ្ឌបន្ទាប់នោះគឺការបរិយាយអំពីលក្ខណៈមហោស្ចារ្យនៃព្រះគម្ពីរគួរអានតែម្តង៖

*«អាលីហ្វ ឡាម មីម។ នេះគឺជាព្រះគម្ពីរដែលឥតមានមន្ទិលសង្ស័យសោះឡើយ ព្រះគម្ពីរនេះជាការចង្អុលបង្ហាញដល់អស់អ្នកណាហើយ ដែលកោតខ្លាចព្រះអល់ឡោះ។»* (ព្រះគម្ពីរគួរអាន ២:១-២)

# ៨

# តើព្រះគម្ពីរគួរអានលើកឡើងថាផែនដីមានរាងរាបសំប៉ែតឬយ៉ាងណា?

**សំណួរ៖**

ព្រះគម្ពីរគួរអានបានលើកឡើងថា ព្រះអល់ឡោះបានបង្កើតពិភពលោកនេះជាកម្រាល។ នេះក៏សំដៅថាផែនដីនេះមានរាងរាបសំប៉ែត។ តើនេះមិនបញ្ច្រាសពីអ្វីដែលវិទ្យាសាស្ត្រទំនើបរកឃើញទេឬ?

**ចម្លើយ**

## ក.ផែនដីបង្កើតមកជាកម្រាល

សំណួរនេះគឺសំដៅដល់វាក្យខណ្ឌមួយក្នុងចំពូក ៧១ នៃព្រះគម្ពីរគួរអានដែលចែងថា៖

*«ហើយព្រះអល់ឡោះទ្រង់បានបង្កើតផែនដីជាកម្រាលសម្រាប់ឯងរាល់គ្នា។»* (ព្រះគម្ពីរគួរអាន ៧១:១៩)

ប៉ុន្តែប្រយោគក្នុងវាក្យខណ្ឌខាងលើនេះមិនចប់ត្រឹមហ្នឹងទេ ហើយវាក្យខណ្ឌបន្ទាប់ពីនេះនឹងពន្យល់សេចក្ដីបន្ថែមទៀត ៖

*«ដើម្បីឱ្យឯងរាល់គ្នាអាចធ្វើដំណើរលើ(ផែនដីនេះ) តាមផ្លូវដ៏ទូលាយជាច្រើន។»* (ព្រះគម្ពីរគួរអាន ៧១:២០)

ខ្លឹមសារស្រដៀងគ្នានេះដែរក៏មានចែងក្នុងចំពូក ២០ ផងដែរ៖

*«ព្រះអង្គជាព្រះជាម្ចាស់ដែលបង្កើតផែនដី(រាបស្មើ)ដូចជាកម្រាលសម្រាប់ឯងរាល់គ្នា ហើយព្រះអង្គបានក្រាយនៅលើដីឱ្យឯងរាល់គ្នាមានផ្លូវជាច្រើន..»* (ព្រះគម្ពីរគួរអាន ២០:៥៣)

ផ្ទៃនៃផែនដី ឬហៅថា សំបកផែនដី មានកម្រាស់មិនដល់៣០គីឡូម៉ែត្រនោះទេ ដែលស្តើងណាស់បើធៀបនឹងចម្ងាយកាំរបស់ផែនដីដែលមានរហូតទៅដល់ជាង៦៥០០ គីឡូម៉ែត្រ។ ស្រទាប់ជ្រៅនៃផែនដីគឺមានកម្តៅក្តៅខ្លាំង មានធាតុរាវ និងមិនអាចឱ្យមានជីវិតអ្វីរស់នៅបានឡើយ។ សំបកផែនដីមានសភាពជាសំបករឹងដែលអាចឱ្យយើងរស់នៅបាន។ ព្រះគម្ពីរគួរអានបានពិពណ៌នាប្រៀបនឹងកម្រាលដែលក្រាលសន្ធឹង ដើម្បីយើងអាចធ្វើដំណើរតាមផ្លូវច្រកនានាបាន។

## ខ.កម្រាលអាចក្រាលលើផ្ទៃដទៃដែលមិនរាបស្មើក៏បាន

គ្មានវាក្យខណ្ឌណាមួយនៃព្រះគម្ពីរគួរអានដែលនិយាយថាផែនដីមានរាងរាបសំប៉ែតនោះទេ។ ព្រះគម្ពីរគ្រាន់តែប្រៀបធៀបសំបកផែនដីទៅនឹងកម្រាល។ មនុស្សខ្លះទំនងជាគិតថាកម្រាលអាចក្រាលបានតែនៅលើផ្ទៃរាបស្មើប៉ុណ្ណោះ តាមពិតគេក៏អាចក្រាលកម្រាលនៅលើដុំបាល់មូលធំមួយ ដូចជាផែនដីនេះជាដើម។ ហើយយើងក៏អាចសាកល្បងដោយខ្លួនឯងបានដោយគ្រាន់តែយកកម្រាលមួយទៅក្រាលលើភូគោលធំមួយនោះនឹងឃើញថាអាចទៅរួច។

ជាទូទៅគេក្រាលកម្រាលនៅលើផ្ទៃណាមួយដែលពិបាកនឹងដើរលើ។ ព្រះគម្ពីរគួរអានពិពណ៌នាអំពីសំបកផែនដីថាជាកម្រាល បើគ្មានកម្រាលនេះទេនោះ មនុស្សលោកប្រាកដមិនអាចរស់បានទេ ដ្បិតកម្តៅឯស្រទាប់ខាងក្រោមក៏ក្តៅខ្លាំង ហើយជាធាតុរាវព្រមទាំងមិនអាចទ្រទ្រង់ជីវិតបានទៀត។ អ្វីដែលព្រះគម្ពីរគួរអានមិនត្រឹមតែលើកឡើងដោយសមហេតុសមផលនោះទេ ប៉ុន្តែថែមទាំងលើកឡើងអំពីការពិតមួយដែលវិទ្យាសាស្ត្រទំនើបទើបតែរកឃើញក្នុងរយៈកាលក្រោយមកផងដែរ។

## គ.ផែនដីត្រូវបានលាតសន្ធឹង

មិនខុសគ្នាឡើយ ព្រះគម្ពីរគួរអានក៏បានលើកឡើងក្នុងវាក្យខណ្ឌជាច្រើនថា ផែនដីត្រូវបានលាតសន្ធឹង៖

*«ហើយផែនដីត្រូវបានយើងលាតសន្ធឹង ហើយយើងពិតជាអ្នកលាតសន្ធឹងយ៉ាងល្អប្រណិត»* (ព្រះគម្ពីរគួរអាន ៥១:៤៨)

ព្រះគម្ពីរគួរអានក៏បានលើកឡើងវាក្យខណ្ឌថា ផែនដីត្រូវបានពង្រាបស្មើ៖

*«តើយើងមិនបានបង្កើតជាកន្លែងផ្តេកខ្លួន(រាបស្មើ) ហើយមានភ្នំជាស្នឹងទេឬ?»* (ព្រះគម្ពីរគួរអាន ៧៨:៦-៧)

វាក្យខណ្ឌទាំងនេះពុំមានព័ត៌មានណាមួយដែលនាំឱ្យយល់ថាផែនដីមានរាងរាបសំប៉ែតនោះដែរ។ វាគ្រាន់តែសំដៅថាផែនដីមានភាពទូលាយល្វឹងល្វើយ ហើយភាពទូលាយល្វឹងល្វើយនេះទៀតសោតក៏ត្រូវបានព្រះគម្ពីរគួរអានលើកឡើងមកផងដែរដោយចែងថា៖

*«ម្នាលអស់អ្នកបម្រើដែលមានជំនឿ! ប្រាកដណាស់ ផែនដីរបស់យើងពិតជាទូលាយល្វឹងល្វើយ ចូរឯងរាល់គ្នាគោរពសក្ការៈមកចំពោះយើង។»* (ព្រះគម្ពីរគួរអាន ២៩:៥៦)

ដូច្នេះគ្មានអ្នកនរណាម្នាក់ថាប្រើលេសថា ថាខ្លួនមិនអាចធ្វើអំពើល្អបាន ឬខ្លួនត្រូវបង្ខំចិត្តធ្វើអំពើអាក្រក់ដោយប្រការណាមួយ ព្រោះដោយសារស្ថានភាព ឬបរិយាកាសជុំវិញខ្លួនគេនោះឡើយ ដ្បិតផែនដីនេះទូលាយណាស់ គេអាចផ្លាស់ទីបានបើគេចង់។

## ឃ.ផែនដីមានរាងអេលីបសូអ៊ីត ឬស្ទើរមូល

ព្រះគម្ពីរគួរអានបានលើកឡើងពីរាងពិតប្រាកដរបស់ផែនដី ដូចមានចែងថា៖

*«ហើយយើងបានបង្កើតផែនដីមានរាងជាស៊ុត(ឬរាបស្មើ)។»* (ព្រះគម្ពីរគួរអាន ៧៩:៣០)

ពាក្យភាសាអារ៉ាប់ថា «دَحَاٰهَا» (ដាហាហា) មានន័យពីរយ៉ាង មួយគឺ «រាងជាស៊ុត» មួយទៀតគឺ«រាបស្មើ» ។ ពាក្យ «دَحَاٰهَا» (ដាហាហា) ក្លាយមកពីពាក្យ «دحية» (ឌូហ៊ីយ៉ា) ដែលសំដៅជាពិសេសទៅលើស៊ុតសត្វអូទ្រីសដែលមានរាងស្ទើរមូល ដូចនឹងរាងផែនដីដែរ។

ដូច្នេះក៏មានន័យថា ព្រះគម្ពីរគួរអាន និងអ្វីដែលវិទ្យាសាស្ត្រទំនើបបានរកឃើញគឺមានភាពស្របគ្នា។

# ៤

# តើមានតែព្រះអល់ឡោះទេមែនទេដែលអាចដឹងពីភេទរបស់ទារកក្នុងផ្ទៃម្ដាយបាន?

**សំណួរ៖**

ព្រះគម្ពីរគួរអានបានលើកឡើងថា មានតែព្រះអល់ឡោះតែមួយអង្គគត់ដែលអាចដឹងជ្រាបអំពីភេទនៃទារកក្នុងផ្ទៃម្ដាយ ក៏ប៉ុន្តែបច្ចុប្បន្ននេះវិទ្យាសាស្ត្រមានការរីកចម្រើនដែលធ្វើឱ្យគេដឹងបានយ៉ាងងាយអំពីភេទរបស់ទារកក្នុងផ្ទៃដោយប្រើឧបករណ៍អេកូសាស្ត្រ។ តើនេះមានន័យថាព្រះគម្ពីរគួរអានលើកឡើងខុសពីវេជ្ជសាស្ត្រទេឬ?

**ចម្លើយ៖**

ព្រះអល់ឡោះជាព្រះដ៏ពេញព្រះចេស្ដា ដ៏សព្វញ្ញុភាព[5]។ ព្រះអល់ឡោះព្រះអង្គជ្រាបដឹងសព្វគ្រប់ទាំងអស់អំពីមនុស្សលោកនេះ ហើយមិនតែប៉ុណ្ណោះព្រះអង្គជ្រាបដឹងអំពីរឿងអាថ៌កំបាំងទៀតផង។

## ក.ព្រះអល់ឡោះទ្រង់ជ្រាបដឹងរាល់សព្វអ្វីទាំងអស់

មនុស្សជាច្រើនជឿថាក្នុងព្រះគម្ពីរគួរអានមានចែងថា មានតែព្រះអល់ឡោះតែមួយអង្គគត់ដែលអាចដឹងជ្រាបពីភេទរបស់ទារកក្នុងផ្ទៃម្ដាយបាន។ ព្រះគម្ពីរគួរអានចែងថា៖

*«ជាការប្រាកដណាស់ ការដឹងជ្រាបអំពីអវសានកាលគឺនៅឯព្រះអល់ឡោះ ហើយព្រះអង្គគឺជាអង្គដែលបង្អុរទឹកភ្លៀង។ ហើយព្រះអង្គជ្រាបដឹងអំពីអ្វីដែលមាននៅក្នុងស្បូន (គភ៌)...។»* (ព្រះគម្ពីរគួរអាន ៣១:៣៤)

សេចក្ដីស្រដៀងគ្នានេះក៏មានចែងផងដែរក្នុងចំពូក ១៣៖

[5] ការដឹងជ្រាបនូវរាល់សព្វអ្វីៗទាំងអស់។

*«ព្រះអល់ឡោះទ្រង់ដឹងជ្រាបនូវអ្វីដែលអស់ទាំងស្ត្រីពរផ្ទៃ ព្រមទាំងការរួមឬរីកនៃស្បូនផង។ ហើយរាល់សព្វសារពើទាំងអស់ ក្រិតដោយខ្នាតរបស់វានៅឯព្រះអង្គ។»* (ព្រះគម្ពីរគួរអាន ១៣:៨)

## ខ.ឧបករណ៍អេកូសាស្រ្តអាចកំណត់ដឹងអំពីភេទបាន

វិទ្យាសាស្រ្តបច្ចុប្បន្ននេះមានការរីកចម្រើនខ្លាំងណាស់ យើងអាចដឹងបានយ៉ាងងាយអំពីភេទរបស់ទារកក្នុងផ្ទៃម្តាយដោយប្រើឧបករណ៍អេកូសាស្រ្ត។

## គ.ពាក្យ«ភេទ»ឥតមានលើកឡើងក្នុងវាក្យខណ្ឌដែលពាក់ព័ន្ធឡើយ

ជាការពិតណាស់ មានការបកប្រែក្នុងភាសាខ្លះ និងសេចក្តីអធិប្បាយមួយចំនួន នៃព្រះគម្ពីរគួរអានបានលើកឡើងថា មានតែព្រះអល់ឡោះប៉ុណ្ណោះដែលអាចដឹងជ្រាបអំពីភេទរបស់ទារកក្នុងផ្ទៃម្តាយបាន។ បើលោកអ្នកអានវាក្យខណ្ឌខាងលើជាអត្ថបទភាសាអារ៉ាប់ នោះនឹងឃើញថាគ្មានពាក្យភាសាអារ៉ាប់ណាមួយក្នុងវាក្យខណ្ឌមានន័យសំដៅដល់ពាក្យ«ភេទ»ឡើយ។ ជាការពិត ព្រះគម្ពីរពិតជាបានលើកឡើងថា ការជ្រាបដឹងអំពីអ្វីដែលមាននៅក្នុងស្បូនគឺនៅឯព្រះអល់ឡោះតែមួយអង្គគត់។ មានអ្នកធ្វើសេចក្តីអធិប្បាយមួយចំនួនបានយល់ច្រឡំអត្ថន័យថា មានតែព្រះអល់ឡោះមួយអង្គគត់ដែលជ្រាបដឹងអំពីភេទរបស់ទារកក្នុងផ្ទៃទៅវិញ ដែលនេះគឺជាកំហុសមួយរបស់អ្នកអធិប្បាយ។

## ឃ.មានតែព្រះអល់ឡោះមួយអង្គគត់ដែលអាចកំណត់បានអំពីលក្ខណៈរបស់ទារកក្នុងផ្ទៃ

វាក្យខណ្ឌនេះមិនសំដៅទៅលើបញ្ហាភេទរបស់ទារកឡើយ ក៏ប៉ុន្តែសំដៅលើបុគ្គលិកលក្ខណៈរបស់ទារកនោះថានឹងទៅជាយ៉ាងណានៅពេលអនាគត។ តើចរិតទារកនោះនឹងយ៉ាងណា? ហើយតើគេជាព្រះពរ ឬ ជាបណ្តាសារដល់ឪពុកម្តាយគេ? តើគេនឹងចូលចំណោមគេឯងក្នុងសង្គមដែរឬទេ? តើគេសុចរិត ឬទុច្ចរិត? គេនឹងបានទៅស្ថានសួគ៌ ឬស្ថាននរក? ហើយការដឹងជ្រាបរាល់សព្វសារពើទាំងអស់គ្នាគឺនៅឯព្រះអល់ឡោះតែមួយអង្គគត់។ លើលោកនេះគ្មានអ្នកវិទ្យាសាស្រ្តណាអាចកំណត់ដឹងអំពីបញ្ហាទាំងអស់នេះឡើយចំពោះទារកដែលនៅក្នុងផ្ទៃម្តាយនៅឡើយ បើទោះជាមានឧបករណ៍ទំនើបយ៉ាងណាក៏ដោយចុះ។

# ១០

# ទេពអប្សរនៃស្ថានសួគ៌

## សំណួរ

បើយោងតាមព្រះគម្ពីរគួរអាន នៅពេលមនុស្សប្រុសចូលទៅស្ថានសួគ៌ គេនឹងទទួលបានទេពអប្សរជាភរិយា។ ចុះមនុស្សស្រីវិញ តើទទួលបានអ្វីដែរនៅពេលចូលស្ថានសួគ៌?

## ចម្លើយ

ពាក្យថា«حُورِيَّة»(អានថា៖ ហ៊ូរី) ត្រូវបានលើកឡើងក្នុងព្រះគម្ពីរគួរអានមិនតិចជាង៤ដងនោះទេ ដូចជា៖

១.«*យ៉ាងដូច្នេះហើយ យើងនឹងផ្សំផ្គុំគេជាមួយទេពអប្សរ ដែលមានភ្នែកស្អាតភ្លឺក្រឡង់។*»
(ព្រះគម្ពីរគួរអាន ៤៤:៥៤)

២.«*ហើយយើងនឹងផ្សំផ្គុំគេជាមួយទេពអប្សរ ដែលមានភ្នែកស្អាតភ្លឺក្រឡង់។*»
(ព្រះគម្ពីរគួរអាន ៥២:២០)

៣.«*ទេពអប្សរទាំងឡាយដែលត្រូវគេថែថួននៅក្នុងពន្លា។*»
(ព្រះគម្ពីរគួរអាន ៥៥:៧២)

៤.«*ហើយនឹងទេពអប្សរដែលមានភ្នែកស្អាតភ្លឺក្រឡង់ ប្រៀបបាននឹងត្បូងមុក្តាដែលគេរក្សាយ៉ាងល្អ។*» (ព្រះគម្ពីរគួរអាន ៥៦:២២-២៣)

### ខ.ពាក្យថា«ហ៊ូរី»ត្រូវបានបកប្រែថា«ស្រីទេពអប្សរ»

ក្នុងសេចក្តីបកប្រែព្រះគម្ពីរគួរអានជាច្រើនបានបកប្រែពាក្យ «ហ៊ូរី» ថា «ស្រីទេពអប្សរ ឬ ស្រីសួគ៌ា» ទាំងនៅក្នុងការបកប្រែជាភាសាខ្មែរ និងភាសាមួយចំនួនទៀតផង

ដែរ។ បើពាក្យ «ហ៊ូរី» មានន័យសំដៅដល់តែ «ស្រីទេពអប្សរ ឬ ស្រីសួគ៌ា» ដែលមានភេទជាស្រី នោះក៏មានន័យថា អ្នកទាំងនេះគឺសម្រាប់តែមនុស្សប្រុសប៉ុណ្ណោះ។ ចុះផ្ទុយទៅវិញ តើមនុស្សស្រីនឹងទទួលបានអ្វីនៅពេលគេចូលស្ថានសួគ៌?

## គ.អត្ថន័យនៃពាក្យថា«ហ៊ូរី»

ពាក្យភាសាអារ៉ាប់ថា «ហ៊ូរី» ជាពហុវចនៈនាមដែលបំបែកមកពីពាក្យថា «អះវ៉ា»[6] និងពាក្យថា «ហូរវ៉ា»[7] ដែលពាក្យទាំងនេះសំដៅដល់អ្នកដែលមានភ្នែកភ្លឺថ្លាធំក្រឡង់ ប្រកបដោយគុណជាតិពិសេសនៃព្រលឹងវិញ្ញាណដែលល្អសុចរិត អាចជាប្រុស ឬជាស្រីនៅឯស្ថានសួគ៌ ហើយក៏បង្ហាញពីភាពសល្អល្អះនៃប្រស្រីសក្នុងភ្នែកអ្នកនោះផង។

ព្រះគម្ពីរគួរអានក៏បានពិពណ៌នានៅក្នុងវាក្យខណ្ឌជាច្រើនថា នៅឯស្ថានសួគ៌មនុស្សយើងនឹងមានគូគ្រង(មនុស្សប្រុសនឹងមានភរិយា មនុស្សស្រីនឹងមានស្វាមី) ដែលគូគ្រងនោះមានលក្ខណៈល្អស្អាតវិសុទ្ធ។

*«ហើយចូរឯងផ្តល់ដំណឹងរីករាយ ដល់អស់អ្នកដែលបានជឿ និងបានប្រព្រឹត្តសុចរិតថា ពួកគេនឹងទទួលបានឧទ្យានស្ថានសួគ៌ ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមស្ថានសួគ៌នោះ យ៉ាងប្រាកដ។ នៅពេលពួកគេទទួលបានអាហារដែលជាផ្លែឈើក្នុងស្ថានសួគ៌នោះ ពួកគេតែងតែនិយាយថា៖ ផ្លែឈើនេះហើយដែលគេធ្លាប់ផ្តល់ឱ្យពួកយើងពីពេលមុន។ ហើយផ្លែឈើដែលផ្តល់ដល់ពួកគេនោះគឺប្រហាក់ប្រហែលគ្នា។ ហើយក្នុងស្ថានសួគ៌នោះពួកគេនឹងមានគូគ្រងដ៏ស្អាតវិសុទ្ធជាច្រើន។ ពួកគេនឹងរស់ក្នុងស្ថានសួគ៌ជាអស់កល្បជាដរាបរៀងទៅ។»* (ព្រះគម្ពីរគួរអាន ២:២៥)

*«រីឯអស់អ្នកដែលបានជឿ និងបានប្រព្រឹត្តសុចរិត យើងនឹងបញ្ចូលពួកគេចូលទៅក្នុងឧទ្យានស្ថានសួគ៌ ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមស្ថានសួគ៌នោះ ដោយពួកគេនឹងរស់នៅទីនោះអស់កល្បជាដរាបរៀងទៅ។ នៅក្នុង(ស្ថានសួគ៌)នោះ ពួកគេនឹងមានគូគ្រងដ៏ស្អាតវិសុទ្ធ។ ហើយយើងនឹងបញ្ចូលពួកគេទៅក្រោមម្លប់ដ៏ត្រឈឹងត្រឈៃ។»* (ព្រះគម្ពីរគួរអាន ៤:៥៧)

---

[6] នាមប្រើសម្រាប់ភេទប្រុស ឬ បុំលិង្គនាម។

[7] នាមប្រើសម្រាប់ភេទស្រី ឬ ឥត្ថិលិង្គនាម។

ពាក្យ «ហ៊ូរី» ពុំមានកំណត់ភេទនោះទេ អ្នកបកប្រែព្រះគម្ពីរជាភាសាអង់គ្លេសដូចជាលោក មូហាំម៉ាត់ អាសាដ ប្រែពាក្យនេះជាភាសាអង់គ្លេសថា «Spouse»[8] ឯលោកអាប់ឌុលឡោះ យូសុហ្វអាលី បានបកប្រែទៅជា «Companion»[9] ដែលសុទ្ធតែមិនកំណត់ភេទនោះទេ។ យ៉ាងណាមិញ បើយោងតាមសាសនវិទូមួយចំនួនបានបញ្ជាក់ថានៅស្ថានសួគ៌ បុរសនឹងទទួលបានស្ត្រីដែលមានភ្នែកភ្លឺថ្លាធំក្រឡង់ ឯស្ត្រីក៏នឹងទទួលបានបុរសដែលមានភ្នែកភ្លឺថ្លាធំក្រឡង់ដូចគ្នា។

## ឃ.មនុស្សស្រីនឹងទទួលបានអ្វីដែលជាទីគាប់ចិត្តនៅឯស្ថានសួគ៌

មានសាសនវិទូជាច្រើនបានលើកឡើងថា ក្នុងបរិបទនៃខ្លឹមសារនេះ ពាក្យ «ហ៊ូរី» អាចសំដៅតែទៅលើស្រីទេពអប្សរប៉ុណ្ណោះ ដ្បិតមានលើកយកពាក្យ «បុរស» មកប្រើឯខាងដើមទី។ ចម្លើយមួយដែលមនុស្សគ្រប់គ្នាអាចទទួលយកបាននោះ គឺមានចែងក្នុងមគ្គវចនៈ[10]មួយរបស់ព្យាការីមូហាំម៉ាត់ នៅគ្រាដែលមានអ្នកសួរសំណួរស្រដៀងនេះដែរទៅកាន់លោកថា៖ *នៅពេលមនុស្សប្រុសចូលទៅស្ថានសួគ៌ គេនឹងទទួលបានទេពអប្សរជាភរិយា។ ចុះមនុស្សស្រីវិញ តើនឹងទទួលបានអ្វីដែរនៅពេលចូលស្ថានសួគ៌?* ចម្លើយរបស់ព្យាការីនោះគឺ៖ *មនុស្សស្រីនឹងទទួលបានអ្វីដែលចិត្តគេមិនដែលប្រាថ្នាដល់ ត្រចៀកគេមិនដែលធ្លាប់ឮ ភ្នែកគេមិនដែលធ្លាប់ឃើញ។* ចម្លើយនេះមានន័យថាមនុស្សស្រីនឹងទទួលបានអ្វីដែលជាទីគាប់ចិត្តគេបំផុតនៅឯស្ថានសួគ៌។

---

[8] ពាក្យនេះត្រូវនឹងពាក្យភាសាខ្មែរថា«សហព័ទ្ធ»ដែលអាចសំដៅដល់ស្វាមីក៏បាន ភរិយាក៏បាន។

[9] ពាក្យនេះអាចបកប្រែថា«ដៃគូជីវិត»។

[10] «حديث»អានថា ហាឌីស ជាគម្ពីរកំណត់ត្រាប្រសាសន៍ និងសកម្មភាពរបស់ព្យាការីមូហាំម៉ាត់។

# ១១

# តើបេះដូងជាអ្នកទទួលមុខងារនៃការយល់ដឹងឬយ៉ាងណា?

## សំណួរ

ព្រះគម្ពីរគួរអានបានលើកឡើងថាព្រះអល់ឡោះបានបិទភ្ជិតបេះដូងរបស់អ្នកគ្មានជំនឿ ហើយពួកគេនឹងគ្មានថ្ងៃក្លាយជាអ្នកមានជំនឿឡើយ។ វិទ្យាសាស្ត្របច្ចុប្បន្នបានឱ្យយើងដឹងថា ខួរក្បាលឯណោះទេ ដែលជាអ្នកទទួលមុខងារខាងការយល់ដឹង និងជំនឿ មិនមែនបេះដូងនោះទេ។ តើនេះមិនមែនមានន័យថាព្រះគម្ពីរគួរអានមិនស្របគ្នានឹងវិទ្យាសាស្ត្រទេឬ?

## ចម្លើយ

### ក.ព្រះអល់ឡោះបានបិទភ្ជិតបេះដូងអ្នកគ្មានជំនឿ

ព្រះគម្ពីរគួរអានបានចែងថា៖

*«ប្រាកដណាស់ រីឯពួកអ្នកដែលមិនជឿវិញគឺ(គេ)នៅតែដដែលទេ ទោះបីជាឯងបានដាស់តឿនព្រមាន ឬមិនបានដាស់តឿនព្រមានពួកគេក៏ដោយ ក៏ពួកគេនៅតែមិនជឿដដែល។ ព្រះអល់ឡោះទ្រង់ធ្វើឱ្យពួកគេមានមោហ៍បាំងចិត្តគំនិត[11] និងសោតវិញ្ញាណ*

[11] នេះជាសេចក្តីបកប្រែស្រង់ចេញពីសៀវភៅ «អត្ថន័យនៃព្រះគម្ពីរអាល់គួរអានជាខេមរភាសា» ដែលបានសម្រួលខ្លឹមសារជាភាសាខ្មែរឱ្យត្រឹមត្រូវរួចជាស្រេច។ ត្រង់ឃ្លាថា «មោហ៍បាំងចិត្តគំនិត» នេះហើយ ដែលភាសាអារ៉ាប់ប្រើបម្រៀបន័យថា៖ ព្រះអល់ឡោះបាន «បិទភ្ជិតបេះដូង» ឬ «បោះត្រាភ្ជិតបេះដូង»(خَتَمَ ٱللَّهُ عَلَىٰ قُلُوبِهِمْ)។ យ៉ាងណាមិញក្នុងសេចក្តីបកប្រែជាភាសាខ្មែរដទៃទៀតក៏បានប្រែសម្រួលពាក្យ «បេះដូង» មកជា «ចិត្ត» វិញរួចជាស្រេច។ ដូច្នេះបញ្ហានៃចំណោទខាងលើអាចមានក្នុងការបកប្រែជាភាសាដទៃក៏ប៉ុន្តែពុំមាននៅក្នុងភាសាខ្មែរនោះឡើយ។

*របស់ពួកគេ រីឯចក្ខុវិញ្ញាណពួកគេក៏មានរបាំងគ្របលើផងដែរ ហើយពួកគេនឹងទទួលការធ្វើទោសយ៉ាងក្រៃលែងបំផុត។* »(ព្រះគម្ពីរគួរអាន ២:៦-៧)

## ខ.ពាក្យ«ختم»ក្នុងភាសាអារ៉ាប់មានន័យថាបេះដូងផង និងចិត្តគំនិតផង

ក្នុងភាសាអារ៉ាប់ ពាក្យ«ختم»(អានថា កល់ប៍)ដែលប្រើក្នុងវាក្យខណ្ឌខាងលើនេះ សំដៅដល់បេះដូងផង និងចិត្តគំនិតផង។ វាក្យខណ្ឌខាងលើមានន័យថា ព្រះអល់ឡោះបានបិទភ្ជិត ឬឱ្យមានមោហ៍បាំងលើចិត្តគំនិតរបស់អ្នកប្រឆាំង បណ្ដាលឱ្យគេមិនអាចយល់បាន និងមិនអាចក្លាយជាអ្នកមានជំនឿ។

## គ.ក្នុងភាសាអារ៉ាប់ បេះដូងគឺជាស្នូលនៃការយល់ដឹងនានា

ក្នុងភាសាអារ៉ាប់ ពាក្យ«បេះដូង»គឺគេប្រើសំដៅដល់ស្នូលនៃការគិតពិចារណា និងការយល់ដឹងជាដើម។

## ឃ.ពាក្យក្នុងភាសាអង់គ្លេសជាច្រើនដែលប្រើជាបម្រៀបន័យខុសពីន័យត្រង់របស់ពាក្យ

សូម្បីតែនៅក្នុងភាសាអង់គ្លេសក៏ដោយ មានពាក្យជាច្រើនដែលគេយកមកប្រើប្រាស់ដើម្បីអធិប្បាយអំពីអ្វីមួយ ទាំងពាក្យដើមនោះមានន័យត្រង់ជារឿងផ្សេងវិញ។ យើងសាកគិតពិចារណាអំពីពាក្យភាសាអង់គ្លេសខាងក្រោម៖

### ១.ពាក្យ Lunatic ដែលមានន័យត្រង់ថា ព្រះចន្ទសន្ទប់

ពាក្យ Lunatic មានន័យត្រង់ថា ព្រះចន្ទសន្ទប់។ បច្ចុប្បន្ននេះមនុស្សម្នាប្រើពាក្យនេះសំដៅដល់ អ្នកដែលវិកលចរិត ឬមានស្មារតីមិននឹងនរ។ មនុស្សគ្រប់គ្នាដឹងច្បាស់ណាស់ថា មនុស្សឆ្កួត ឬមានស្មារតីមិននឹងនរ មិនមែនដោយសារព្រះចន្ទសន្ទប់នោះទេ ក៏ប៉ុន្តែឥឡូវនេះសូម្បីតែវេជ្ជបណ្ឌិតក៏បានប្រើពាក្យនេះ ហើយវាវិវត្តន៍មកជាពាក្យសាមញ្ញប្រើប្រចាំថ្ងៃទៅហើយ។

### ២..ពាក្យ Disaster ដែលមានន័យត្រង់ថា ផ្កាយគ្រោះ

ពាក្យ Disaster មានន័យត្រង់ថា ផ្កាយគ្រោះ។ សព្វថ្ងៃពាក្យនេះគេប្រើសំដៅដល់ហេតុការណ៍អាសន្ន ឬមហន្តរាយខូចខាតផ្សេងៗ។ យើងគ្រប់គ្នាដឹងច្បាស់ណាស់ថា

ហេតុការណ៍អាសន្ន ឬមហន្តរាយខូចខាតផ្សេងៗ គ្មានទាក់ទងអ្វីនឹងផ្កាយគ្រោះសោះឡើយ។

**៣.ពាក្យថា«ព្រះអាទិត្យរះ» និង «ព្រះអាទិត្យលិច»**

ពាក្យ«ព្រះអាទិត្យរះ»មានន័យថាដំណើររះឡើងរបស់ព្រះអាទិត្យ។ យើងទាំងអស់គ្នាដែលនិយាយពាក្យនេះសុទ្ធតែបានដឹងថា ផែនដីជាអ្នកវិលជុំវិញព្រះអាទិត្យ ហើយព្រះនៅនឹងដដែលពុំមាន «រះឡើង» ឬ «លិចចុះ» នោះទេ។ ទោះជាដឹងយ៉ាងនេះហើយក្ដី មិនថាមនុស្សធម្មតា ឬអវកាសយានិកសុទ្ធតែនិយាយពាក្យនេះ បើទោះជាន័យត្រង់របស់វាមិនត្រឹមត្រូវក៏ដោយ។

**៤.ពាក្យ«មុខមាត់»ក្នុងភាសាខ្មែរ**

ក្នុងភាសាខ្មែរ ពាក្យ«មុខមាត់»មានន័យត្រង់សំដៅដល់សរីរាង្គ២ដែលនៅជាប់នឹងក្បាល។ ក៏ប៉ុន្តែក្នុងសង្គមខ្មែរបានប្រើពាក្យ«មុខមាត់»សំដៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះវិញ។ បើទោះជាយើងដឹងច្បាស់ថា កិត្តិយស និងកេរ្តិ៍ឈ្មោះពុំមានទាក់ទងនឹងរូបសម្បត្តិខាងក្រៅ ជាពិសេសគឺមុខ និងមាត់ តែក៏យើងនៅបន្តប្រើពាក្យនេះរហូតមក។

## ង.នៅក្នុងភាសាខ្មែរ ពាក្យ«បេះដូង»គឺជាស្នូលនៃក្ដីស្រឡាញ់ និងមនោសញ្ចេតនា

ក្នុងភាសាខ្មែរ ពាក្យ«បេះដូង»សំដៅលើសរីរាង្គខាងក្នុងមួយដែលមានតួនាទីជាអ្នកច្របាច់ឈាមឱ្យហូរទៅផ្នែកផ្សេងៗនៃសារពាង្គកាយ។ ពាក្យបេះដូងដដែលនេះក៏ត្រូវបានគេប្រើក្នុងន័យក្ដីស្រឡាញ់ និងមនោសញ្ចេតនាផងដែរ។ យោងតាមវិទ្យាសាស្ត្រយើងដឹងថា សូម្បីតែក្ដីស្រឡាញ់ និងមនោសញ្ចេតនាក៏កើតមានក្នុងខួរក្បាលដែរ។ ប៉ុន្តែនៅពេលគេចង់សម្តែងសេចក្ដីស្នេហានៅកាន់នរណាម្នាក់ គេក៏តែងនិយាយថា *«បងស្រឡាញ់អូនអស់ពីបេះដូងបង»*(ខ្លះមានថែមទាំងថ្លើមប្រម៉ាត់ទៅទៀត)។ សាកគិតលេងៗទៅមើល បើមានប្តីប្រពន្ធជាពេទ្យមួយគូ ហើយប្តីនិយាយទៅកាន់ប្រពន្ធថា *«បងស្រឡាញ់អូនអស់ពីបេះដូង»* ហើយប្រពន្ធក៏តបថា *«បងរៀនពេទ្យទាំងមូល បែរជាមិនដឹងថារឿងស្រឡាញ់និងមនោសញ្ចេតនា វាកើតមាននៅឯខួរក្បាលជាអ្នកបញ្ជាទេតើ មិនមែនបេះដូងទេ! បើឱ្យត្រឹមត្រូវនោះបងគួរតែនិយាយថា បងស្រឡាញ់អូនអស់ពីខួរក្បាលវិញទើបត្រូវ!»*។

### ច.អ្នកនិយាយភាសាអារ៉ាប់យល់ពាក្យនេះច្បាស់

គ្មានជនជាតិអារ៉ាប់ណាមកសួរសំណួរថា ម្តេចបានជាព្រះអល់ឡោះបិទភ្ជិតបេះដូង អ្នកមិនជឿនោះឡើយ ដ្បិតគេគេយល់ច្បាស់ណាស់អំពីសំនួននៃពាក្យបេះដូងនេះដោយ យោងទៅលើបរិបទនៃអត្ថបទ គឺច្បាស់ជាសំដៅដល់ការគិតពិចារណា ការយល់ដឹង និង មនោសញ្ចេតនាមិនខាន។

# ១២

# តើហេតុអ្វីទើយបានជាអ្នកមូស្លីមបែកជានិកាយផ្សេងគ្នា?

**សំណួរ**

បើអ្នកមូស្លីមបដិបត្តិតាមព្រះគម្ពីរគួរអានដូចគ្នា ចុះហេតុម្ដេចបានជាមាននិកាយជាច្រើន ហើយក្នុងនិកាយមានសាលាទិដ្ឋិ[12]ច្រើនទៀត?

**ចម្លើយ**

## ក.អ្នកមូស្លីមចាំបាច់ត្រូវរួបរួមគ្នា

ជាការពិតណាស់ អ្នកមូស្លីមសព្វថ្ងៃបានបែងចែកគ្នាជាក្រុម និកាយផ្សេងៗគ្នា។ ការបែងចែកគ្នាដ៏អកុសលនេះ មិនត្រូវបានសាសនាអ៊ីស្លាមលើកទឹកចិត្តនោះទេ។ សាសនាអ៊ីស្លាមផ្ដោត និងជឿជាក់លើការរួបរួមគ្នារវាងអ្នកបដិបត្តិទាំងអស់។

ព្រះគម្ពីរគួរអានបានចែងថា៖

*«ហើយចូរឯងរាល់គ្នាប្រកាន់ខ្ជាប់នឹងមាគ៌ា នៃព្រះអល់ឡោះទាំងអស់គ្នា ហើយមិនត្រូវបែកបាក់គ្នាឡើយ។»*(ព្រះគម្ពីរគួរអាន ២:៦-៧)

អ្នកមូស្លីមគ្រប់រូបត្រូវបដិបត្តិតាមព្រះគម្ពីរគួរអាន និងមគ្គវចនៈដ៏ត្រឹមត្រូវរបស់ព្យាការីមូហាំម៉ាត់ ហើយមិនត្រូវបែងចែកគ្នាជាដាច់ខាត។

## ខ.ការហាមប្រាមមិនឱ្យបង្កើតនិកាយ និងការបែងចែកក្នុងសាសនាអ៊ីស្លាម

[12]សាលាទិដ្ឋិ ឬសាលាច្បាប់ ជាពាក្យបកប្រែមកពីភាសាអារ៉ាប់ថា«مذهب» *Eng.* School of thought

ព្រះគម្ពីរគួរអានបានចែងថា៖

*«ជាការប្រាកដណាស់ នរណាហើយបំបែកបំបាក់សាសនា ហើយបែកចេញជានិកាយនោះ ឯង(ព្យាការីមូហាំម៉ាត់)មិនពាក់ព័ន្ធនឹងពួកគេបន្តិចសោះឡើយ។ ប្រាកដណាស់ កិច្ចការរបស់ពួកគេនឹងត្រូវថ្វាយដល់ព្រះអល់ឡោះ បន្ទាប់មកព្រះអង្គនឹងត្រាស់ប្រាប់ពួកគេនូវអ្វីដែលពួកគេបានប្រព្រឹត្ត។»* (ព្រះគម្ពីរគួរអាន ៦:១៥៩)

ក្នុងវាក្យខណ្ឌនេះ ព្រះអល់ឡោះទ្រង់មានបន្ទូលថា យើងត្រូវនៅឱ្យឆ្ងាយ ឬកុំពាក់ព័ន្ធនឹងនរណាដែលនាំឱ្យមានការបែកបាក់ក្នុងសាសនា នឹងកើតជានិកាយនានានោះ។

ប៉ុន្តែនៅពេលមានគេសួរថា៖«តើអ្នកកាន់តាមអ្វី?» មនុស្សជាច្រើននាំគ្នាឆ្លើយថា៖«ខ្ញុំជាអ្នកកាន់តាមស៊ុណ្ណះ» ឬ «ខ្ញុំជាអ្នកកាន់តាមស៊ីអះ»។ អ្នកខ្លះថែមទាំងហៅខ្លួនឯងថាជា ហាណាហ្វី, សាហ្វីអ៊ី, ម៉ាលីគី ឬហាំបាលី[13] ទៅទៀត។

## គ.ព្យាការីរបស់យើងគឺជា«មូស្លីម»

គេអាចនឹងសួរអ្នកមូស្លីមថា៖ «តើព្យាការីជាទីស្រឡាញ់របស់យើងលោកកាន់តាមអ្វី? តើលោកជា ហាណាហ្វី, សាហ្វីអ៊ី, ម៉ាលីគី ឬហាំបាលី? ទេ! មិនដូច្នេះទេ! លោកគឺជាមូស្លីម មិនខុសពីព្យាការី និងអ្នកនាំសារមុនៗដែលព្រះអល់ឡោះចាត់បញ្ជូនមកមុនលោកនោះទេ។

ព្រះគម្ពីរគួរអាន ចំពូក ៣ វាក្យខណ្ឌ ៥២ ចែងថា លោក យេស៊ូ គឺជាមូស្លីម។

មិនតែប៉ុណ្ណោះ ព្រះគម្ពីរគួរអាន ចំពូក ៣ វាក្យខណ្ឌ ៦៧ ចែងថាលោក អប្រាហាំ មិនមែនជាបរិស័ទយូដា ឬជាបរិស័ទគ្រិស្តឡើយ លោកជាមូស្លីម។

## ឃ.ព្រះគម្ពីរគួរអានបង្គាប់ឱ្យយើងហៅខ្លួនឯងថាជាមូស្លីម

១.បើមានអ្នកសួរសំណួរថាតើអ្នកកាន់តាមអ្វី? គេត្រូវឆ្លើយវិញថា«ខ្ញុំជាមូស្លីម» មិនមែនឆ្លើយថា ជាហាណាហ្វី ឬសាហ្វីអ៊ីឡើយ។ ចំពូក ៤១ វាក្យខណ្ឌ ៣៣ ចែងថា៖

*«ហើយគ្មានអ្នកណាម្នាក់ដែលប្រសើរខាងពាក្យសម្តី ជាងអ្នកដែលបានអំពាវនាវ(មនុស្សលោកឱ្យ)ទៅរកព្រះអល់ឡោះ និងប្រព្រឹត្តសុចរិត ព្រមទាំងបាននិយាយថា៖ ពិត*

---

[13] ទាំង៤នេះជាឈ្មោះសាលាទិដ្ឋិធំៗក្នុងសាសនាអ៊ីស្លាម។

*ប្រាកដណាស់ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមអ្នកមូស្លីមទាំងឡាយ នោះឡើយ។»* (ព្រះគម្ពីរគួរអាន ៤១:៣៣)

ព្រះគម្ពីរគួរអានប្រាប់ឱ្យយើងនិយាយថា«ខ្ញុំស្ថិតក្នុងចំណោមអ្នកមូស្លីម» ឬន័យត្រង់ថា «ខ្ញុំគឺជាមូស្លីម» ដែលពាក្យ«មូស្លីម»នេះមានន័យថា«អ្នកថ្វាយខ្លួនចំពោះព្រះ»

២.ព្យាការីមូហាំម៉ាត់លោកធ្លាប់បានផ្ញើចុតហ្មាយថ្វាយដល់ព្រះរាជាដែលមិនមែនជាមូស្លីម ដើម្បីយាងស្តេចមកកាន់សាសនាអ៊ីស្លាម។ ក្នុងចុតហ្មាយនោះលោកបានលើកឡើងពីវាក្យខណ្ឌមួយក្នុងព្រះគម្ពីរគួរអានដែលចែងថា៖

*«...ចូរឯងរាល់គ្នានិយាយទៅកាន់ពួកគេថា៖ ចូរអ្នករាល់គ្នាធ្វើជាសាក្សីផងថា ប្រាកដណាស់ ពួកយើងគឺជាអ្នកថ្វាយខ្លួន(មូស្លីម)។»*(ព្រះគម្ពីរគួរអាន ៣:៦៤)

## ង.ត្រូវគោរពផ្តល់តម្លៃដល់សាសនាវិទូ

យើងត្រូវតែគោរពផ្តល់តម្លៃដល់អស់លោកជាសាសនវិទូនៃសាសនាអ៊ីស្លាម ជាពិសេសសាសនវិទូកំពូលទាំង៤រូប រួមមាន៖ លោក អាប៊ូហានីហ្វះ, លោក សាហ្វីអ៊ី, លោក ហាំបាល់ និងលោក ម៉ាលិក។ លោកទាំងអស់នេះជាកំពូលសាសនវិទូដ៏ប៉ិនប្រសព្វ សូមព្រះជាម្ចាស់ប្រោសប្រទានផលតបស្នងដល់កិច្ចខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវរបស់លោកទាំងអស់គ្នា។ បើមាននរណាម្នាក់យល់ស្របតាមគំនិតនិងទស្សនៈរបស់លោក អាប៊ូហានីហ្វះ ឬលោក សាហ្វីអ៊ី នោះ គ្មាននរណាអាចប្រឆាំងទាស់ឬហាមឃាត់គេនោះឡើយ។ ប៉ុន្តែបើមានអ្នកសួរថា«តើអ្នកជាអ្វី? ឬតើអ្នកកាន់តាមអ្វី?» នោះត្រូវឆ្លើយតែម្យ៉ាងគត់ថា«ខ្ញុំគឺជាមូស្លីម»។

## ច.មគ្គវចនៈរបស់ព្យាការីមូហាំម៉ាត់

មនុស្សខ្លះអាចនឹងមកជជែកតវ៉ា ដោយលើកយកប្រសាសន៍របស់ព្យាការីជាទីស្រឡាញ់របស់យើង ដកស្រង់ពីគម្ពីរ ស៊ុណ្ណាន អាប៊ូដាវូត វចនៈលេខ ៤៥៧៩។ ក្នុងមគ្គវចនៈនេះ គេបានកត់ត្រាថា ព្យាការីលោកបានមានប្រសាសន៍ថា៖*«ប្រជាជាតិរបស់ខ្ញុំនឹងត្រូវបែកចេញជា៧៣និកាយ។»*

មគ្គវចនៈនេះចែងអំពីការណ៍ដែលព្យាការីលោកបានព្យាករណ៍ទុកជាមុនអំពីការបែកនិកាយជា៧៣។ នេះមិនមែនមានន័យថាលោកជំរុញឱ្យអ្នកមូស្លីមបំបែកខ្លួនជា

និកាយផ្សេងៗនោះឡើយ។ ព្រះគម្ពីរគួរអានហាមប្រាមយើងមិនឱ្យបង្កើតនិកាយផ្សេងៗ។ នរណាហើយបដិបត្តិតាមសេចក្តីបង្រៀននៃព្រះគម្ពីរគួរអាន និងគម្ពីរមគ្គវចនៈដែលត្រឹមត្រូវ ហើយមិនបំបែកគ្នាជាក្រុម ជានិកាយនោះ ពួកគេពិតជាស្ថិតនៅលើមាគ៌ាក៏ត្រឹមត្រូវប្រាកដហើយ។

យោងតាមគម្ពីរ អាត់ ទៀរមីហ្ស៊ី វចនៈលេខ ១៧១ គេបានកត់ត្រាថាៈ ព្យាការីលោកមានប្រសាសន៍ថាៈ«ប្រជាជាតិរបស់ខ្ញុំនិងត្រូវបែកជា៧៣និកាយ ហើយនិកាយទាំងអស់នោះត្រូវធ្លាក់ទៅនរកអវចីទាំងអស់ វៀរលែងតែមួយក្រុមប៉ុណ្ណោះ។» សហការីរបស់លោកក៏បានសួរថាលោកថាៈ«តើក្រុមនោះជាក្រុមណាទៅ?» ពេលនោះលោកឆ្លើយថាៈ«គឺអ្នកដែលនៅរួមជាមួយខ្ញុំ និងសហការីរបស់ខ្ញុំ»។

ព្រះគម្ពីរគួរអានបានលើកឡើងនូវវាក្យខណ្ឌជាច្រើន ដែលចែងថា«ចូរស្តាប់បង្គាប់ព្រះអល់ឡោះ និងស្តាប់បង្គាប់អ្នកនាំសាររបស់ព្រះអង្គ»។ អ្នកមូស្លីមពិតប្រាកដត្រូវបដិបត្តិតាមព្រះគម្ពីរគួរអាន និងមគ្គវចនៈដែលត្រឹមត្រូវ ហើយគេអាចតាមទស្សនៈរបស់អស់លោកជាសាសនវិទូបានដរាបណាទស្សនៈនោះស្របនឹងព្រះគម្ពីរគួរអាន និងមគ្គវចនៈដែលត្រឹមត្រូវ។ បើទស្សនៈខ្លះមិនស្របនឹងព្រះបន្ទូលនៃព្រះអល់ឡោះ ឬប្រសាសន៍របស់ព្យាការីទេនោះ ទស្សនៈនោះគ្មានតម្លៃអ្វីទេបើទោះជាសាសនវិទូនោះរៀនសូត្របានច្រើនយ៉ាងណាក៏ដោយចុះ។

បើអ្នកមូស្លីមទាំងអស់គ្នាអាចមានលទ្ធភាពអានព្រះគម្ពីរគួរអាន ហើយសិក្សាស្វែងយល់ផងនោះ ព្រមទាំងប្រកាសផ្សាយអំពីមគ្គវចនៈរបស់ព្យាការីឱ្យបានទូលំទូលាយទៀតនោះប្រាកដជាអាចដោះស្រាយបញ្ហាខ្វែងយោបល់គ្នាបាន ព្រមទាំងអាចរួបរួមអ្នកមូស្លីមទាំងអស់ឱ្យក្លាយជាធ្លុងមួយយ៉ាងរឹងមាំផងដែរ។

# ១៣

# ព្រះអល់ឡោះបិទភ្ជិតចិត្តគំនិតអ្នកមិនជឿ

## សំណួរ

ប្រសិនបើព្រះអល់ឡោះទ្រង់ជាអ្នកបិទភ្ជិតចិត្តគំនិតអ្នកមិនជឿនោះ ហេតុអ្វីអ្នកនោះត្រូវទទួលទោសដោយសារការមិនជឿទៅវិញ?

## ចម្លើយ

### ក.ព្រះអល់ឡោះបិទភ្ជិតចិត្តគំនិតអ្នកដែលបន្តបដិសេធសេចក្តីពិត

ព្រះអល់ឡោះមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖

*«ប្រាកដណាស់ រីឯពួកអ្នកដែលមិនជឿវិញគឺ(គេ)នៅតែដដែលទេ ទោះបីជាឯងបានដាស់តឿនព្រមាន ឬមិនបានដាស់តឿនព្រមានពួកគេក៏ដោយ ក៏ពួកគេនៅតែមិនជឿដដែល។ ព្រះអល់ឡោះទ្រង់ធ្វើឱ្យពួកគេមានមោហ៍បាំងចិត្តគំនិត និងសោតវិញ្ញាណរបស់ពួកគេ រីឯចក្ខុវិញ្ញាណពួកគេក៏មានរបាំងគ្របលើផងដែរ ហើយពួកគេនឹងទទួលការធ្វើទោសយ៉ាងក្រៃលែងបំផុត។»*(ព្រះគម្ពីរគួរអាន ២:៦-៧)

វាក្យខណ្ឌនេះមិនសំដៅលើអ្នកទូទៅដែលមិនមានជំនឿលើព្រះនោះទេ។ ក្នុងភាសាអារ៉ាប់ប្រើឃ្លាថា«ٱلَّذِينَ كَفَرُواْ» ដែលមានន័យថា«អ្នកដែលនៅតែមិនជឿ»។ បើទោះជាមានអ្នកទៅដាស់តឿនព្រមានពួកគេនោះក៏ដោយ ក៏ពួកគេនៅតែគ្មានផ្លាស់ប្តូរអ្វីដែរ ហើយពួកគេនៅតែមិនជឿដដែល។ ព្រះអល់ឡោះទ្រង់ធ្វើឱ្យពួកគេមានមោហ៍បាំងចិត្តគំនិត និងសោតវិញ្ញាណរបស់ពួកគេ រីឯចក្ខុវិញ្ញាណពួកគេក៏មានរបាំងគ្របលើផងដែរ។ តែនេះមិនមែនមកពីព្រះអល់ឡោះបិទភ្ជិតចិត្តគំនិតពួកគេ ទើបពួកគេមិនអាចយល់ឬមិនអាចជឿបាននោះទេ ប៉ុន្តែផ្ទុយទៅវិញគឺដោយសារតែមនុស្សចំពូកនេះបានប្រឆាំងនឹងសេចក្តីពិតតាំងពីដើមទីមក បើទោះជាមានអ្នកដាស់តឿនព្រមានហើយក្តីក៏គេនៅតែមិនជឿដដែល នោះទើបព្រះអល់ឡោះបិទភ្ជិតចិត្តរបស់គេ។ យ៉ាងណាមិញគេមិនត្រូវបន្ទោស

ព្រះអល់ឡោះចំពោះការណ៍នេះឡើយ ដ្បិតមនុស្សណាបានបដិសេធជំនឿ អ្នកនោះត្រូវទទួលខុសត្រូវដោយខ្លួនឯង។

## ខ.ឧទាហរណ៍អំពីគ្រូម្នាក់

ឧបមាមានគ្រូបង្រៀនជើងចាស់ម្នាក់ មុនពេលប្រឡងបញ្ចប់គាត់បានព្យាករណ៍ទុកមុនថា សិស្សណាម្នាក់មុខជាត្រូវប្រឡងធ្លាក់មិនខាន នេះក៏ព្រោះតែសិស្សនោះមានអាកប្បកិរិយាមិនសមរម្យ មិនសូវមករៀនជាប់លាប់ ហើយមិនដែលធ្វើកិច្ចការផ្ទះផង។ ហើយបើក្រោយការប្រឡង សិស្សនោះធ្លាក់តាមការព្យាករណ៍ទុកមែន តើគេត្រូវបន្ទោសគ្រូ ឬបន្ទោសសិស្ស? ដ្បិតថាគ្រូបានព្យាករណ៍ទុកមុនមែន ប៉ុន្តែក៏មិនមែនមកពីគ្រូព្យាករណ៍ទើបសិស្សនោះប្រឡងធ្លាក់ឯណា! សិស្សនោះត្រូវទទួលខុសត្រូវចំពោះបរាជ័យនេះដោយខ្លួនឯង។

មិនខុសគ្នាប៉ុន្មានឡើយ ព្រះអល់ឡោះទ្រង់ជ្រាបដឹងជាមុនអំពីមនុស្សមួយចំនួនដែលនឹងបដិសេធជំនឿ ហើយព្រះអង្គបានបិទភ្ជិតចិត្តគំនិតគេ។ អ្នកមិនជឿទាំងនេះហើយដែលត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះអ្វីដែលខ្លួនបានប្រឆាំង។

# ១៨

# មេឃនិងដីត្រូវបានបង្កើតក្នុងរយៈកាល៦ថ្ងៃ មិនមែន៨ថ្ងៃទេ

## សំណួរ

ព្រះគម្ពីរគួរអានបានលើកឡើងជាច្រើនកន្លែងអំពីការណ៍ដែលមេឃនិងដីត្រូវបានបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ។ ប៉ុន្តនៅក្នុងចំពូក ៤១ ចែងថា មេឃនិងដីបង្កើតឡើងក្នុងរយៈកាល៨ថ្ងៃទៅវិញ តើនេះមិនបញ្ច្រាសគ្នាទេឬ? វាក្យខណ្ឌនោះចែងថា ផែនដីត្រូវបានបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ ហើយក្រោយមកមេឃត្រូវបានបង្កើតឡើង២ថ្ងៃទៀត។ សេចក្តីលើកឡើងនេះមិនស្របនឹងទ្រឹស្តីបន្ទុះមហិមា(The Big bang theory) ដែលថាមេឃនិងដីត្រូវបានបានបង្កើតឡើងដំណាលគ្នាឡើយ។

## ចម្លើយ

### ក.មេឃនិងដីត្រូវបានបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ

ខ្ញុំយល់ស្របដែលថាមេឃនិងដីត្រូវបានបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ ឬ៦សម័យដូចមានចែងក្នុងព្រះគម្ពីរគួរអានរួមមាន៖

ចំពូក ៧ វាក្យខណ្ឌ ៥៤

ចំពូក ១០ វាក្យខណ្ឌ ៣

ចំពូក ១១ វាក្យខណ្ឌ ៧

ចំពូក ២៥ វាក្យខណ្ឌ ៥៩

ចំពូក ៣២ វាក្យខណ្ឌ ៤

ចំពូក ៥០ វាក្យខណ្ឌ ៣៨

ចំពូក ៥៧ វាក្យខណ្ឌ ៤

វាក្យខណ្ឌដែលលើកឡើងក្នុងសំណួរខាងលើដែលថា មេឃនិងដីត្រូវបានបង្កើតឡើងក្នុងរយៈកាល៨ថ្ងៃនោះ គឺក្នុងចំពូក ៤១ វាក្យខណ្ឌ ៩ ដល់ ១២ ៖

*«ចូរឯងនិយាយថា៖ តើអ្នករាល់គ្នាពិតជាមិនជឿលើព្រះជាម្ចាស់ដែលបានបង្កើតផែនដីក្នុងរយៈពេលពីរថ្ងៃ ហើយរាល់គ្នាបែរជាបង្កើតព្រះនានាយកមកធ្វើគោរពសក្ការៈខុសឆ្គងរួមនឹងទ្រង់ឬយ៉ាងណា? ព្រះអង្គនោះហើយគឺព្រះជាម្ចាស់ អភិបាលសព្វស្ថានទាំងឡាយ។ ហើយនៅលើផែនដីព្រះអង្គបានបង្កើតភ្នំជាច្រើន និងបានប្រទានព្រះពរនៅលើនោះផង ព្រមទាំងបានកំណត់ចំណីអាហារ នៅលើដីនោះរយៈកាលបួនថ្ងៃ(នេះជាចម្លើយ)សម្រាប់អស់អ្នកដែលបានសួរ។ មិនតែប៉ុណ្ណោះព្រះអង្គឆ្ពោះទៅឯមេឃ ក្នុងគ្រាដែលមេឃនោះនៅជាផ្សែងនៅឡើយ។ ហើយព្រះអង្គបានមានបន្ទូលទៅកាន់មេឃនិងផែនដីថា« ចូរឯងទាំងពីរមក ទោះដោយស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តក៏ដោយ។» ពួកវាទាំងពីរបានតបថា៖«ពួកទូលបង្គំទាំងពីរបានមកទាំងស្ម័គ្រចិត្ត។» ព្រះអង្គបានបង្កើតមេឃទាំងប្រាំពីរជាន់រួចរាល់ក្នុងរយៈកាល ពីរថ្ងៃ។ ហើយព្រះអង្គបានរៀបចំឱ្យមេឃគ្រប់ទាំងជាន់នូវមុខការរបស់ខ្លួន។ ហើយយើងបានតុបតែងលម្អមេឃជាន់ក្រោមដោយហ្វូងតារា និងការការពារផង។ នោះគឺជាការកំណត់នៃព្រះជាម្ចាស់ដ៏ពេញព្រះចេស្ដា ដ៏ប្រាជ្ញាញាណ។»*
(ព្រះគម្ពីរគួរអាន ៤១:៩ដល់១២)

បើមើលមួយភ្លែតទៅ ហាក់បីដូចជាព្រះគម្ពីរគួរអានផ្ដល់ព័ត៌មានប្រាប់យើងថាមេឃនិងដីត្រូវបានបង្កើតឡើងក្នុងរយៈកាល៨ថ្ងៃ។

ព្រះអល់ឡោះមានព្រះបន្ទូលនៅក្បាលវាក្យខណ្ឌនេះថា ចំពោះអ្នកដែលមិនជឿលើសេចក្ដីទាំងអម្បាលម៉ានដែលមកនេះទេ ហើយកើតមន្ទិលសង្ស័យថាសេចក្ដីទាំងនេះពិតជាមកអំពីព្រះជាម្ចាស់មែនឬអត់ នោះគឺស្មើនឹងអ្នកនោះប្រកាសមើលងាយព្រះជាម្ចាស់ដូចគ្នា ហើយបដិសេធនឹងព្រះចេស្ដារបស់ព្រះអង្គ។ ព្រះអល់ឡោះក៏មានព្រះបន្ទូលប្រាប់យើងដែរថា នឹងមានពេលមួយ មានអ្នកមិនជឿព្រះលើករឿងរ៉ាវទាំងអស់មកនេះ ដើម្បីបង្ហាញពីភាពមិនស្របគ្នានៃព្រះគម្ពីរគួរអាន។

## ខ.ពាក្យ«ثُمَّ»មានន័យថា«លើសពីនេះទៅទៀត»

បើយើងវិភាគអំពីវាក្យខណ្ឌទាំងនេះឱ្យបានល្អិតល្អន់យើងនឹងឃើញថា វាក្យខណ្ឌនេះចែងអំពីការបង្កើត២ដោយឡែកពីគ្នាគឺមេឃ និងដី។ ផែនដី (មិនរាប់បញ្ចូលភ្នំផងទេ)

ត្រូវបានបង្កើតឡើងក្នុងរយៈកាល២ថ្ងៃ ហើយភ្នំត្រូវបានបង្កើតឡើងពីលើដីនោះ ហើយព្រះអង្គប្រទានព្រះពរ ក្នុងរយៈកាល៤ថ្ងៃ។ ដូច្នេះបើយោងតាមវាក្យខណ្ឌ៩ និង១០ ផែនដីនិងភ្នំត្រូវបានបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ។ វាក្យខណ្ឌ១១ និង១២ ចែងថា លើសពីនេះទៅទៀត មេឃត្រូវបានបង្កើតឡើងក្នុងរយៈកាល២ថ្ងៃ។ ពាក្យភាសាអារ៉ាប់ដែលត្រូវបានប្រើក្នុងក្បាលដំបូងនៃវាក្យខណ្ឌ១១ នៃចំពូក ៤១ គឺពាក្យ«ثُمَّ»(អានថា ស៊ុមម៉ា) ដែលមានន័យថា«បន្ទាប់មក»ឬ«លើសពីនេះទៅទៀត»ឬ«មិនតែប៉ុណ្ណោះ»។ មានសេចក្តីបកប្រែព្រះគម្ពីរគួរអានជាច្រើនបានប្រើពាក្យ«បន្ទាប់មក» ដែលមានន័យថា«ក្រោយពីនោះ»។ បើពាក្យ«ស៊ុមម៉ា»ត្រូវបានគេបកប្រែដោយខុសឆ្គងថា«បន្ទាប់មក» នោះរយៈកាលសរុបនៃការបង្កើតមេឃនិងដីត្រូវជា៨ថ្ងៃ ដោយបញ្ច្រាសនឹងវាក្យខណ្ឌដទៃៗទៀតដែលថាមេឃនិងដីបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ ហើយថែមទាំងមិនស្របនឹងទ្រឹស្តីបន្ទុះមហិមា ក៏ដូចជាខ្លឹមសារក្នុងចំពូក២១ វាក្យខណ្ឌ៣៣ ដែលថាមេឃនិងដីត្រូវបានបង្កើតឡើងដំណាលគ្នា។

យ៉ាងណា ការបកប្រែពាក្យ«ស៊ុមម៉ា»ឱ្យបានត្រឹមត្រូវនោះគឺគួរប្រែថា«លើសពីនេះទៅទៀត»ឬ«មិនតែប៉ុណ្ណោះ»ឬ«ម្យ៉ាងវិញទៀត»។ លោក អាប់ឌុលឡោះ យូសុហ្វ អាលី បានបកប្រែពាក្យនេះទៅជាភាសាអង់គ្លេសថា«Moreover»ដែលមានន័យដូចបីពាក្យខាងលើ ដែលអាចនាំឱ្យយើងដឹងថា ទន្ទឹមនឹងផែនដី ព្រមទាំងភ្នំនិងអ្វីៗមួយចំនួនទៀតដែលត្រូវបានបង្កើតឡើងក្នុងរយៈកាល៦ថ្ងៃ មេឃត្រូវបានបង្កើតឡើងក្នុងរយៈកាល២ថ្ងៃដំណាលគ្នាផងដែរ។ ដូច្នេះអាចសរុបនៅតែ៦ថ្ងៃដដែល ពុំមែន៨ថ្ងៃនោះទេ។

ឧបមាអ្នកម៉ៅការសំណង់ម្នាក់បាននិយាយថា គាត់នឹងសាងសង់អគារមួយកម្ពស់១០ជាន់ ព្រមទាំងរបងព័ទ្ធជុំវិញឱ្យរួចរាល់ក្នុងរយៈពេល៦ខែ។ ក្រោយមកនៅពេលរួចរាល់អស់ គាត់បានបញ្ជាក់លម្អិតថា គ្រឹះខាងក្រោមចំណាយពេលអស់២ខែ តួអគារចំណាយពេលអស់៤ខែ ហើយខណៈដែលកំពុងចាក់គ្រឹះនិងសាងសង់តួអគារ គាត់បានសង់របងបណ្តើរៗចំណាយអស់ពេល២ខែដែរ។ ដូច្នេះហើយការណ៍ដែលគាត់និយាយពីដំបូង និងអ្វីដែលគាត់និយាយក្រោយពេលសាងសង់រួចរាល់គឺមិនផ្ទុយគ្នានោះទេ គ្រាន់តែពេលសាងសង់រួចគាត់បានផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតប៉ុណ្ណោះ។

## គ.មេឃនិងដីត្រូវបានបង្កើតឡើងដំណាលគ្នា

ព្រះគម្ពីរគួរអានចែងជាច្រើនកន្លែងអំពីការបង្កើតចក្រវាឡនេះ ដោយជួនកាលប្រើពាក្យថា «មេឃ និងដី» (មានចែងក្នុង ៧:៥៤, ១០:៣, ១១:៧, ២៥:៩, ៣២:៤, ៥០:៣៨, ៥៧:៤) ហើយជួនកាលប្រើពាក្យថា «ដី និងមេឃ» វិញ(មានចែងក្នុង ៤៩:៩ ដល់១២, ២:២៩, ២០:៤)។ ដើម្បីឱ្យកាន់តែជាក់ច្បាស់ ចំពូក ២១ វាក្យខណ្ឌ ៣០ បានចែងអំពីបន្ទុះមហិមា ហើយនឹងការណ៍ដែលមេឃ និងដីត្រូវបានបង្កើតឡើងដំណាលគ្នា។

ស្រដៀងគ្នានេះដែរ ចំពូក ២ វាក្យខណ្ឌ ២៩ ចែងថា៖

*«ទ្រង់ជាអង្គដែលបង្កើតនូវរាល់សព្វសារពើនៅលើផែនដីនេះសម្រាប់ពួកឯង។ បន្ទាប់មកទ្រង់សំដៅទៅឯមេឃ ហើយបង្កើតមេឃប្រាំពីរជាន់។ ហើយទ្រង់ដឹងជ្រាបបំផុតនូវសព្វសារពើទាំងឡាយ។»*(ព្រះគម្ពីរគួរអាន ២:២៩)

ឬអាចបកប្រែម្យ៉ាងទៀតថា៖

*«ទ្រង់ជាអង្គដែលបង្កើតនូវរាល់សព្វសារពើនៅលើផែនដីនេះសម្រាប់ពួកឯង។ លើសពីនេះទៅទៀតទ្រង់សំដៅទៅឯមេឃ ហើយបង្កើតមេឃប្រាំពីរជាន់។»*

ត្រង់នេះបើយើងបកប្រែពាក្យថា«ស៊ុមម៉ា»មកជា«បន្ទាប់មក»នៅវាក្យខណ្ឌនេះ មុខជានឹងមិនស្របនឹងទ្រឹស្ដីបន្ទុះមហិមា និងវាក្យខណ្ឌដទៃទៀតក្នុងព្រះគម្ពីរគួរអាន។ ដូច្នេះហើយពាក្យបកប្រែដែលត្រឹមត្រូវបំផុតនោះគឺប្រែមកជា«លើសពីនេះទៅទៀត»ឬ «មិនតែប៉ុណ្ណោះ»ឬ«ម្យ៉ាងវិញទៀត»។

# ១៥

# តើមនុស្សកើតមកអំពីទឹកអសុចិ ឬកើតមកពីដី?

## សំណួរ

មានកន្លែងមួយក្នុងព្រះគម្ពីរគួរអានចែងថាមនុស្សកើតមកអំពីទឹកអសុចិ[14] ហើយមានកន្លែងមួយទៀតចែងថាមនុស្សកើតមកអំពីដី។ តើការលើកឡើងទាំងពីរនេះមិនស្របគ្នាឬយ៉ាងណា? ហើយតើអាចពន្យល់តាមបែបវិទ្យាសាស្ត្របានទេថាមនុស្សកើតពីដីយ៉ាងដូចម្តេច?

## ចម្លើយ

### ក.មនុស្សកើតមកអំពីទឹកអសុចិ និងដី

ព្រះគម្ពីរគួរអានចែងអំពីដើមដំបូងនៃជីវិតមនុស្សដែលកើតអំពីដំណក់ទឹកអសុចិ ដោយមានចែងជាច្រើនកន្លែង ដូចជាចំពូក៧៥ខាងក្រោម៖

«*តើគេមិនមែនជាតំណក់ទឹកអសុចិដែលបញ្ចេញមកទេឬ?* » (ព្រះគម្ពីរគួរអាន ៧៥:៣៧)

ព្រះគម្ពីរគួរអានក៏បានចែងជាច្រើនកន្លែងដែលថាមនុស្សត្រូវបានបង្កើតមកអំពីដី។ ខាងក្រោមនេះគឺជាវាក្យខណ្ឌដែលចែងអំពីការណ៍នេះ៖

«*...យើងពិតជាបានបង្កើតឯងរាល់គ្នាអំពីដី...*» (ព្រះគម្ពីរគួរអាន ២២:៥)

យើងបានដឹងហើយថាសារធាតុដែលមានក្នុងសារពាង្គកាយយើងទាំងអស់ សុទ្ធតែមាននៅក្នុងធម្មជាតិ អាចក្នុងបរិមាណតិចឬច្រើន។ នេះជាការពន្យល់បែបវិទ្យាសាស្ត្រអំពីការណ៍ដែលព្រះគម្ពីរគួរអានលើកឡើងថាមនុស្សកើតមកអំពីដី។

---

[14] ជាពាក្យសមគួរនៃពាក្យថា«ទឹកកាម»។

ក្នុងវាក្យខណ្ឌដដែលនេះបញ្ជាក់ថាមនុស្សកើតមកអំពីទឹកអសុចិ ខណៈដែលវាក្យខណ្ឌខ្លះទៀតលើកឡើងថាមនុស្សកើតមកអំពីដី។ យ៉ាងណាមិញការលើកឡើងទាំងពីរនេះមិនបញ្ច្រាសគ្នាឡើយ។ ដែលថាបញ្ច្រាសគ្នានោះគឺទាល់តែការលើកឡើងនោះពីរឬច្រើនផ្ទុយគ្នាអំពីព្រឹត្តការណ៍តែមួយដែលមិនអាចកើតឡើងព្រមៗគ្នាបាន។

## ខ.មនុស្សកើតមកអំពីទឹក

មានកន្លែងខ្លះក្នុងព្រះគម្ពីរគួរអានចែងបានមនុស្សកើតមកអំពីទឹកផងដែរ។ ក្នុងចំពូក ២៥ បានចែងថា៖

*«ហើយព្រះអង្គជាអ្នកបង្កើតមនុស្សលោកអំពីទឹក...»* (ព្រះគម្ពីរគួរអាន ២៥:៥៤)

វិទ្យាសាស្ត្រសព្វថ្ងៃបានបញ្ជាក់ថាការលើកឡើងទាំង៣ខាងលើគឺត្រឹមត្រូវទាំងអស់។ មនុស្សត្រូវបានបង្កើតមកអំពីដី, ទឹកអសុចិ និងទឹក។

## គ.មិនបញ្ច្រាសគ្នាទេ តែដោយឡែកពីគ្នា

ឧបមាថា ខ្ញុំបាននិយាយថា បើគេចង់ឆុងតែមួយប៉ាន់ គេត្រូវការទឹក។ គេក៏ត្រូវការផងដែរនូវស្លឹកតែក្រៀម ឬម្សៅតែ។ ការលើកឡើងទាំងពីរខាងលើនេះមិនបញ្ច្រាសគ្នាឡើយ ដ្បិតដើម្បីឆុងតែមួយប៉ាន់បាន គេត្រូវការទាំងទឹកនិងទាំងតែ។ លើសពីនេះបើចង់ផ្អែម គេអាចដាក់ស្ករថែមទៀតក៏បាន។

ដូចគ្នាដែរព្រះគម្ពីរគួរអានមិនបានចែងបញ្ច្រាសគ្នាឡើយ នៅពេលដែលថា មនុស្សកើតអំពីទឹកអសុចិ ដី ឬទឹកនោះ។ នេះមិនមែនជាការចែងបញ្ច្រាសគ្នាទេ ក៏ប៉ុន្តែជាការចែងដោយឡែកពីគ្នា។ ដែលថាដោយឡែកពីគ្នានេះ គឺជាការនិយាយផ្នែកផ្សេងគ្នាអំពីប្រធានបទតែមួយដោយមិនបញ្ច្រាសគ្នា។ ឧបមាបើខ្ញុំនិយាយថា «គាត់ម្នាក់នោះស្មោះត្រង់ណាស់ ហើយក៏ក្រឡិចក្រឡុចផងដែរ» នេះជាការលើកឡើងបញ្ច្រាសគ្នា។ ប៉ុន្តែបើខ្ញុំនិយាយថា «គាត់ម្នាក់នោះស្មោះត្រង់ណាស់ ហើយចិត្តល្អ និងស្រឡាញ់រាប់អានគេឯងផង» នេះរាប់ថាជាការនិយាយដោយឡែក។

# ១៦

# ព្រះអល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ាទាំងពីរ និងទិសបស្ចិមទាំងពីរ

## សំណួរ

មានវាក្យខណ្ឌមួយនៃព្រះគម្ពីរគួរអានបានចែងថា ព្រះអល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ទាំង២ និងទិសបស្ចិមទាំង២។ តើគេអាចពន្យល់វាក្យខណ្ឌនេះតាមលក្ខណៈវិទ្យាសាស្ត្របានយ៉ាងដូចម្ដេច?

## ចម្លើយ

### ក.ព្រះគម្ពីរគួរអានបានចែងថា ព្រះអល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ទាំង២ និងទិសបស្ចិមទាំង២

វាក្យខណ្ឌមួយនៃព្រះគម្ពីរគួរអានដែលបានចែងថា ព្រះអល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ទាំង២ និងទិសបស្ចិមទាំង២នោះគឺនៅក្នុងចំពូក ៥៥៖

*«(ព្រះអង្គជា)ព្រះអម្ចាស់នៃទិសបូព៌ទាំងពីរ និងជាព្រះអម្ចាស់នៃទិសបស្ចិមទាំងពីរ។»* (ព្រះគម្ពីរគួរអាន ៥៥:១៧)

នៅក្នុងអត្ថបទជាភាសាអារ៉ាប់ ពាក្យ«ទិសបូព៌»និង«ទិសបស្ចិម»ត្រូវបានប្រើប្រាស់ក្នុងទម្រង់ទ្វិវចនៈ[15] ដែលបញ្ជាក់ថាឱ្យយើងដឹងថា ព្រះអល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ទាំងពីរ និងទិសបស្ចិមទាំងពីរ។

---

[15] ខុសពីភាសាខ្មែរដែលមានតែឯកវចនៈ(១គត់) និងពហុវចនៈ(២ឡើងទៅ) ភាសាអារ៉ាប់មានឯកវចនៈ(១គត់), ទ្វិវចនៈ(២គត់) និងពហុវចនៈ(៣ឡើងទៅ)។

## ខ.ព្រះអល់ឡោះជាព្រះអម្ចាស់នៃចុងបូព៌ទិស និងចុងបស្ចិមទិស

វិទ្យាសាស្ត្រខាងភូគព្ភវិទ្យាបានឱ្យយើងដឹងថាព្រះអាទិត្យរះចេញពីទិសបូព៌។ ប៉ុន្តែចំណុចដែលព្រះអាទិត្យរះនោះគឺរំកិលរហូតពេញមួយឆ្នាំ លើកលែងតែ២ថ្ងៃប៉ុណ្ណោះដែលរះចំទិសបូព៌ប្រាកដនោះគឺសមរាត្រី[16]ដែលមាន២ដងក្នុងមួយឆ្នាំ។ ក្រៅពីនោះព្រះអាទិត្យរះរំកិលមកខាងទិសឧត្តរខ្លះ និងខាងទិសទក្សិណខ្លះ។ ក្នុងរដូវក្តៅ សុរិយដ្ឋាន[17]នៃព្រះអាទិត្យរះរំកិលមកខាងទិសឧត្តរខ្លាំង ឯនៅក្នុងរដូវត្រជាក់វិញសុរិយដ្ឋាននៃព្រះអាទិត្យរះរំកិលមកខាងទិសទក្សិណខ្លាំង។ មិនខុសគ្នាឡើយ នៅពេលព្រះអាទិត្យលិចក្នុងរដូវក្តៅ សុរិយដ្ឋាននៃព្រះអាទិត្យលិចរំកិលមកខាងទិសឧត្តរខ្លាំង ឯនៅក្នុងរដូវត្រជាក់វិញ សុរិយដ្ឋាននៃព្រះអាទិត្យលិចក៏រំកិលមកខាងទិសទក្សិណខ្លាំងដូចគ្នា។ បាតុភូតនេះគេអាចសង្កេតមើលបានយ៉ាងងាយពៅទីក្រុងនានា និងអ្នករស់នៅទីណាក៏ដោយ ជាពិសេសអ្នករស់នៅអគារខ្ពស់ៗ ដោយចំណាំចំណុចដែលព្រះអាទិត្យរះនិងលិចក្នុងរដូវក្តៅ ធៀបនឹងរដូវត្រជាក់។ និយាយឱ្យខ្លី ក្នុងរយៈពេលពេញមួយឆ្នាំព្រះអាទិត្យរះនៅចំណុចខុសៗគ្នានៅទិសបូព៌ ហើយលិចនៅចំណុចខុសៗគ្នានៅទិសបស្ចិម។ ដូច្នេះនៅពេលដែលព្រះគម្ពីរគួរអានចែងថា អល់ឡោះជាព្រះអម្ចាស់នៃទិសបូព៌ទាំង២ និងទិសបស្ចិមទាំង២ នោះមានន័យថាព្រះអង្គជាព្រះអម្ចាស់នៃចុងទាំងពីរនៃទិសបូព៌(ចំណុចចុងពីរដែលព្រះអាទិត្យរះងាកមកទិសឧត្តរខ្លាំង និងទិសទក្សិណខ្លាំង) និងព្រះអង្គជាព្រះអម្ចាស់នៃចុងសងនៃទិសបស្ចិម(ចំណុចចុងពីរដែលព្រះអាទិត្យលិចងាកមកទិសឧត្តរខ្លាំង និងទិសទក្សិណខ្លាំង)។

## គ.ព្រះអល់ឡោះជាព្រះអម្ចាស់នៃគ្រប់ចំណុចទាំងអស់នៅទិសបូព៌ និងទិសបស្ចិម

វចនៈក្នុងភាសាអារ៉ាប់មានដល់ទៅ៣ ពោលគឺឯកវចនៈ(នាមដែលមានចំនួន១គត់), ទ្វិវចនៈ(នាមដែលមានចំនួន២គត់) និងពហុវចនៈ(នាមដែលមានចំនួន៣ឡើងទៅ)។ ក្នុងចំពូក ៥៥ វាក្យខណ្ឌ ៧១ ភាសាអារ៉ាប់ប្រើពាក្យ«ٱلْمَشْرِقَيْنِ»បកប្រែថា«ទិសបូព៌» និងពាក្យ«ٱلْمَغْرِبَيْنِ»បកប្រែថា«ទិសបស្ចិម»ដែលពាក្យទាំងពីរនេះប្រើក្នុងទម្រង់ទ្វិវចនៈ ដែលមានន័យថា«ទិសបូព៌ទាំង២» និង«ទិសបស្ចិមទាំង២»។

---

16 Equinox ព្រឹត្តិការណ៍២ដងប្រចាំឆ្នាំដែលថ្ងៃនឹងយប់មានរយៈពេលស្មើគ្នា។

17 Solstice ទីតាំងនៃព្រះអាទិត្យ។

សូមពិចារណាអំពីវាក្យខណ្ឌខាងក្រោមនេះ៖

«*យើងស្បថនឹងព្រះអម្ចាស់នៃទិសបូព៌ទាំងអស់ និងទិសបស្ចិមទាំងអស់ថា ពិតប្រាកដណាស់យើងគឺជាអ្នកដែលមានមហិទ្ធានុភាព។*» (ព្រះគម្ពីរគួរអាន ៧០:៤០)

ពាក្យភាសាអារ៉ាប់ត្រង់នេះដែលប្រើថា«ٱلْمَشَٰرِقِ»បកប្រែថា«ទិសបូព៌» និងពាក្យ«ٱلْمَغَٰرِبِ»បកប្រែថា«ទិសបស្ចិម»ដែលពាក្យទាំងពីរនេះប្រើក្នុងទម្រង់ពហុវចនៈវិញម្តងដែលមានន័យថា «ទិសបូព៌ទាំងអស់» និង«ទិសបស្ចិមទាំងអស់»។

យើងអាចសរុបជារួមបានថា ព្រះគម្ពីរគួរអានលើកឡើងអំពីព្រះអល់ឡោះជាព្រះអម្ចាស់នៃគ្រប់ចំណុចនៃទិសបូព៌ និងទិសបស្ចិម ក៏ដូចជាចុងទាំងពីរនៃទិសបូព៌ និងទិសបស្ចិមផងដែរ។

# ១៧

# តើ១ថ្ងៃសម្រាប់ព្រះអល់ឡោះ ស្មើនឹង១០០០ឆ្នាំ ឬ ៥០០០០ឆ្នាំសម្រាប់មនុស្សលោក?

## សំណួរ

មានវាក្យខណ្ឌក្នុងព្រះគម្ពីរគួរអានដែលចែងថា ១ថ្ងៃសម្រាប់ព្រះអល់ឡោះស្មើនឹង ១០០០ឆ្នាំសម្រាប់មនុស្សលោក ឯវាក្យខណ្ឌមួយទៀតចែងថា ១ថ្ងៃស្មើនឹង៥០០០០ ឆ្នាំទៅវិញ។ តើនេះមិនមែនមានន័យថាព្រះគម្ពីរគួរអានចែងបញ្ច្រាសគ្នាទេឬ?

## ចម្លើយ

### ក.ពេលវេលាចំពោះព្រះអល់ឡោះមិនអាចប្រៀបនឹងមនុស្សលោកបានឡើយ

ព្រះគម្ពីរគួរអានចែងក្នុងវាក្យខណ្ឌ២គឺនៅក្នុងចំពូក ២២ វាក្យខណ្ឌ ៤៧ និងចំពូក ៣២ វាក្យខណ្ឌ ៥ ដែលថារង្វាស់ពេលវេលា ១ ថ្ងៃចំពោះព្រះអល់ឡោះ ស្មើនឹង ១០០០ ឆ្នាំនៃពេលវេលារបស់មនុស្សលោក។ ហើយមានវាក្យខណ្ឌមួយទៀតនៅក្នុងចំពូក ៧០ វាក្យខណ្ឌ ៤ ដែលចែងថារង្វាស់ពេលវេលា ១ ថ្ងៃចំពោះព្រះអល់ឡោះ ស្មើនឹង ៥០០០០ ឆ្នាំនៃពេលវេលារបស់មនុស្សលោក។

វាក្យខណ្ឌទាំងនេះមានន័យជាទូទៅថា រង្វាស់ពេលវេលាចំពោះព្រះអល់ឡោះគឺមិនអាចយកមកប្រៀបធៀបនឹងរង្វាស់ពេលរបស់មនុស្សលោកឡើយ។ ព្រះគម្ពីរបានប្រើរយៈពេល ១០០០ឆ្នាំ ឬ៥០០០០ឆ្នាំនៃមនុស្សលោកជាឧបមា។ ម្យ៉ាងទៀតបើនិយាយដល់ពាក្យ «រាប់ពាន់ឆ្នាំ» គឺជារយៈកាលដ៏យូរនៃពេលវេលាមនុស្សលោក ប៉ុន្តែត្រឹមមួយថ្ងៃប៉ុណ្ណោះសម្រាប់ព្រះអល់ឡោះ។

## ខ.ពាក្យ«يوم»មានន័យថា យុគ ឬ សម័យ

ពាក្យភាសាអារ៉ាប់ដែលប្រើក្នុងវាក្យខណ្ឌទាំង៣ខាងលើគឺពាក្យ«يوم»(អានថា យ៉ូម)ដែលក្រៅពីមានន័យថា«ថ្ងៃ»ក៏មានន័យផងដែរថា«យុគ»ឬ«សម័យ»។ ប្រសិនបើគេបកប្រែពាក្យ«យ៉ូម»នេះឱ្យត្រឹមត្រូវថា«សម័យ»នោះនឹងមិនមានការភ័ន្តច្រឡំឡើយ។

**១**.វាក្យខណ្ឌមួយក្នុងចំពូក២២ចែងថា៖

*«ហើយពួកគេសុំឯងឱ្យឆាប់ធ្វើទោសភ្លាមៗ ព្រះអល់ឡោះមិនធ្វើខុសសន្យារបស់ព្រះអង្គឡើយ។ ហើយជាការប្រាកដណាស់ មួយថ្ងៃសម្រាប់ព្រះអម្ចាស់នៃឯងគឺ ដូចជាមួយពាន់ឆ្នាំតាមការគន់គូររបស់ឯងរាល់គ្នា។»* (ព្រះគម្ពីរគួរអាន ២២:៤៧)

នៅពេលដែលពួកអ្នកគ្មានជំនឿបន្ទាន់ឱ្យឆាប់ធ្វើទោសមកលើពួកគេ(ជាការផ្តើន) ព្រះគម្ពីរគួរអានបានចែងថា ព្រះអល់ឡោះនឹងមិនធ្វើឱ្យខុសសន្យារបស់ព្រះអង្គឡើយ។ ជាក់ស្តែងការធ្វើទោសនោះនឹងឆាប់មកដល់ទេ ដ្បិត១ថ្ងៃចំពោះព្រះអល់ឡោះ ប្រៀបបាននឹងរាប់ពាន់ឆ្នាំនៃមនុស្សលោក។

**២**.វាក្យខណ្ឌមួយក្នុងចំពូក ៣២ ចែងថា៖

*«ព្រះអង្គចាត់ចែងកិច្ចការតាំងពីលើមេឃរហូតដល់ផែនដី ក្រោយមកភារកិច្ចនោះនឹងឡើងទៅកាន់ទ្រង់វិញនៅថ្ងៃមួយដែលរយៈពេលរបស់វាស្មើនឹងមួយពាន់ឆ្នាំតាមការគន់គូររបស់ឯងរាល់គ្នា។»* (ព្រះគម្ពីរគួរអាន ៣២:៥)

វាក្យខណ្ឌនេះបង្ហាញឱ្យយើងដឹងថា រយៈកាលដែលកិច្ចការទាំងអស់ត្រូវឡើងទៅដល់ព្រះអល់ឡោះណោះគឺត្រូវការពេល១០០០ឆ្នាំតាមការគន់គូររបស់មនុស្សលោក ឬថាតាមការកំណត់ពេលវេលារបស់មនុស្សលោក។

**៣**.វាក្យខណ្ឌមួយក្នុងចំពូក ៧០ ចែងថា៖

*«បណ្តាទេវតា និងវិញ្ញាណបរិសុទ្ធ[18]ឡើងទៅកាន់ព្រះអង្គក្នុងមួយថ្ងៃដែលមានរយៈពេលហាសិបពាន់ឆ្នាំ។»* (ព្រះគម្ពីរគួរអាន ៧០:៤)

---

[18] វិញ្ញាណបរិសុទ្ធ ជាគោរមងារដែលព្រះជាម្ចាស់ប្រទានឱ្យទេវតាកាព្រីយ៉ែល។

វាក្យខណ្ឌនេះបង្ហាញឱ្យយើងដឹងថា រយៈកាលដែលបណ្តាទេវតា និងវិញ្ញាណបរិសុទ្ធត្រូវឡើងទៅដល់ព្រះអស់ឡោះណោះគឺត្រូវការពេល៥០០០០ឆ្នាំតាមការគន់គូររបស់មនុស្សលោក ឬថាតាមការកំណត់ពេលវេលារបស់មនុស្សលោក។

កិច្ចការពីរដោយឡែកពីគ្នា គឺត្រូវការរយៈពេលមិនដូចគ្នាទេ។ ឧទាហរណ៍ ខ្ញុំធ្វើដំណើរពីភ្នំពេញទៅក្រចេះចំណាយពេល៥ម៉ោង ហើយបើខ្ញុំធ្វើដំណើរពីភ្នំពេញទៅកំពតប្រើពេល២ម៉ោង នេះមិនមែនមានន័យថាខ្ញុំលើកឡើងអំពីរយៈកាលមកខុសគ្នា ហើយផ្តល់ព័ត៌មានបញ្ច្រាសគ្នានោះទេ។

នេះមិនត្រឹមតែថា ព្រះគម្ពីរគួរអានមិនបានចែងបញ្ច្រាសគ្នានោះទេ ថែមទាំងចុះសម្រុងគ្នានឹងអ្វីដែលវិទ្យាសាស្រ្តបានរកឃើញផង។

# ១៨

# តើអ៊ីព្លីស[19]ជាទេវតា[20] ឬជាអារក្សយីសាច[21]?

## សំណួរ

នៅក្នុងព្រះគម្ពីរគួរអានមានចែងជាច្រើនកន្លែងដែលថា អ៊ីព្លីស ធ្លាប់ជាទេវតា ប៉ុន្តែក្នុងចំពូក ១៨ ចែងថា អ៊ីព្លីស ជាអារក្សបីសាចវិញ។ តើនេះមិនមែនជាការចែងបញ្ច្រាសគ្នាទេឬ?

## ចម្លើយ

រឿងរ៉ាវរបស់ព្យាការីអាដាំ និងអ៊ីព្លីស ត្រូវបានចែងជាច្រើនកន្លែងដែរនៅក្នុងព្រះគម្ពីរគួរអាន ដែលព្រះអល់ឡោះមានព្រះបន្ទូលថា«យើងបានមានព្រះបន្ទូលទៅកាន់បណ្តាទេវតាថា៖ *«ចូរឯងរាល់គ្នាក្រាបកាយ(សម្តែងការវកិច្ច)ចំពោះអាដាំចុះ ។ គ្រានោះបណ្តាទេវតាបានក្រាបកាយទាំងអស់ លើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលបានប្រឆាំង។»* ខ្លឹមសារស្រដៀងៗគ្នានេះក៏បានចែងផងដែរនៅក្នុង៖

ចំពូក ២ វាក្យខណ្ឌ ៣៤

ចំពូក ៧ វាក្យខណ្ឌ ១៧

ចំពូក ១៥ វាក្យខណ្ឌ ២៨ ដល់ ៣១

ចំពូក ១៧ វាក្យខណ្ឌ ៦១

---

[19] إِبْلِيس ជាឈ្មោះរបស់អារក្សសាតាំងកាលដែលវានៅបម្រើព្រះជាម្ចាស់។ ក្រោយមកវាបានប្រឆាំងនឹងព្រះជាម្ចាស់ហើយបានក្លាយជាអារក្សបីសាច។

[20] ملائِكة ជាភូតម្យ៉ាងដែលព្រះជាម្ចាស់បង្កើតឡើងមកពីពន្លឺ។ ពួកគេកើតមកដើម្បីគោរពសក្ការៈនិងបម្រើព្រះជាម្ចាស់តែម្យ៉ាងគត់។

[21] جن ជាភូតម្យ៉ាងដែលព្រះជាម្ចាស់បង្កើតមកពីភ្លើងគ្មានផ្សែង។ គេអាចហៅថា អមនុស្ស ក៏បាន។ ពួកនេះប្រហាក់ប្រហែលនឹងមនុស្សលោកដែរ ដ្បិតវាមានសេរីភាពខាងជំនឿ និងការប្រព្រឹត្ត មិនដូចទេវតានោះទេ ហើយរស់នៅឯភពដោយឡែក។

ចំពូក ២០ វាក្យខណ្ឌ ១១៦
ចំពូក ៣៨ វាក្យខណ្ឌ ៧១ ដល់ ៧៤

ក៏ប៉ុន្តែក្នុងចំពូក ១៨ វាក្យខណ្ឌ ៥០ ចែងថា៖

*«ហើយនៅពេលដែលយើងបានមានព្រះបន្ទូលទៅកាន់បណ្តាទេវតាថា៖ ចូរឯងរាល់គ្នាក្រាបកាយសម្តែងគារវកិច្ចចំពោះអាដាំចុះ ។ គ្រានោះបណ្តាទេវតាបានក្រាបកាយទាំងអស់ លើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលស្ថិតក្នុងចំណោមពួកអារក្សបីសាច។»*

## ខ.បញ្ញត្តិ«تغليب»នៅក្នុងភាសាអារ៉ាប់

ការបកប្រែវាក្យខណ្ឌខាងលើថា«*យើងបានមានព្រះបន្ទូលទៅកាន់បណ្តាទេវតាថា៖ ចូរឯងរាល់គ្នាក្រាបកាយ(សម្តែងគារវកិច្ច)ចំពោះអាដាំចុះ ។ គ្រានោះបណ្តាទេវតាបានក្រាបកាយទាំងអស់ លើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលបានប្រឆាំង។*» បានឱ្យយើងដឹងថាអ៊ីព្លីសក៏ស្ថិតក្នុងចំណោមបណ្តាទេវតាដែរ។

ព្រះគម្ពីរគួរអានត្រូវបានប្រទានចុះមកជាភាសាអារ៉ាប់។ ក្នុងវេយ្យាករណ៍អារ៉ាប់មានបញ្ញត្តិមួយដែលហៅថា«تغليب»(អានថា តាក់លីប) ដែលទំនងមានន័យជាភាសាខ្មែរថា«សមូហសព្វនាម»។ បើយោងតាមបញ្ញត្តិនេះ បើគេលើកឡើងអំពីអ្វីៗដែលជាភាគច្រើនហើយ អ្វីៗដែលជាភាគតិចនៅក្នុងនោះក៏ត្រូវបានរាប់បញ្ចូលដែរ បើទោះគេមិនលើកឡើងក៏ដោយ។ ជាឧទាហរណ៍ បើខ្ញុំនិយាយអំពីបន្ទប់រៀនមួយដែលមានសិស្ស១០០នាក់ ហើយក្នុងមាន៩៥នាក់អាយុតិចជាខ្ញុំ ហើយមាន៥នាក់អាយុច្រើនជាងខ្ញុំ។ ហើយបើខ្ញុំនិយាយជាភាសាអារ៉ាប់ថា«សូមប្អូនៗទាំងអស់គ្នាក្រោកឈរ» នោះក៏មានន័យថា អ្នកទាំង៥ដែលមានអាយុច្រើនជាងខ្ញុំក៏ត្រូវក្រោកឈរដែរ ទោះជាខ្ញុំមិនបានប្រើពាក្យ«បងៗ»ក៏ដោយ។

នៅក្នុងព្រះគម្ពីរគួរអានក៏មិនខុសគ្នាដែរ នៅពេលព្រះជាម្ចាស់ត្រាស់បង្គាប់ដល់បណ្តាទេវតា ទាំងពេលនោះអ៊ីព្លីសក៏នៅទីនោះដែរ ប៉ុន្តែព្រះមិនបាច់លើកឡើងដោយបង្គាប់ទេវតាផង និងអ៊ីព្លីសផងនោះទេ។ ហើយបើយើងពិនិត្យមើលប្រយោគនេះ អ៊ីព្លីសអាចជាទេវតាផង និងមិនមែនជាទេវតាផង ប៉ុន្តែយើងបានដឹងច្បាស់នៅក្នុងចំពូក ១៨ វាក្យខណ្ឌ ៥០ ដែលចែងថា អ៊ីព្លីសជាអារក្សបីសាច។ គ្មានកន្លែងណាមួយក្នុងព្រះគម្ពីរ

គួរអានថែងថាអ៊ីព្លីសជាទេវតានោះឡើយ។ យ៉ាងនេះហើយគ្មានការចែងបញ្ជាក់សគ្នានោះ ឡើយនៅក្នុងព្រះគម្ពីរ។

## គ.អារក្សបីសាចមានសេរីភាពខាងជំនឿ និងការប្រព្រឹត្ត ហើយអាច ប្រឆាំងទាស់នឹងព្រះជាម្ចាស់

យើងក៏ត្រូវដឹងដែរថា អារក្សបីសាចមានសេរីភាពអាចស្តាប់បង្គាប់ឬប្រឆាំងទាស់ នឹងព្រះជាម្ចាស់បាន ក៏ប៉ុន្តែទេវតាវិញគ្មានសេរីភាពនោះឡើយ ហើយពួកគេតែងតែស្តាប់ បង្គាប់ព្រះជានិច្ច។ យ៉ាងនេះហើយ គេមិនបាច់សួរអំពីរឿងទេវតាប្រឆាំងទាស់នឹងព្រះជា ម្ចាស់នោះឡើយ។ សរុបជារួមមក អ៊ីព្លីសគឺជាអារក្សបីសាច មិនមែនជាទេវតានោះទេ។

# ១៩

# ព្រះគម្ពីរគួរអានគណនាគណិតវិទ្យាមិនត្រឹមត្រូវ

## សំណួរ

យោងតាមការលើកឡើងរបស់លោក អារុណ សូរី ថាព្រះគម្ពីរគួរអានមានកំហុសខាងគណិតវិទ្យា។ ក្នុងចំពូក ៤ វាក្យខណ្ឌ ១១ និង ១២ នៅពេលដែលបូកសរុបភាគទាំងអស់នៃមរតកដែលត្រូវចែកទៅសន្តតិជន[22] ឃើញថាលើសពី១០០ភាគរយនៃទ្រព្យ។ នេះបញ្ជាក់ថាព្រះគម្ពីរគួរអានគណនាគណិតវិទ្យាមិនត្រឹមត្រូវ។

## ចម្លើយ

ព្រះគម្ពីរគួរអានចែងអំពីសន្តតិកម្ម[23]ជាច្រើនកន្លែងដូចជាៈ

ចំពូក ២ វាក្យខណ្ឌ ១៨០
ចំពូក ២ វាក្យខណ្ឌ ២៤០
ចំពូក ៤ វាក្យខណ្ឌ ៧ ដល់ ៩
ចំពូក ៤ វាក្យខណ្ឌ ១៩ ដល់ ៣៣
ចំពូក ៥ វាក្យខណ្ឌ ១០៥ ដល់ ១០៨

ទាក់ទងនឹងចំណែកសន្តតិកម្មនេះ គឺមានចែងយ៉ាងច្បាស់លាស់នៅក្នុងចំពូក ៤ វាក្យខណ្ឌ ១១ដល់១២ និងវាក្យខណ្ឌ ១៧៦។

សូមពិនិត្យមើលខ្លឹមសារនៃវាក្យខណ្ឌនេះជាមួយគ្នាៈ

*«ព្រះអល់ឡោះទ្រង់ត្រាស់បង្គាប់ឱ្យឯងរាល់គ្នាគិតគូពីកូនចៅរបស់ឯងរាល់គ្នា (ដោយបែងចែកមរតកសម្រាប់ពួកគេ) ដោយសម្រាប់កូនប្រុសម្នាក់(ទទួលមរតក)ស្មើនឹង*

[22] អ្នកដែលត្រូវទទួលមរតក។

[23] ការបែងចែងមរតក។

*ចំណែកកូនស្រីពីរនាក់។ តែប្រសិនបើសពមានតែកូនស្រីពីរនាក់ឬលើសពីនេះ គឺពួកនាងទទួលបានពីរភាគបីនៃមរតកនោះ។ ហើយប្រសិនបើសពមានតែកូនស្រីម្នាក់ គឺនាងទទួលបានពាក់កណ្ដាលចំណែក។ ហើយចំពោះឪពុកម្ដាយនៃសពវិញ ម្នាក់ៗត្រូវទទួលបានមួយភាគប្រាំមួយនៃមរតក ប្រសិនបើសពនោះមានកូន។ តែប្រសិនបើសពនោះគ្មានកូនទេនោះ គឺឪពុកម្ដាយជាអ្នកទទួលមរតកនោះទាំងស្រុង ដោយម្ដាយសពទទួលបានមួយភាគបី។ តែប្រសិនបើសពនោះមានបងប្អូនចាប់ពីពីរនាក់ឡើងទៅ គឺម្ដាយសពទទួលបានមួយភាគប្រាំមួយបន្ទាប់ពីបំពេញតាមបណ្ដាំមរតករបស់សពរួច ឬបន្ទាប់ពីសងបំណុលរបស់សពរួច។ ឯងរាល់គ្នាមិនបានដឹងទេថា រវាងឪពុកម្ដាយនិងកូនៗរបស់ឯងរាល់គ្នា តើអ្នកណាមួយដែលមានប្រយោជន៍ច្រើនសម្រាប់ឯងរាល់គ្នា។ (ទាំងនេះ)ជាកាតព្វកិច្ចមកពីព្រះអល់ឡោះ។ ពិតប្រាកដណាស់ ព្រះអល់ឡោះទ្រង់ដ៏ជ្រាបដឹង ទ្រង់ដ៏ព្រះប្រាជ្ញាញាណ។ ហើយសម្រាប់ឯងរាល់គ្នា(ជាស្វាមី)ត្រូវទទួលបានពាក់កណ្ដាល នៃមរតកដែលបណ្ដាភរិយារបស់ឯងរាល់គ្នាបានបន្សល់ទុក ប្រសិនបើពួកនាងគ្មានកូនទេនោះ។ តែបើពួកនាងមានកូនវិញ គឺឯងរាល់គ្នាទទួលបានមួយភាគបួនពីមរតកដែលពួកនាងបានបន្សល់ទុក បន្ទាប់ពីបំពេញតាមបណ្ដាំមរតកដែលពួកនាង(សព)ផ្ដែផ្ដាំ ឬសងបំណុលរបស់ពួកនាងរួច។ រីឯពួកនាង(ជាភរិយា)វិញត្រូវទទួលបានមួយភាគបួនពីមរតកដែលឯងរាល់គ្នា(ជាប្ដី) បានបន្សល់ទុក ប្រសិនបើឯងរាល់គ្នាគ្មានកូនទេនោះ។ តែបើឯងរាល់គ្នាមានកូនវិញ គឺពួកនាងទទួលបានមួយភាគប្រាំបីប៉ុណ្ណោះពីមរតកដែលឯងរាល់គ្នាបានបន្សល់ទុកបន្ទាប់ពីបំពេញតាមបណ្ដាំមរតកដែលឯងរាល់គ្នា (សព) ផ្ដែផ្ដាំ ឬសងបំណុលរបស់ឯងរាល់គ្នារួច។ ដោយឡែកបុរសឬស្ត្រី(សព)ដែលគ្មានកូន គ្មានឪពុក តែគាត់មានបងប្អូនប្រុសម្នាក់ ឬបងប្អូនស្រីម្នាក់គឺ គេម្នាក់ៗទទួលបានមួយភាគប្រាំមួយ។ តែបើពួកគេមានគ្នាលើសពីពីរនាក់ គឺពួកគេទទួលបានមួយភាគបីរួមគ្នាបន្ទាប់ពីបំពេញតាមបណ្ដាំមរតករបស់សព ឬសងបំណុល(របស់សព)រួចរាល់ដោយគ្មានផលប៉ះពាល់(លើអ្នកទទួលមរតក)ឡើយ។ (ទាំងនេះ)ជាសេចក្ដីត្រាស់បង្គាប់មកពីព្រះអល់ឡោះ។ ព្រះអល់ឡោះទ្រង់ដ៏ជ្រាបដឹង ទ្រង់ដ៏ខន្តី។»* (ព្រះគម្ពីរគួរអាន ៤:១១ដល់១២)

សាសនាអ៊ិស្លាមបានបង្ហាញពីបញ្ញត្តិនៃសន្តតិកម្មយ៉ាងល្អិតល្អន់ នឹងមានរៀបរាប់ជាក់ស្ដែងបន្ថែមទៀតនៅក្នុងមគ្គវចនៈរបស់ព្យាការី។

គេអាចចំណាយពេលសឹងមួយជីវិតដើម្បីសិក្សាអំពីបញ្ញត្តិសន្តតិកម្មក្នុងសាសនាអ៊ីស្លាមដោយសិក្សាពីករណីជាច្រើនដែលអាចកើតមាន។ ឯលោក អារុណ សូរី គិតថាខ្លួនបានយល់ដឹងសព្វគ្រប់អំពីបញ្ញត្តិនេះដោយគ្រាន់តែអានវាក្យខណ្ឌទាំងពីរខាងលើ ដោយមិនទាំងដឹងអំពីលក្ខណៈវិនិច្ឆ័យផង។

វាដូចនឹងមនុស្សម្នាក់ដែលចង់ដោះស្រាយសមីការគណិតវិទ្យា ក៏ប៉ុន្តែមិនចេះមូលដ្ឋាននៃគណិតវិទ្យាផង។ ឧទាហរណ៍ បើគេចង់ដោះស្រាយចំណោទគណិតមួយ គេត្រូវដឹងអំពីលំដាប់លំដោយនៃការគណនា៖ ទីមួយ បំបាត់វង់ក្រចក, ទីពីរគណនាប្រភាគ(ឬសញ្ញាចែក), ទីបី គណនាសញ្ញាគុណ, ទីបួន គណនាសញ្ញាបូក និងទី៥ គណនាសញ្ញាដក។ បើលោក អារុណ សូរី មិនចេះក្បួននេះទេហើយគាត់ចាប់ផ្តើមដោយគុណ ហើយបន្ទាប់មកដក ហើយបំបាត់វង់ក្រចក រួចទើបចែក ហើយបូកតាមក្រោយនេះ ចម្លើយដែលគាត់ទទួលបានមុខជាខុសមិនខាន។

មិនខុសគ្នាដែរ ព្រះគម្ពីរគួរអានចែងអំពីបញ្ញត្តិនៃសន្តតិកម្មក្នុងចំពូក ៤ វាក្យខណ្ឌ ១១ និង ១២ សូម្បីតែចំណែកមរតករបស់ក្មេងក៏ត្រូវបានលើកឡើងមុខ ចំណែករបស់ឪពុកម្តាយ និងប្តី/ប្រពន្ធនៃសពទៅទៀត។ តាមបញ្ញត្តិសន្តតិកម្មនៃសាសនាអ៊ីស្លាម បន្ទាប់ពីសងបំណុល និងបំពេញតាមបណ្តាំសពដែលត្រូវធ្វើមុនគេរួចរាល់ ចំណែករបស់ប្តី/ប្រពន្ធ និងឪពុកម្តាយនៃសពគឺត្រូវបែងចែកផ្អែកទៅលើថាតើសពមានកូនឬអត់ ហើយត្រូវចែករវាងកូនប្រុស និងកូនស្រីតាមចំណែកដែលពួកគេត្រូវទទួលបាន។

ដូច្នេះតើការណ៍ដែលសួរថាភាគនៃទ្រព្យបែងចែកសរុបមិនស្មើ១០០ភាគរយនោះ តើអាចមានអ្នកឆ្ងល់ដែរឬទេ?(បើយក១០០ភាគរយមកចែកទៅហើយនោះ)។ ដូច្នេះមិនមែនព្រះជាម្ចាស់គណនាខុសនោះទេ គឺលោក អារុណ សូរី ខ្លួនឯងដែលមិនចេះគណិតវិទ្យា។

# ២០

# តើព្រះអល់ឡោះជាព្រះដ៏អភ័យទោស ឬជាព្រះដ៏ចងអាឃាត?

## សំណួរ

ព្រះគម្ពីរគួរអានបានចែងជាច្រើនកន្លែងថា ព្រះអល់ឡោះជាព្រះដ៏មេត្តាករុណា និងអភ័យទោស ហើយក៏ចែងផងដែរថាព្រះអង្គជាព្រះដែលធ្វើទោសដ៏ក្រៃលែង។ តើព្រះអល់ឡោះជាព្រះដ៏អភ័យទោស ឬជាព្រះដ៏ចងអាឃាត?

## ចម្លើយ

### ក.ព្រះអល់ឡោះជាព្រះដ៏មេត្តាករុណា

ព្រះគម្ពីរគួរអានបានចែងយ៉ាងច្រើនថា ព្រះអល់ឡោះជាព្រះដ៏មេត្តាករុណា។ ជាការពិត ចំពូកទាំង១១៤នៃព្រះគម្ពីរគួរអាន(លើកលែងចំពូក៩) សុទ្ធតែផ្ដើមដោយឃ្លាថា «*ក្នុងព្រះនាមនៃព្រះអល់ឡោះ ទ្រង់ដ៏មេត្តាករុណា ដ៏អាណិតអាសូរ* »។

### ខ.ព្រះអល់ឡោះជាព្រះដ៏អភ័យទោស

ព្រះគម្ពីរគួរអានក៏បានចែងយ៉ាងច្រើនថា ព្រះអល់ឡោះជាព្រះដ៏អភ័យទោស ដូចមានក្នុងចំពូក ៤ វាក្យខណ្ឌ ២៥ និងចំពូក ៥ វាក្យខណ្ឌ ៧៤៖

«*ហើយព្រះអល់ឡោះ ជាព្រះដ៏អភ័យទោស ដ៏មេត្តាករុណា*»

### គ.ព្រះអល់ឡោះទ្រង់ដាក់ទោសដល់អ្នកដែលសមនឹងទទួលការដាក់ទោស

ព្រះអល់ឡោះក្រៅតែពីព្រះដ៏មេត្តាករុណា ព្រះអង្គក៏ជាអ្នកដាក់ទោសដ៏តឹងរឹងបំផុតដល់អ្នកដែលសមនឹងដាក់ទោស។ ព្រះគម្ពីរគួរអានចែងអំពីការណ៍ដែលព្រះជាម្ចាស់ដាក់ទោសយ៉ាងក្រៃលែងចំពោះនរណាហើយដែលបដិសេធជំនឿ និងអ្នកដែលមិនស្ដាប់បង្គាប់ទ្រង់។ មានវាក្យខណ្ឌជាច្រើនចែងអំពីប្រភេទនៃទោសទណ្ឌ ដែលព្រះអល់ឡោះនឹងធ្វើទោសអ្នកមិនស្ដាប់បង្គាប់ទាំងឡាយនៅឯស្ថាននរក។

*«ជាការប្រាកដណាស់ អស់អ្នកណាហើយដែលប្រឆាំងនឹងទីសម្គាល់នៃយើង យើងនឹងបញ្ជូនគេចូលទៅស្ថាននរក។ រាល់ពេលដែលស្បែករបស់គេឆេះអស់ យើងនឹងប្ដូរស្បែកផ្សេងទៀតដើម្បីពួកគេទទួលរសជាតិនៃការធ្វើទោស។ ជាការប្រាកដណាស់ព្រះអល់ឡោះជាព្រះដ៏ពលានុភាព ដ៏ប្រាជ្ញាញាណ។»* (ព្រះគម្ពីរគួរអាន ៤:៥៦)

## ឃ.ព្រះអល់ឡោះជាព្រះដ៏យុត្តិធម៌

សំណួរសួរថា តើព្រះអល់ឡោះជាព្រះដ៏មេត្តាករុណា ឬជាព្រះដ៏ចងអាឃាត? រឿងដែលសំខាន់បំផុតនោះគឺថា ព្រះអង្គក្រៅតែពីជាព្រះដ៏មេត្តាករុណា និងអភ័យទោស ទ្រង់ក៏ជាព្រះដែលដាក់ទោសដល់មនុស្សអាក្រក់ទុច្ចរិតទាំងឡាយផងដែរ នេះក៏ព្រោះតែទ្រង់ក៏ជាព្រះដ៏យុត្តិធម៌។ ព្រះគម្ពីរគួរអានបានចែងថា៖

*«ការជាប្រាកដណាស់ ព្រះអល់ឡោះមិនអយុត្តិធម៌ឡើយ សូម្បីប៉ុនល្អងធូលីក៏ដោយចុះ។»* (ព្រះគម្ពីរគួរអាន ៤:៤០)

កាន់តែស៊ីជម្រៅថែមទៀតនោះ ចំពូក ២១ ចែងថា៖

*«ហើយយើងនឹងដាក់ជញ្ជីងយុត្តិធម៌នៅថ្ងៃដែលប្រោសឱ្យរស់ឡើងវិញ។ ដូច្នេះមនុស្សគ្រប់រូបនឹងមិនត្រូវគេបំបាត់អ្វីបន្តិចឡើយ សូម្បីតែប៉ុនគ្រាប់ស្ពៃ ក៏យើងនាំវាមក (ជំនុំជម្រះ)ដែរ។ គ្រប់គ្រាន់ហើយយើងជាអ្នកជម្រះបញ្ជីរនោះ។»* (ព្រះគម្ពីរគួរអាន ២១:៤៧)

## ង.ឧទាហរណ៍អំពីសិស្សលួចចម្លង

បើនៅក្នុងការប្រឡង មានសិស្សបានលួចចម្លង ហើយគ្រូដែលជាអនុរក្សនោះចាប់បានជាក់ស្ដែង ហើយគ្រូនោះក៏និយាយឡើងថា ខ្លួនជាមនុស្សដែលពេញដោយក្ដីមេត្តា

ករុណា និងសប្បុរស ហើយបានអភ័យទោសដល់សិស្សនោះ ព្រមទាំងឱ្យគេប្រឡងបន្តផង។ សិស្សឯទៀតដែលគេខំប្រឹងយ៉ាងសស្រាក់សស្រាំក្នុងការប្រឡងនោះ មិនយល់ថាគ្រូជាមនុស្សពេញដោយក្តីមេត្តា និងសប្បុរសឡើយ តែនឹងទុកជាមនុស្សដ៏អយុត្តិធម៌ទៅវិញ។ ហើយក្តីមេត្តារបស់អនុរក្សនេះនឹងជំរុញឱ្យសិស្សផ្សេងៗទៀតលួចចម្លងដែរ។ បើគ្រូទាំងអស់សុទ្ធតែពេញដោយក្តីមេត្តា និងចិត្តសប្បុរសហើយឱ្យសិស្សលួចចម្លងគ្រប់គ្នានោះប្រាកដជាគ្មានសិស្សណាខិតខំរៀនសូត្រនោះទេ ហើយមុខជាប្រឡងជាប់ទាំងអស់គ្នាដោយគ្មានតម្លៃអ្វីទាំងអស់។ បើការណ៍នេះកើតឡើងមែននោះ លទ្ធផលនៃការប្រឡងមុខជាល្អប្រសើរគ្រប់ៗគ្នាហើយជាប់បានបន្តទៅមុខទៀត ក៏ប៉ុន្តែនៅពេលដែលគេអនុវត្តន៍ចំណេះដឹងទាំងនេះក្នុងជីវភាពប្រចាំថ្ងៃ គេមុខជាបរាជ័យមិនខាន។ ការប្រឡងនេះគ្មានន័យខ្លឹមសារអ្វីទាំងអស់។

## ច.ជីវិតនេះជាការល្បងសម្រាប់ជីវិតបរលោក

ជីវិតលើលោកនេះគ្រាន់តែជាការល្បងសម្រាប់បរលោកប៉ុណ្ណោះ។ ព្រះគម្ពីរគួរអានចែងថា៖

*«(ព្រះអង្គ)គឺជាព្រះអម្ចាស់ដែលបានបង្កើតសេចក្តីស្លាប់ និងសេចក្តីរស់ដើម្បីល្បងឯងរាល់គ្នា តើក្នុងចំណោមឯងរាល់គ្នា អ្នកណាមួយដែលបានសាងអំពើល្អជាងគេ។ ហើយព្រះអង្គដ៏ឫទ្ធានុភាព ដ៏អភ័យទោស។»* (ព្រះគម្ពីរគួរអាន ៦៧:២)

## ឆ.បើព្រះអល់ឡោះមានតែមេត្តាករុណា ហើយគ្មានការដាក់ទោស

ប្រសិនបើព្រះអល់ឡោះអភ័យទោសដល់មនុស្សគ្រប់រូប ហើយមិនដាក់ទោសអ្នកណាសោះនោះ តើមានហេតុផលអ្វីដែលមនុស្សត្រូវស្តាប់បង្គាប់ព្រះ? បើយ៉ាងនោះមែន ខ្ញុំឯកភាពថា មុខជាគ្មានអ្នកណាធ្លាក់ចូលស្ថាននរកនោះទេ ប៉ុន្តែផែនដីនេះមុខជាក្លាយជានរកមិនខាន។ ហើយបើមនុស្សទាំងអស់សុទ្ធតែបានចូលស្ថានសួគ៌នោះ តើមនុស្សចាំបាច់មកកើតនិងរស់នៅលើផែនដីនេះធ្វើអ្វី? នោះជីវិតនឹងមែនជាការល្បងទៀតទេ ហើយការល្បងក៏គ្មានន័យខ្លឹមសារអ្វីផងដែរ។

## ជ.ព្រះអល់ឡោះទ្រង់អភ័យទោសដល់អ្នកសារភាពទោសប៉ុណ្ណោះ

ព្រះអល់ឡោះទ្រង់អភ័យទោសដល់អ្នកណាដែលចេះសារភាពទោសកំហុសប៉ុណ្ណោះ។ ព្រះគម្ពីរគួរអានចែងថា៖

*«ចូរឯងពោលថា៖ ម្នាលអស់អ្នកបម្រើទាំងឡាយរបស់យើងដែលបានបំពានលើខ្លួនឯង(ប្រព្រឹត្តបាប)។ ចូរកុំអស់សង្ឃឹមចំពោះក្តីមេត្តាករុណានៃព្រះអល់ឡោះឱ្យសោះ ដ្បិតព្រះអល់ឡោះទ្រង់អភ័យទោសរាល់បាបទាំងអស់។ ព្រះអង្គជាព្រះដ៏អភ័យទោស ដ៏មេត្តាករុណា។ ចូរបែរត្រឡប់ទៅព្រះអម្ចាស់នៃឯងវិញ ហើយចូរថ្វាយខ្លួនដល់ព្រះអង្គ មុននឹងការធ្វើទោសមកដល់ឯងរាល់គ្នា។ បន្ទាប់ពីនោះ ឯងរាល់គ្នាឥតមានអ្នកណាជួយបានឡើយ។ ហើយចូរបដិបត្តិឱ្យបានខ្ជាប់ខ្ជួន(តាមព្រះគម្ពីរ)ដែលបានប្រទានចុះមកដល់ឯងពីព្រះអម្ចាស់នៃឯងរាល់គ្នា មុននឹងការធ្វើទោសមកដល់ឯងរាល់គ្នាមួយរំពេច ទាំងមិនបានដឹងខ្លួនមុន។»* (ព្រះគម្ពីរគួរអាន ៣៩:៥៣ ដល់ ៥៥)

មានលក្ខខណ្ឌបួនយ៉ាងក្នុងការសារភាពទោសកំហុស៖ ទីមួយ ត្រូវទទួលស្គាល់ថាអ្វីដែលយើងបានប្រព្រឹត្តពិតជាខុសពិតមែន។ ទីពីរ ត្រូវបញ្ឈប់កិច្ចការខុសឆ្គងនោះជាបន្ទាន់។ ទីបី មិនប្រព្រឹត្តកិច្ចការខុសឆ្គងនោះម្តងទៀតនៅពេលខាងមុខ។ ទីបួន ចុងក្រោយគឺត្រូវសុំអភ័យទោស និងសងប៉ះប៉ូវឡើងវិញក្នុងករណីកំហុសនោះប៉ះពាល់ដល់អ្នកដទៃ។

